សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ

និង វិទ្យាសាស្ត្រសេដ្ឋកិច្ច


## របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងឥណទានខ្នាតតូច និងមធ្យម

កម្មសិក្សាពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៧ ដល់ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០១៧

ឈ្មោះស្ថាប័ន៖ **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត សាខាស្រុកបាត្តំ**


| | |
|---|---|
| តាក់តែងឡើងដោយ | សាស្ត្រាចារ្យណែនាំ |
| និស្សិតឈ្មោះ **លី រដ្ឋា** | លោក **ជា សែម** |
| ថ្នាក់បរិញ្ញាបត្រ ធនាគារ និងហិរញ្ញវត្ថុ | ឆ្នាំចូលសិក្សា ២០១៣ |
| ជំនាន់ទី ១០ | ឆ្នាំសរសេររបាយការណ៍ ២០១៧ |

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **លី រដ្ឋា** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ឆ្នាំទី ៤ ជំនាន់ទី១០ ក្រុម B4C2 ផ្នែក ធនាគារ និង ហិរញ្ញវត្ថុ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ចិ សូមថ្លែងអំណរគុណចំពោះ ៖

លោកឪពុក និង អ្នកម្តាយដែលបានយកចិត្តទុកដាក់ខិតខំតស៊ូយ៉ាងលំបាកក្នុងការផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សាខ្ញុំអស់ពីកម្លាំងកាយចិត្ត ហើយអប់រំទូន្មានប្រៀនប្រដៅឲ្យប្រព្រឹត្តិតែអំពើល្អ។ លោកទាំងពីរបានផ្គត់ផ្គង់ទាំងសំភារៈ និងថវិកាដើម្បីផ្តល់ឪកាសឲ្យនាងខ្ញុំបានសិក្សារៀនសូត្រ រហូតដល់ខ្ញុំបានក្លាយទៅជាមនុស្សដែលមានលក្ខណៈសម្បត្តិពេញបរិបូរណ៍ដែលសង្គមសព្វថ្ងៃកំពុងត្រូវការ។

ឯកឧត្តមសាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរង លោក-លោកស្រីព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោក-លោកស្រីប្រធាន-អនុប្រធានដេប៉ាតឺម៉ង់ លោក-លោកស្រីប្រធាន-អនុប្រធានការិយាល័យ លោក-លោកស្រីសាស្រ្តាចារ្យ និងបុគ្គលិកមន្រ្តីរាជការទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ព្រមទាំងលោកគ្រូ អ្នកគ្រូទាំងអស់នៃគ្រឹះស្ថានសិក្សាទាំងអស់ដែលបានយកចិត្តទុកដាក់ ខិតខំចំណាយពេលវេលាដ៏មានតម្លៃ ដើម្បីបង្ហាត់បង្ហាញ និងផ្តល់ចំណេះដឹងដល់ខ្ញុំតាំងពីដើមរហូតដល់ថ្នាក់ឧត្តមសិក្សា។

លោកសាស្រ្តាចារ្យ **ខា សែម** ដែលលោកបានចំណាយពេលវេលា និងផ្តល់ដំបូន្មានល្អៗ ព្រមទាំងជាអ្នកដឹកនាំ ត្រួតពិនិត្យ ពន្យល់ណែនាំ និងផ្តល់ជាមតិយោបល់ ដើម្បីធ្វើការកែលម្អនូវរាល់កំហុសឆ្គងទាំងឡាយដែលមានពេលចងក្រងរបាយការណ៍កម្មសិក្សា។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត ដែលអនុញ្ញាតឲ្យខ្ញុំបានចុះកម្មសិក្សា ជាពិសេស លោក **យាន យ៉ាត** នាយកសាខាស្រុកបាភ្នំ និងព្រមទាំងបុគ្គលិកទាំងអស់ដែលបានជួយពន្យល់ណែនាំបង្ហាត់បង្រៀន និងផ្តល់ឯកសារដល់ខ្ញុំ រហូតសម្រេចបានជោគជ័យក្នុងកម្មសិក្សានេះ។

ខ្ញុំសូមឧទ្ទិសស្នាដៃ និងគុណប្រយោជន៍ដែលកើតចេញពីការសិក្សាស្រាវជ្រាវនេះ ជូនចំពោះអ្នកទាំងអស់ដែលបានរៀបរាប់ខាងលើ និងសូមជូនពរឲ្យអ្នកទាំងអស់ជួបប្រទះតែសេចក្តីសុខ សុភមង្គល និងទទួលបានជោគជ័យគ្រប់ភារកិច្ច។

## អារម្ភកថា

ប្រទេសកម្ពុជា ជាប្រទេសមួយដែលមានសង្គ្រាមរ៉ាំរ៉ៃអូសបន្លាយអស់រយៈពេលជាច្រើនឆ្នាំ ហើយ ប៉ុន្តែបន្ទាប់ពីបានក្លាយទៅជាសមាជិកនៃអង្គការធំៗមួយចំនួនដូចជា ASEAN និង WTOមក យើងសង្កេតឃើញថា សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាយើងមានការរីកចំរើនមួយកម្រិត ដោយសារតែទទួលបានការលើកលេងពន្ធលើការនាំចេញ ក៏ដូចជាកូតាលើផលិតផលមួយចំនួនទៅកាន់បរទេស ដូចជា សហគមន៍អឺរ៉ុប និងសហរដ្ឋអាមេរិចជាដើម។ កត្តាទាំងនេះហើយដែលធ្វើឲ្យបណ្តាវិនិយោគិនជាច្រើនមកធ្វើការវិនិយោគ ដែលជាឱកាសមួយសម្រាប់ប្រជាជនកម្ពុជា ព្រមទាំងវិនិយោគិនក្នុងស្រុកទាំងឡាយ ចូលរួមសកម្មក្នុងការលើកកំពស់កំរិតសេដ្ឋកិច្ចជាតិ។ យ៉ាងណាមិញ មិនត្រឹមតែវិនិយោគិនដែលនៅទីប្រជុំជនអាចស្វែងរកឱកាសនេះទេ ប្រជាជនដែលរស់នៅតាមតំបន់នានាទូទាំងប្រទេសអាចទទួលបានឱកាសអាជីវកម្មនេះបានផងដែរ តាមរយៈការធ្វើការផ្តល់កម្ចីទុនពីស្ថាប័នហិរញ្ញវត្ថុនានាក្នុងតំបន់។ ក្នុងនោះ យើងសង្កេតឃើញថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត ជាគ្រឹះស្ថានមួយដែលមានសាខា ការិយាល័យ និងប៉ុស្ត៍សេវាគ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជា បាននឹងកំពុងបម្រើសេវាកម្មជូនប្រជាពលរដ្ឋគ្រប់ផ្នែក ដែលក្នុងនោះសង្កត់ធ្ងន់ទៅលើការផ្តល់ឥណទានជូនប្រជាជននៅតាមតំបន់នីមួយៗ ដើម្បីជួយសំរួលស្ថានភាពសេដ្ឋកិច្ចរបស់ពួកគាត់។ ក្នុងនោះ ឥណទានខ្នាតតូច និងមធ្យមក៏បានបំរើដល់ការវិនិយោគ និងការពង្រីកអាជីវកម្មច្រើនប្រភេទ។ ដោយសារតែសក្តានុពល និងភាពជោគជ័យរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត ក្នុងការផ្តល់សេវាកម្មឥណទានប្រភេទនេះ ទើបខ្ញុំបានសម្រេចចិត្តធ្វើរបាយការណ៍មួយ និងបានធ្វើការចុះកម្មសិក្សាផ្ទាល់នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត ក្រោមប្រធានបទមួយស្តីពី "**ការគ្រប់គ្រងឥណទានខ្នាតតូច និងខ្នាតមធ្យម**" គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត សាខាស្រុកបាភ្នំ ដើម្បីឲ្យយល់កាន់តែច្បាស់អំពីផលិតផលឥណទានមួយប្រភេទនេះ ព្រមទាំងរៀបចំចងក្រងសៀវភៅនេះដើម្បីទុកជាឯកសារ។

ដោយសារតែបទពិសោធន៍ខ្ញុំនៅមានកម្រិត ហេតុនេះការចងក្រងឯកសារនេះរមែងតែងមានកង្វះខាត ព្រមទាំងមានកំហុសឆ្គងមួយចំនួនកើតឡើងជាក់ជាមិនខាន។ ដូចនេះខ្ញុំសូមអភ័យទោសរាល់កំហុសឆ្គង និងកង្វះខាតនានាដែលមាននៅក្នុងសៀវភៅនេះ ហើយខ្ញុំរង់ចាំទទួលនូវការកែលម្អ រិះគន់ក្នុងន័យស្ថាបនាពីសំណាក់អ្នកអានទាំងអស់ដោយក្តីសោមនស្សរីករាយ និងគុណយ៉ាងជ្រាលជ្រៅបំផុត។

# មាតិកា

*ទំព័រ*

បញ្ជីតារាង ....... vii
បញ្ជីរូបភាព ....... vii
បញ្ជីដ្យាក្រាម ....... vii

## សេចក្តីផ្តើម

១. លំនាំបញ្ហា ....... ១
២. ចំណោទបញ្ហា ....... ២
៣. គោលបំណងនៃការស្រាវជ្រាវ ....... ២
៤. សារៈសំខាន់នៃការស្រាវជ្រាវ ....... ២
៥. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ....... ៣
៦. វិធីសាស្រ្តនៃការស្រាវជ្រាវ ....... ៣
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ....... ៤

## ជំពូកទី១
## ការរំលឹកទ្រឹស្តី

១.១. លក្ខណៈទូទៅនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ....... ៦
១.១.១. ប្រវត្តិនៃការកកើតគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ....... ៦
១.១.២. និយមន័យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ....... ៨
១.១.៣. គោលបំណងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ....... ៩
១.១.៤. តួនាទីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ....... ៩
១.២. លក្ខណៈទូទៅនៃឥណទាន ....... ១០
១.២.១. និយមន័យ ....... ១០
១.២.២.សមាសភាគនៃដំណើរការឥណទាន ....... ១០
១.២.៣. មុខងារឥណទាន ....... ១១
១.២.៤.១. ឥណទានទោល (Individual loan) ....... ១២

១.២.៤.២. ឥណទានក្រុម (Group Loan) ..... ១២
១.៣. អត្ថប្រយោជន៍ឥណទាន ..... ១២
១.៣.១. អត្ថប្រយោជន៍ចំពោះអ្នកប្រើប្រាស់ ..... ១២
១.៣.២. អត្ថប្រយោជន៍ចំពោះអាជីវកម្ម ..... ១៣
១.៣.៣. អត្ថប្រយោជន៍ចំពោះសេដ្ឋកិច្ច ..... ១៤
១.៤. គ្រោះថ្នាក់នៃការប្រើប្រាស់ឥណទានខុសគោលដៅ ..... ១៤
១.៤.១. គ្រោះថ្នាក់ក្នុងការប្រើប្រាស់ឥណទានសម្រាប់អ្នកប្រើប្រាស់ ..... ១៤
១.៤.២. គ្រោះថ្នាក់ក្នុងការប្រើប្រាស់ឥណទានសម្រាប់អាជីវកម្ម ..... ១៤
១.៤.៣. ភាពចាំបាច់សម្រាប់ការអប់រំ ..... ១៥
១.៥. លក្ខណៈទូទៅនៃនីតិវិធីក្នុងការផ្តល់ឥណទាន ..... ១៥
១.៥.១. និយមន័យ ..... ១៥
១.៥.២. នីតិវិធីនៃការផ្តល់ឥណទាន ..... ១៥
១.៥.៣. គោលការណ៍នៃការផ្តល់ឥណទាន ..... ១៧
១.៥.៣.១. គោលការណ៍ឲ្យខ្ចីមានគោលដៅ និងផែនការ ..... ១៧
១.៥.៣.២. គោលការណ៍ឲ្យខ្ចីដោយសងវិញទាំងដើមទាំងការ ..... ១៧
១.៥.៣.៣. គោលការណ៍ឲ្យខ្ចីដោយមានការធានា ..... ១៨
១.៥.៣.៤. គោលការណ៍នៃការប្រមូលប្រាក់បំណុល ..... ១៩
១.៥.៣.៥. គោលការណ៍ផាកពិន័យចំពោះការសងបំណុលយឺត និងការខកខានមិនបានសង ..... ១៩
១.៥.៤. ការវាយតម្លៃឥណទាន ..... ១៩
១.៥.៤.១. ចរិកលក្ខណៈ ..... ២០
១.៥.៤.២. សមត្ថភាព ..... ២០
១.៦. វិធីសាស្ត្រសងរំលស់នៃឥណទាន ..... ២០
១.៦.១. បំណុលដែលសងតែម្តងគត់នៅកាលអវសាន (Pure Discount Loan) ..... ២០

១.៦.២. បំណុលដែលសងតែការប្រាក់ (Interest-Only Loan) ..................................... ២១
១.៦.៣. បំណុលសងរំលស់ ..................................... ២១
១.៧. ការគ្រប់គ្រងហានិភ័យឥណទាន ..................................... ២១
១.៧.១. និយមន័យ ..................................... ២១
១.៧.២. មូលហេតុដែលបណ្ដាលឲ្យមានហានិភ័យ..................................... ២២
១.៧.២.១. មូលហេតុបណ្ដាលមកពីអតិថិជន ..................................... ២២
១.៧.២.២. មូលហេតុបណ្ដាលមកពីធនាគារ..................................... ២២
១.៧.២.៣. មូលហេតុដែលបណ្ដាលមកពីសេដ្ឋកិច្ច សង្គម និងគ្រោះធម្មជាតិ ..................................... ២២
១.៧.៣. ផលប៉ះពាល់ដែលបណ្ដាលឲ្យមានហានិភ័យឥណទាន..................................... ២៣
១.៧.៤. យុទ្ធសាស្ត្រក្នុងការកាត់បន្ថយហានិភ័យឥណទាន..................................... ២៣
១.៨. វិធីសាស្ត្រគិតការប្រាក់..................................... ២៤
១.៨.១. និយមន័យ..................................... ២៤
១.៨.២. ការប្រាក់ធម្មតា (Simple Interest)..................................... ២៤
១.៨.៣. ការប្រាក់ផ្គួប (Compound Interest ) ..................................... ២៥
១.៩. វិធីសាស្ត្រដោះស្រាយឥណទានមានបញ្ហា ..................................... ២៦
១.១០. តួនាទីឥណទានក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ..................................... ២៧

## ជំពូកទី ២

## ស្ថានភាពទូទៅរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត

២.១. ប្រវត្តិរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត..................................... ២៨
២.២. ប្រវត្តិរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹតសាខាស្រុកបាភ្នំ ..................................... ៣១
២.៣.១. រូបសញ្ញា..................................... ៣១
២.៣.២. អត្ថន័យនៃរូបសញ្ញា ..................................... ៣២
២.៤. ទីតាំងរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត ..................................... ៣៣
២.៤.១. ទីតាំងសាខាទូទាំង២៤ខេត្ត-ក្រុង..................................... ៣៣

២.៤.២. ទីតាំងរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត សាខាស្រុកបាភ្នំ .................................... ៣៤
២.៥. ភាគទុនិក ដើមទុន និងប្រភពហិរញ្ញវត្ថុ .................................... ៣៥
២.៥.១. ភាគហ៊ុនិក ដើមទុន .................................... ៣៥
២.៥.២.ប្រភពហិរញ្ញវត្ថុ .................................... ៣៦
២.៦. រចនាសម្ព័ន្ធគ្រប់គ្រងរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត សាខាស្រុកបាភ្នំ .................................... ៣៧
២.៧. ទស្សនៈវិស័យ បេសកកម្ម និងវប្បធម៌រួម .................................... ៣៨
២.៧.១. ទស្សនៈវិស័យ .................................... ៣៨
២.៧.២. បេសកកម្ម .................................... ៣៨
២.៧.៣. វប្បធម៌រួម .................................... ៣៨
២.៨. ផលិតផល និងសេវាកម្មទូទៅរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត .................................... ៣៨

## ជំពូកទី ៣

## ការគ្រប់គ្រងឥណទានខ្នាតតូច និងខ្នាតមធ្យមរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត

៣.១. ទីផ្សារគោលដៅសម្រាប់ឥណទានខ្នាតតូច និងខ្នាតមធ្យម .................................... ៤០
៣.២. ឥណទានខ្នាតតូច និងខ្នាតមធ្យម .................................... ៤០
៣.២.១. ផលិតផលឥណទានខ្នាតតូច .................................... ៤០
៣.២.១.១. ទំហំឥណទាន .................................... ៤០
៣.២.១.២. ការកំណត់ថ្លៃ .................................... ៤១
៣.២.២. ផលិតផលឥណទានខ្នាតមធ្យម .................................... ៤២
៣.២.២.១. ទំហំឥណទាន .................................... ៤២
៣.២.២.២. ការកំណត់ថ្លៃ .................................... ៤២
៣.២.៣. ការផ្លាស់ប្តូរអត្រាការប្រាក់លើឥណទាន .................................... ៤៣
៣.៣. ការកំណត់ទំហំឥណទាន និងថ្លៃសេវា .................................... ៤៣
៣.៣.១. ការកំណត់ទំហំឥណទាន .................................... ៤៣

៣.៣.២. ថ្លៃសេវា ............................................................................................................................ ៤៣
៣.៤. ការគ្រប់គ្រងឥណទានខ្នាតតូច និងមធ្យម .................................................................................. ៤៣
៣.៤.១. ការវាយតម្លៃក្នុងការផ្តល់ឥណទាន ......................................................................................... ៤៣
៣.៤.១.១. អត្តចរិតរបស់អតិថិជន...................................................................................................... ៤៣
៣.៤.១.២. ដើមទុន........................................................................................................................... ៤៤
៣.៤.១.៣. សមត្ថភាពសង.................................................................................................................. ៤៤
៣.៤.១.៤. ទ្រព្យធានា....................................................................................................................... ៤៤
៣.៤.១.៥. លក្ខខណ្ឌ ........................................................................................................................ ៤៤
៣.៤.២. នីតិវិធីក្នុងការផ្តល់ឥណទាន .................................................................................................. ៤៤
៣.៤.២.១. ការដាក់ពាក្យសុំចុះឈ្មោះខ្ចីប្រាក់...................................................................................... ៤៤
៣.៤.២.២. ការចុះទៅពិនិត្យដល់ផ្ទះអតិថិជន និងការវាយតម្លៃឥណទាន............................................. ៤៥
៣.៤.២.៣. ការរៀបចំឯកសារខ្ចីប្រាក់.................................................................................................. ៤៥
៣.៤.២.៤. ការអនុមតឥណទាន ......................................................................................................... ៤៥
៣.៤.២.៥. ការរៀបចំកិច្ចសន្យា ......................................................................................................... ៤៦
៣.៤.២.៦. ការបញ្ចេញឥណទាន......................................................................................................... ៤៦
៣.៤.៣. លក្ខខណ្ឌក្នុងការផ្តល់ឥណទាន............................................................................................... ៤៦
៣.៤.៤. ការសងត្រលប់មកវិញនៃឥណទាន ......................................................................................... ៤៧
៣.៤.៤.១. ការគណនាការប្រាក់ ......................................................................................................... ៤៧
៣.៤.៤.២. របៀបសងប្រាក់................................................................................................................ ៤៨
៣.៤.៤.៣. ការសងត្រឡប់មកវិញនៃឥណទាន..................................................................................... ៥២
៣.៤.៤.៤. ការធ្វើតារាងកាលវិភាគសងប្រាក់ឡើងវិញ ......................................................................... ៥៣
៣.៤.៤.៥. ការផ្តល់ឥណទានបន្ថែម..................................................................................................... ៥៣
៣.៤.៥. ការខកខានសង និងការពិន័យ................................................................................................ ៥៣
៣.៤.៥.១. ការខកខានសង................................................................................................................ ៥៣

៣.៤.៥.២. ការពិន័យ ........................................................................................................ ៥៤
៣.៤.៦. ការធ្វើចំណាត់ថ្នាក់ឥណទាន និងសំវិធានធន ........................................................ ៥៤
៣.៤.៦.១. ការធ្វើចំណាត់ថ្នាក់ឥណទាន ........................................................................ ៥៤
៣.៤.៦.២. ការធ្វើសំវិធានធន ...................................................................................... ៥៥
៣.៤.៧. ហានិភ័យឥណទាន ............................................................................................ ៥៦
៣.៤.៧.១ និយមន័យហានិភ័យឥណទាន .......................................................................... ៥៦
៣.៤.៧.២. មូលហេតុនៃហានិភ័យឥណទាន ...................................................................... ៥៦
៣.៤.៧.៣. វិធីសាស្រ្តកាត់បន្ថយហានិភ័យឥណទាន ........................................................... ៥៨
៣.៤.៧.៤. វិធីសាស្រ្តដោះស្រាយបំណុលមានបញ្ហា ............................................................ ៥៩
៣.៤.៧.៥. ការវាស់វែងអត្រាហានិភ័យឥណទាន ................................................................ ៦០
៣.៥. លទ្ធផលឥណទាននៃការស្រាវជ្រាវ ........................................................................... ៦១
៣.៥.១. សមតុល្យឥណទានសរុបរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត សាខាស្រុកបាភ្នំ ចាប់ពីឆ្នាំ ២០១៤ ដល់ ២០១៦ ........................................................................................................ ៦១
៣.៥.២. ទំហំឥណទានដែលបានលុបចេញពីបញ្ជី ................................................................ ៦២
៣.៦. ការវិភាគ SWOT ................................................................................................. ៦៣
៣.៦.១. ចំណុចខ្លាំង ........................................................................................................ ៦៣
៣.៦.២. ចំណុចខ្សោយ ...................................................................................................... ៦៤
៣.៦.៣. ឱកាស ................................................................................................................ ៦៤
៣.៦.៤. ការគំរាមគំហែង ................................................................................................... ៦៤

## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

១. សេចក្តីសន្និដ្ឋាន ........................................................................................................ ៦៦
២. ការផ្តល់អនុសាសន៍ ....................................................................................................... ៦៦

## ឯកសារយោង

## ឧបសម្ព័ន្ធ

## បញ្ជីតារាង


– តារាងភាគហ៊ុនិក ដើមទុន ............................................................................ ៣៥
– តារាងប្រភពហិរញ្ញវត្ថុ.................................................................................... ៣៦
– តារាងបង់រំលស់ការប្រាក់ និងប្រាក់ដើមរំលស់រៀងរាល់ខែ........................................ ៤៩
– តារាងបង់រំលស់ដើមថេរ.................................................................................. ៥០
– តារាងបង់រំលស់បតបែន.................................................................................. ៥២
– តារាងបង្ហាញពីបម្រែបម្រួលនៃទំហំឥណទានដែលបានបញ្ចេញគិតជាប្រាក់រៀល ពីឆ្នាំ ២០១៤-២០១៦............................................................................................... ៦១
– តារាងអត្រាឥណទាន និងបុរេប្រទានដែលខាតបង់ពីឆ្នាំ ២០១៤-២០១៦..................... ៦៣


## បញ្ជីរូបភាព


– រូបសញ្ញារបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត ........................................................ ៣១
– ទីតាំងសាខាទូទាំង ២៥ខេត្ត-ក្រុងរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត ....................... ៣៣
– ទីតាំងរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត សាខាស្រុកបាភ្នំ......................................... ៣៤


## បញ្ជីដ្យាក្រាម


– ដ្យាក្រាមបង្ហាញពីបម្រែបម្រួលនៃទំហំឥណទានដែលបានបញ្ចេញ ............................... ៦២

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

របបសង្គមរាស្ត្រនិយម គឺជាសម័យកាលមួយដែលប្រទេសកម្ពុជាយើងរីកចម្រើនលើគ្រប់វិស័យ ប៉ុន្តែបន្ទាប់ពីមានការធ្វើរដ្ឋប្រហារ និងឆ្លងកាត់របបមួយដ៏ខ្មៅងងឹតនោះគឺ របបកម្ពុជាប្រជាធិបតេយ្យ និងបានធ្វើឲ្យហេដ្ឋារចនាសម្ព័ន្ធរបស់ប្រទេសទាំងមូលត្រូវខ្ទេចខ្ទីគ្មានសល់ មិនតែប៉ុណ្ណោះបន្ទាប់ពីរបបអាក្រក់មួយនេះបានកន្លងផុតទៅ កម្ពុជានៅមានសង្គ្រាមផ្ទៃក្នុងអូសបន្លាយអស់រយៈ ពេលជាច្រើនឆ្នាំទៀត។ បន្ទាប់ពីមានវត្តមានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសមក បានប្រែក្លាយមុខមាត់កម្ពុជាលើឆាកអន្តរជាតិ ដោយកម្ពុជាបានប្តូរពីទម្រង់សេដ្ឋកិច្ចផែនការ ទៅជាសេដ្ឋកិច្ចទីផ្សារសេរីវិញ។ ក្នុងដំណើរឆ្ពោះទៅរកកិច្ចអភិវឌ្ឍន៍ប្រទេសជាតិរបស់ខ្លួន កម្ពុជាមើលឃើញថាវិស័យសេដ្ឋកិច្ច ជាវិស័យមួយដែលត្រូវដើរតួនាទីយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍន៍ប្រទេសជាតិដែលក្នុងនោះវិស័យនេះបានទាក់ទាញអ្នកវិនិយោគពីគ្រប់ទិសទី។ កត្តានេះបានជំរុញឲ្យមានកំណើននៃតម្រូវការផ្នែកហិរញ្ញវត្ថុ។

ដោយតម្រូវការលើផ្នែកធនធានហិរញ្ញវត្ថុចេះតែមានកំណើនខ្លាំង រួមផ្សំជាមួយនឹងស្ថេរភាពនយោបាយល្អ បានធ្វើឲ្យវិស័យហិរញ្ញវត្ថុនៅប្រទេសកម្ពុជាមានការរីកចម្រើនយ៉ាងឆាប់រហ័ស នៅប៉ុន្មានឆ្នាំចុងក្រោយនេះ។ គ្រឹះស្ថានហិរញ្ញវត្ថុនៅកម្ពុជារួមមាន ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាច្រើនបាននឹងកំពុងកកើត និងរីកដុះដាលជារៀងរាល់ថ្ងៃដូចផ្សិត ក្នុងនោះរួមមាន ធនាគារពាណិជ្ជចំនួន៣៧ ធនាគារឯកទេសចំនួន ១៣ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ៥៤ ដែលក្នុងនោះមានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុធំៗចំនួន ៧ ត្រូវបានផ្តល់អាជ្ញាប័ណ្ណអនុញ្ញាតឲ្យទទួលប្រាក់បញ្ញើពីសាធារណៈជន និងមានការិយាល័យតំណាងធនាគារពីបរទេសចំនួន ៦ ។ ក្នុងចំណោមនោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មានតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់មូលធន ឬសេវាឥណទាន សម្រាប់ឲ្យប្រជាពលរដ្ឋយកទៅធ្វើជាដើមទុន ដើម្បីប្រកបអាជីវកម្មចិញ្ចឹមជីវិត និងពង្រីកមុខរបរឲ្យកាន់តែរីកលូតលាស់ថែមមួយកម្រិតទៀត ទៅតាមអ្វីដែលអតិថិជនចង់បាន។ ដើម្បីឲ្យអតិថិជនមានការយល់ច្បាស់នោះខាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក៏បានតម្រូវឲ្យបុគ្គលិកចុះធ្វើការផ្សព្វផ្សាយ ដើម្បីឲ្យប្រជាពលរដ្ឋយល់ដឹងពីសេវាកម្មរបស់ស្ថាប័ន និងចេះប្រើប្រាស់សេវាកម្មឥណទាន។ ហេតុដូច្នេះហើយបានជាស្ថាប័ននីមួយៗ ខិតខំប្រឹងប្រែងបញ្ចេញនូវលទ្ធភាពរបស់ខ្លួនក្នុងការទាក់ទាញអតិថិជន ឲ្យទទួលបាននូវសេវាកម្មពីស្ថាប័នរបស់យើង។

ការផ្តល់ឥណទាន គឺជាសេវាកម្មហិរញ្ញវត្ថុ ដែលសំខាន់បំផុតក្នុងការបង្កើតប្រាក់ចំណូលដល់ស្ថាប័នជាពិសេសទៅលើទីផ្សារប្រកួតប្រជែងដែលមាននៅក្នុងប្រទេសកម្ពុជា។ ដូចនេះបានជា

នាពេលបច្ចុប្បន្នគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត ខិតខំប្រឹងប្រែងផ្តល់ឥណទាន យ៉ាងសកម្មដល់អតិថិជន មិនតែប៉ុណ្ណោះគ្រឹះស្ថានបានយកចិត្តទុកដាក់ដល់អតិថិជន និងពង្រឹងដល់សមត្ថភាពបុគ្គលិក ឲ្យកាន់តែល្អថែមទៀតដើម្បីឲ្យអតិថិជនមានការពេញចិត្តលើគ្រឹះស្ថានរបស់ខ្លួន។

## ២. ចំណោទបញ្ហា

យើងដឹងហើយថា ឥណទានមានសារៈសំខាន់ ហើយបច្ចុប្បន្ននេះ យើងឃើញថាតម្រូវការលើសេវាឥណទានមានតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ឥណទានសម្រាប់ ការវិនិយោគ និងការបង្កើតរបរអាជីវកម្មឲ្យទាន់ពេលវេលា។ ដូចនេះហើយ នាងខ្ញុំជ្រើសរើសការចុះកម្មសិក្សាស្រាវជ្រាវលើប្រធានបទខាងលើដើម្បីធ្វើការសិក្សានិង ស្វែងយល់អំពីៈ

- តើគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត មានគោលការណ៍យ៉ាងដូចម្តេចខ្លះចំពោះការផ្តល់ឥណ-ទានសហគ្រាសខ្នាតតូច និងខ្នាតមធ្យម ដល់អតិថិជន?
- តើនីតិវិធីអ្វីខ្លះដែលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត យកមកប្រើក្នុងការផ្តល់ ឥណទានដល់អតិថិជនរបស់ខ្លួន?
- តើការផ្តល់ឥណទានសហគ្រាសខ្នាតតូច និងខ្នាតមធ្យម ដល់អតិថិជនមាន ប៉ុន្មានដំណាក់កាល?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការគ្រប់គ្រងឥណទានខ្នាតតូច និងខ្នាតមធ្យមផ្តោតសំខាន់ជារួម ក្នុងនោះមានគោលបំណងជាក់លាក់មួយចំនួនដូចខាងក្រោមៈ

- សិក្សាពីស្ថានភាពទូទៅរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត
- សិក្សាពីគោលការណ៍ និងនីតិវិធីនៃការផ្តល់ឥណទានខ្នាតតូច និងខ្នាតមធ្យម
- សិក្សាពីការត្រួតពិនិត្យ និងតាមដានឥណទាន
- សិក្សាពីការខកខានមិនសង និងការផាកពិន័យ
- សិក្សាពីវិធីសាស្ត្រក្នុងការដោះស្រាយឥណទានមានបញ្ហា
- សិក្សាពីប្រសិទ្ធិភាព និងចំណុចខ្វះខាតនៃការផ្តល់ឥណទាន
- រកឲ្យឃើញពីចំណុចខ្លាំង និងចំណុចខ្សោយនៃការគ្រប់គ្រងឥណទានខ្នាតតូច និងខ្នាតមធ្យមរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត សាខាស្រុកបាភ្នំ
- ធ្វើការសន្និដ្ឋាន និងផ្តល់អនុសាសន៍ក្នុងការកែលម្អការគ្រប់គ្រងឲ្យមានប្រសិទ្ធិភាពខ្ពស់

## ៤. សារៈសំខាន់នៃការស្រាវជ្រាវ

របាយការណ៍ស្រាវជ្រាវនេះវានឹងផ្តល់សារៈប្រយោជន៍ដូចជាៈ

- ទទួលបាននូវចំនេះដឹង និងបទពិសោធន៍ទាក់ទងនឹងការអនុវត្តជាក់ស្តែងនៃការផ្តល់ឥណទានខ្នាតតូច និងខ្នាតមធ្យម ដែលបង្ហាញឲ្យឃើញច្បាស់ពីភាពដូចគ្នា និងភាពខុសគ្នារវាងទ្រឹស្តី និងការអនុវត្តជាក់ស្តែង។
- ផ្តល់បទពិសោធន៍ក្នុងការគ្រប់គ្រងឥណទានប្រកបដោយប្រសិទ្ធិភាពខ្ពស់។
- បង្កើនចំណេះដឹងផ្ទាល់ខ្លួនក្នុងការផ្តល់ឥណទាន ការគ្រប់គ្រងហានិភ័យឥណទាន និងក្បួនក្នុងការសម្រេចចិត្តផ្តល់ឥណទានជូនវិនិយោគិន ក៏ដូចជាសាធារណៈជនទូទៅ។
- ផ្តល់ជាឯកសារសម្រាប់អ្នកសិក្សា ក៏ដូចអ្នកស្រាវជ្រាវជំនាន់ក្រោយៗដែលមានបំណងចង់ស្វែងយល់ពីបញ្ហានេះ។
- អាចបង្ហាញផ្លូវដល់អ្នក ដែលមានបំណងចង់ទទួលបានឥណទាននេះ ក្នុងការរៀបចំខ្លួនមុននឹងទទួលបានឥណទាន។

## ៥. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត សាខាស្រុកបាភ្នំ មានផលិតផល និង សេវាកម្មហិរញ្ញវត្ថុជាច្រើន។ ដោយឡែកការសិក្សាស្រាវជ្រាវ គឺផ្តោតសំខាន់ទៅលើតែការគ្រប់គ្រងឥណទានខ្នាតតូច និងខ្នាតមធ្យម ដែលប្រព្រឹត្តិទៅនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត សាខាស្រុកបាភ្នំ តាមរយៈការចុះកម្មសិក្សារយៈពេលមួយខែ គឺចាប់ពីថ្ងៃទី ២៤ ខែមេសា ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៧។ ចំពោះការសិក្សាស្រាវជ្រាវនេះមិនបានធ្វើការប្រៀបធៀប គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត ជាមួយស្ថាប័នមីក្រូហិរញ្ញវត្ថុដទៃទៀតទេ គឺនាងខ្ញុំសិក្សាស្រាវជ្រាវ និងធ្វើការវិភាគទិន្នន័យក្នុងឆ្នាំ ២០១៤-២០១៦ ដែលផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ "អម្រឹតសាខាស្រុកបាភ្នំ" សម្រាប់ការសិក្សាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រឆ្នាំ ២០១៧ តែប៉ុណ្ណោះ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះអាចប្រព្រឹត្តទៅបាន គឺអាស្រ័យលើទិន្នន័យពីរប្រភពផ្សេងៗដូចជា៖

- ទិន្នន័យចម្បង៖ ដោយបានចុះកម្មសិក្សាដោយផ្ទាល់នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត សាខាស្រុកបាភ្នំ ហើយបានស្រាវជ្រាវ និងធ្វើការសាកសួរដោយផ្ទាល់ជាមួយមន្ត្រីឥណទានដែលកំពុងបម្រើការនៅទីនោះ ជាពិសេសមន្ត្រីទទួលបន្ទុកផ្នែកភ្នាក់ងារឥណទានរួមផ្សំជាមួយ និងការចុះទៅផ្ទាល់ជាមួយមន្ត្រីឥណទាន។
- ទិន្នន័យបន្ទាប់បន្សំ៖ គឺជាការប្រមូលបានមកពីឯកសារនានា និងផ្សារភ្ជាប់ទៅលើទ្រឹស្តីដើម្បីសិក្សាស្រាវជ្រាវ អំពីប្រធានបទដែលរួមមានដូចខាងក្រោម៖
    - ទទួលការប្រឹក្សាយោបល់ពីលោកសាស្ត្រាចារ្យណែនាំ

- ឯកសារពាក់ព័ន្ធផ្សេងៗ ដែលផ្តល់ដោយមន្ត្រីផ្នែកឥណទាន នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត សាខាស្រុកបាភ្នំ។
- ដកស្រង់ចេញពីឯកសារ ដែលធ្លាប់បានរៀនកន្លងមកទាក់ទង ជាមួយសាស្ត្រាចារ្យនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។
- ឯកសារសារណារបស់និស្សិតជំនាន់មុន និងចុះស្រាវជ្រាវតាមបណ្ណាល័យ
- តាមរយៈគេហទំព័រផ្សេងៗ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាទៅលើប្រធានបទនេះ គឺផ្តោតសំខាន់ទៅលើការគ្រប់គ្រងឥណទានខ្នាតមធ្យម ហើយការរៀបចំរបាយការណ៍នេះឡើងគឺ មានបីជំពូក ដែលជំពូកនីមួយៗមានខ្លឹមសារដូចខាងក្រោម៖

- សេចក្តីផ្តើម
- ជំពូកទី១ រំលឹកទ្រឹស្តី
- ជំពូកទី២ ស្ថានភាពទូទៅរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត
- ជំពូកទី៣ ការគ្រប់គ្រងឥណទានខ្នាតតូច និង ខ្នាតមធ្យមរបស់ គ្រឹះស្ថានមីក្រូ-ហិរញ្ញវត្ថុអម្រឹត សាខាស្រុកបាភ្នំ
- សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## គំរោងនៃការស្រាវជ្រាវ



# ជំពូកទី១

# ការសិក្សាលើផ្នែកទ្រឹស្តី

## ១.១. លក្ខណៈទូទៅនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

### ១.១.១. ប្រវត្តិនៃការកកើតគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជា

[1]ចាប់តាំងពីឆ្នាំ ១៩៧៩ ក្រោយពីប្រទេសកម្ពុជាបានបញ្ចប់សង្គ្រាមដ៏វិនាសកម្មក្រោយការគ្រប់គ្រងផ្តាច់ការក្នុងរបប ប៉ុល ពត ដែលមានរយៈពេលរហូតដល់ទៅបីឆ្នាំប្រាំបីខែម្ភៃថ្ងៃនោះមកធ្វើឲ្យប្រទេសជាតិ ធ្លាក់ដល់ចំណុចសូន្យដោយគ្មាន បន្សល់ទុកនូវអ្វីទាំងអស់រាប់ចាប់តាំងពីហេដ្ឋា-រចនាសម្ព័ន្ធគ្រប់បែបយ៉ាង វិស័យសេដ្ឋកិច្ច វិស័យទូរគមនាគមន៍ វិស័យធនាគារ និងវិស័យផ្សេងទៀត។ ជាពិសេសទៀតនោះ គឺធនធានមនុស្សនេះតែម្តងគឺបានរលាយអស់ស្ទើរទាំងស្រុង។ ទើបតែក្រោយថ្ងៃរំដោះឆ្នាំ១៩៧៩មក ទើបប្រទេសជាតិបានចាប់ផ្តើមងើបឡើងបន្តិចម្តងៗ និងវិស័យផ្សេងៗក៏មានដំណើរការជាហូរហែឡើងរាប់ទាំងវិស័យធនាគារ និងហិរញ្ញវត្ថុផងដែរ។ ហើយបើនិយាយពីវិស័យមីក្រូហិរញ្ញវត្ថុវិញ គឺបានចាប់ផ្តើមមកកើតជាថ្មីឡើងវិញ អំឡុងទសវត្ស ឆ្នាំ១៩៩០ ដែលប្រតិបត្តិការមីក្រូហិរញ្ញវត្ថុនៅពេលនោះ គឺស្ថិតនៅក្រោមសកម្មភាពជាលក្ខណៈអង្គការក្រៅរដ្ឋាភិ-បាលតែប៉ុណ្ណោះ។ ការកកើតឡើងវិញរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅ ទសវត្សនោះ គឺដើម្បីបំពេញបន្ថែមការខ្វះចន្លោះរបស់ធនាគារ ជាពិសេសធនាគារពាណិជ្ជដែលមិនមាន សេវាឥណទានទៅដល់ទីជនបទដាច់ស្រយាល ដែលនៅទសវត្សនោះ គឺធនាគារបានស្រូបយកអតិថិជនបានត្រឹមតែ ២០% នៃប្រជាពលរដ្ឋសរុបក្នុងទូទាំងប្រទេសតែប៉ុណ្ណោះ ហើយប្រជាពលរដ្ឋទាំងនោះ គឺភាគច្រើនជាអ្នកដែលមានសេដ្ឋកិច្ចគ្រួសារប្រសើរ និងធូរធារមធ្យមផងដែរ ហើយអ្នកទាំងនោះគឺភាគច្រើនរស់នៅទីប្រជុំជន និងទីក្រុង។ ដូច្នេះក្រៅពីនោះ គឺប្រជាពលរដ្ឋមិនមានឱកាសក្នុងការទទួលបានប្រាក់កម្ចីឥណទានពីធនាគារ ដែលយកការប្រាក់ទាបសមរម្យនោះទេ។ កត្តាមួយទៀតនោះ គឺដើម្បីជួយសម្រួលដល់ប្រជាពលរដ្ឋឲ្យបានខ្ចីប្រាក់ ដែលមានអត្រាការប្រាក់ទាប សមរម្យជាងឈ្មួញចងការប្រាក់នៅតាមភូមិស្រុករបស់ពួកគាត់ តាមរយៈការខ្ចីប្រាក់ឥណទានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ នៅពេលដែលប្រជាពលរដ្ឋចង់ខ្ចីប្រាក់ ដើម្បីយកទៅប្រកបមុខរបរផ្សេងៗ ឬពង្រីកមុខរបរ ឬធ្វើអ្វីមួយនៅមុនទសវត្សឆ្នាំ១៩៧៩ ដល់១៩៩០ ពួកគាត់ គឺមានតែម្យ៉ាងគត់គឺទៅរកខ្ចីប្រាក់ពីឈ្មួញចងការប្រាក់ដែលរស់នៅតាមភូមិ ស្រុក របស់គាត់ដែលនៅទីនោះ ទោះបីអត្រាការប្រាក់ ដែលឈ្មួញចងការប្រាក់ទាំងនោះបានយកការប្រាក់ខ្ពស់ គឺខ្ពស់រហូតដល់ទៅ១០% ឬ២០% ក្នុងមួយខែៗ

[1]http://www.amret.com.kh/amret/index.php/km/2012-08-06-03-28-30/2012-10-01-06-35-24

ក៏ដោយ ក៏ពួកគាត់នៅតែខ្ចីប្រាក់ដែរ។ មួយវិញទៀតនោះមានអ្នកខ្ចីខ្លះ បាននិយាយផងដែរថាការប្រាក់ ១០% ឬ ២០% ក្នុងមួយខែៗគឺមិនថ្លៃទេសម្រាប់គាត់។ ដោយសារតែពួកគាត់គ្មានអ្នកឲ្យខ្ចីប្រាក់ណាផ្សេងទៀត ដើម្បីយកមកប្រៀបធៀបឡើយ ក្រៅតែពីឈ្មួញចងការប្រាក់នៅភូមិ ស្រុករបស់ពួកគាត់។ កត្តាទាំងនេះហើយធ្វើឲ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បានចាប់ផ្តើមដើរតួនាទីឡើងវិញក្នុងនាមជាប្រតិបត្តិករក្នុងការចូល ទៅបំពេញនូវចន្លោះខ្វះខាតទាំងនេះ ដើម្បីឲ្យប្រជាពលរដ្ឋ ដែលភាគច្រើនជាស្ត្រីឲ្យមានឱកាសក្នុងការខ្ចីប្រាក់ យកទៅចាប់ផ្តើមមុខរបរ ឬ ពង្រីកមុខរបរដែលមានស្រាប់ឲ្យកាន់តែប្រសើរឡើងតាមរយៈកម្ចីប្រាក់ឥណទាន ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ សកម្មភាពទាំងនេះ គឺ បញ្ជាក់ឲ្យឃើញថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុពិតជាបានដើរតួនាទី យ៉ាងសំខាន់ និងយ៉ាងសកម្ម និងមានប្រសិទ្ធិភាពខ្ពស់ក្នុងការជួយស្តារ និងធ្វើការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកម្ពុជា ឲ្យកាន់តែប្រសើរឡើងថែមទៀត ស្របទៅនឹងចក្ខុវិស័យរបស់រដ្ឋាភិបាលកម្ពុជា ដែលកំពុងបើកទូលាយ នូវគោលនយោបាយសេដ្ឋកិច្ចទីផ្សារសេរីទាំងក្នុងប្រទេស ក្នុងតំបន់ និងទាំងនៅលើឆាកអន្តរជាតិផងដែរ។ ជាមួយនេះផងដែរ រាជរដ្ឋាភិបាលដែលមានសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជាប្រមុខនៃរាជរដ្ឋាភិបាលកម្ពុជា បានកំណត់ និងប្រកាស ឆ្នាំ២០០៦ គឺជាឆ្នាំមីក្រូហិរញ្ញ-វត្ថុនៅកម្ពុជា។[2] ការចេញអាជ្ញាប័ណ្ណរបស់ធនាគារជាតិនៃកម្ពុជា ដល់គ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងបណ្តាឆ្នាំអំឡុងទសវត្ស ១៩៩៨-២០០០ វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជាមានការរីកដុះដាល និងបានក្លាយជា វិស័យមួយដែលមានសក្តានុពលហើយមានការរីកចម្រើនយ៉ាងខ្លាំងក្លាបើធ្វើការប្រៀបធៀបទៅនឹងបណ្តាប្រទេស នៅក្នុងតំបន់អាស៊ីអាគ្នេយ៍យើងនេះ។ ទន្ទឹមនឹងការ វិវត្តន៍យ៉ាងខ្លាំងនេះហើយទើបធនាគារជាតិនៃកម្ពុជា ដែលជាអាណាព្យាបាលលើគ្រឹះស្ថានធនាគារ ក៏ដូចជាមីក្រូហិរញ្ញវត្ថុបានចេញច្បាប់មួយស្តីពីគ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុក្នុងការផ្តល់អាជ្ញាប័ណ្ណជូនគ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុដែលជាប្រតិបត្តិករ។ ការចេញអាជ្ញាប័ណ្ណនេះ គឺក្នុងគោលបំណង ដើម្បីធានានិរន្តភាពរបស់គ្រឹះស្ថានទាំងនោះឲ្យដំណើរការទៅដោយរលូន និងស្របច្បាប់ ដែលបានកំណត់ដោយធនាគារជាតិនៃកម្ពុជាដែលជាអាណាព្យាបាល។ ច្បាប់នេះរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៩៩ នាសម័យប្រជុំពេញអង្គលើក ទី៣ នីតិ-កាលទី២។ ក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថា ស្របតាមធម្មនុញ្ញកាលពីថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលមានសេចក្តីទាំងស្រុង ស្តីពីច្បាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ហើយច្បាប់នោះត្រង់ជំពូក៥

[2] Sector highlight: Cambodia Microfinance: Development and Challenges by by Mr. Kim Vada, Deputy Director General for National Bank of Cambodia, on March 15-17, 2010 at Dhaka, Bangladesh

មាត្រា១៤ គឺបានបញ្ជាក់យ៉ាងច្បាស់ ស្ដីពីការចេញអាជ្ញាប័ណ្ណជូនគ្រឹះស្ថានធនាគារ និង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (សេចក្ដីលម្អិតមានក្នុងច្បាប់របស់ធនាគារជាតិនៃកម្ពុជា)[3]។

នៅត្រឹមឆ្នាំ២០១៦ គឺគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន៥៨ ដែលទទួលបានអាជ្ញាប័ណ្ណស្របច្បាប់ពីធនាគារជាតិនៃកម្ពុជាក្នុងការប្រកបអាជីវកម្មរបស់ខ្លួន។ ហើយក្នុងចំណោមគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំង៥៨ នោះគឺមានតែគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ៧ ទេ ដែលទទួលអាជ្ញាប័ណ្ណប្រកបអាជីវកម្មទទួលប្រាក់បញ្ញើពីសាធារណៈជន។[4]

### ១.១.២. និយមន័យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

មុននឹងឲ្យនិយមន័យ «អ្វីទៅជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ» យើងត្រូវតែយល់ន័យនៃពាក្យមីក្រូហិរញ្ញវត្ថុជាមុនសិន។

និយមន័យនៃពាក្យថា មីក្រូហិរញ្ញវត្ថុ អាចមានភាពខុសគ្នាពីប្រទេសមួយទៅប្រទេសមួយតាមបទដ្ឋានគតិយុត្តិនៃប្រទេសនោះ។

មីក្រូហិរញ្ញវត្ថុ (មីក្រូ = តូចបំផុត , ហិរញ្ញវត្ថុ = ការគ្រប់គ្រងហិរញ្ញវត្ថុ) សកម្មភាពផ្ដល់សេវាឥណទាន ឬទទួលប្រាក់សន្សំដែលមានទំហំតូចតាច[5]។

មីក្រូហិរញ្ញវត្ថុ មានន័យថាការផ្ដល់សេវាហិរញ្ញវត្ថុដូចជា ការផ្ដល់ឥណទាន និងទទួលប្រាក់បញ្ញើចំពោះគ្រួសារដែលមានចំណូលតិច និងសហគ្រាសខ្នាតតូច[6]។ មួយផ្សេងទៀតមីក្រូហិរញ្ញវត្ថុមានន័យថា ជាការផ្ដល់នូវបណ្ដាសេវាហិរញ្ញវត្ថុទាំងឡាយដូចជា សេវាប្រាក់បញ្ញើ កម្ចី សេវាទូទាត់ ផ្ទេរប្រាក់ ដល់ប្រជាពលរដ្ឋក្រីក្រ និងក្រុមគ្រួសារដែលមានចំនូលទាប (Low-Income households) ហើយព្រមទាំងមីក្រូសហគ្រាស(Microenterprises) ផងដែរ។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គឺជាគ្រឹះស្ថានដែលផ្ដល់នូវបណ្ដាសេវាហិរញ្ញវត្ថុ ទាំងឡាយដូចជាសេវាប្រាក់បញ្ញើ កម្ចី សេវាទូទាត់ ផ្ទេរប្រាក់ ដល់ប្រជាពលរដ្ឋក្រីក្រ និងក្រុមគ្រួសារដែលមានចំណូលទាប ហើយព្រមទាំងមីក្រូសហគ្រាសផងដែរ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គឺជាគ្រឹះស្ថានមួយដែលបានចុះបញ្ជីជាក្រុមហ៊ុន ហើយអាចធ្វើពាណិជ្ជកម្ម បានលុះត្រាទទួលបាន អាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ជាមួយនឹងដើមទុនអតិបរមាក្នុងលក្ខន្តិកកំណត់មួយ។ ម្យ៉ាងទៀត វាជាស្ថាប័នហិរញ្ញវត្ថុសម្រាប់ប្រជាជនក្រីក្រ មានន័យថាចំនួនទឹកប្រាក់ដែលឲ្យខ្ចីមានទំហំតូច ហើយវា

[3]www.nbc.org.kh/legislation/law_on_banking_and_financial_institution.php,ច្បាប់ស្ដីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ
[4]http://www.nbc.org.kh/economic_research/mfis_reports.php
[5]ហ៊ីង ថូរ៉ាក់ស៊ី និង ហ៊ាន សាហ៊ីប, «វចនានុក្រមបច្ចេកស័ព្ទសេដ្ឋកិច្ច» , ទំព័រ ៤៨៨
[6]ធនាគារជាតិនៃកម្ពុជា, ២០០៨, «ច្បាប់ក្រុមអនុវត្តចំពោះធនាគារ និង ហិរញ្ញវត្ថុ», ទំព័រ ៥៥១

ក៏ជាយន្តការមិនអាចខ្វះបាន ក្នុងការជួយជម្រុញកំណើន សេដ្ឋកិច្ចគ្រួសារ និងសេដ្ឋកិច្ចជាតិដោយធ្វើឲ្យប្រភពធនធានដែលនៅក្នុងដៃបុគ្គលនីមួយៗ មានវត្តមាននៅលើទីផ្សារ។ ដូច្នេះហើយ បើគ្មានស្ថាប័នហិរញ្ញវត្ថុទេ ដំណើរការនៃប្រព័ន្ធហិរញ្ញវត្ថុពិតជាជួបនូវបញ្ហាជាមិនខាន។

### ១.១.៣. គោលបំណងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

គោលបំណងរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គឺរៀបចំនូវសេចក្តីត្រូវការខាងហិរញ្ញវត្ថុ ដល់ពលរដ្ឋក្រីក្រ និងកាត់បន្ថយនូវអត្រាការប្រាក់ខ្ពស់នៅលើទីផ្សារ ដោយយកឥណទានរបស់ស្ថាប័នហិរញ្ញវត្ថុទៅជំនួសនូវការខ្ចីបំណុលផ្សេងៗ។

ដោយពិនិត្យឃើញថា ឥណទានជាយន្តការយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍន៍ជនបទ ដែលមានតួនាទីជួយបង្កើន និងពង្រីកនូវមុខរបរ ព្រមទាំងបង្កើតនូវផលិតភាពការងារ និងប្រាក់ចំណូល ដែលធ្វើឲ្យជីវភាពរបស់ប្រជាជនបានល្អប្រសើរឡើង ដែលជាផ្នែកមួយរួមចំណែកយ៉ាងសំខាន់ និងសកម្មបំផុតក្នុងការកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍ជនបទថែមទៀត។

### ១.១.៤. តួនាទីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានដើរតួនាទីយ៉ាងសំខាន់ក្នុងការស្តារ និងការអភិវឌ្ឍន៍ជនបទតាមរយៈការផ្តល់សេវាឥណទាន ដែលធ្វើឲ្យមានលំហូរសាច់ប្រាក់ ក្នុងចរន្តសេដ្ឋកិច្ចបង្កើតឲ្យមានសកម្មភាពសេដ្ឋកិច្ចផ្សេងៗទៀតយ៉ាងសម្បូរបែប។ ខាងក្រោមនេះ គឺបង្ហាញពីសារៈសំខាន់ និងតួនាទីឥណទាន៖

- ផ្តល់ទុនដល់កសិករសម្រាប់ទិញឧបករណ៍ និងមធ្យោបាយកសិកម្ម
- បង្កើតឲ្យមាននិកម្មភាព (Employment) ដើម្បីកសាងសេដ្ឋកិច្ចគ្រួសារនិងសង្គមជាតិ
- ផ្តល់ឥណទានឲ្យកសិករដើម្បីរក្សានូវផលិតផលកសិកម្មរបស់ខ្លួន និងអាចលក់នៅពេលណាដែលមានតម្លៃសមរម្យ។
- ផ្តល់នូវធនធានហិរញ្ញវត្ថុសម្រាប់បង្កើត ពង្រីក និងកែលំអរមុខរបរឲ្យបានប្រសើរ
- ផ្តល់ការហ្វឹកហ្វឺនវិជ្ជាជីវៈ លើវិស័យកសិកម្ម ដើម្បីឲ្យកសិករចេះរៀបចំគម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ចបានត្រឹមត្រូវស្របនឹងកម្មវិធីនៃការប្រើប្រាស់ឥណទាន។
- ផ្តល់ព័ត៌មាន និងវិធីសាស្ត្រផ្សេងៗដូចជា វិធីសាស្ត្រគ្រប់គ្រងមុខរបរ វិធីសាស្ត្រផលិតទំនិញ និងការជួញដូរលើទីផ្សារ។
- កាត់បន្ថយការប្រើប្រាស់ឥណទាន ដែលមានការប្រាក់ខ្ពស់ហួសហេតុពីបណ្តាឈ្មួញនានា

- បង្កើតការងារជូនប្រជាពលរដ្ឋតាមគ្រប់មធ្យោបាយ ដែលមានស្រាប់នៅនឹងកន្លែង ដើម្បីកាត់បន្ថយការធ្វើចំណាកស្រុកភូមិ ដើម្បីស្វែងរកការងារធ្វើនៅតាមទីក្រុង ទីប្រជុំជន និងតាមបណ្តាប្រទេសផ្សេងៗទៀត។
- បង្កើតផលិតផលក្នុងស្រុកសរុប និងសេវាកម្មដើម្បីបន្តការកែច្នៃ និងបែងចែកផលិតផលកសិកម្មឲ្យមានភាពរីកចម្រើនជាងមុន។
- ដើម្បីចូលរួមអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ដោយជម្រុញឲ្យមានការវិនិយោគកម្រិតតូច និង មធ្យមដើម្បីបង្កើតឲ្យមានផលិតផល និងសេវាកម្មផ្សេងៗគ្នា ក្នុងគោលបំណងដើម្បីបម្រើឲ្យវិស័យសេដ្ឋកិច្ច ក្នុងគ្រួសារ និងសង្គមជាតិទាំងមូល។
- ពង្រឹងសាមគ្គីភាព និងការអនុវត្តច្បាប់បានល្អក្នុងចំណោមសមាជិកសហាគមន៍។

## ១.២. លក្ខណៈទូទៅនៃឥណទាន

### ១.២.១. និយមន័យ

[7]ឥណទាន គឺជាការផ្ទេរកម្មសិទ្ធិ ឬប្រើប្រាស់ជាបណ្តោះអាសន្នទៅឲ្យអ្នកខ្ចីនូវបរិមាណតម្លៃមួយអាចជាវត្ថុ រឺ ជារូបិយវត្ថុ (លុយ) ជាមួយនឹងការសន្យានឹងសងត្រលប់ទៅឲ្យម្ចាស់ដើមវិញនូវបរិមាណមួយធំជាងមុន។

[8]ឥណទានមានន័យថា ជាទឹកប្រាក់ដែលធនាគារ ឬស្ថាប័នហិរញ្ញវត្ថុឲ្យអតិថិជនខ្ចី។ ឬមានន័យថា ជាការទទួលមូលធន ឬសាច់ប្រាក់សមមូលដែលត្រូវទទួល ដោយផ្អែកទៅលើកិច្ចព្រមព្រៀងរវាងធនាគារ និងភាគីដទៃដែលតម្រូវឲ្យអ្នកខ្ចីប្រាក់ទូទាត់សងបំណុលគេបន្ទាប់ពីមានលក្ខខណ្ឌជាក់លាក់រួមជាមួយ អត្រាការប្រាក់។

### ១.២.២.សមាសភាគនៃដំណើរការឥណទាន[9]

មានកត្តាជាច្រើន គួរសម្រេចដោយម្ចាស់បំណុល មុននឹងទទួលយកការសន្យារបស់អ្នកស្នើសុំដើម្បីសងបំណុលដោយប្រើឥណទានជំនួសសាច់ប្រាក់សុទ្ធ។ ក្នុងនោះគឺមានតែប្រតិបត្តិការឥណទានមួយគត់ ដែលអាចកំណត់ភារកិច្ចនេះបានហើយមានការពាក់ព័ន្ធ និងការទទួលខុសត្រូវពីមន្ត្រីឥណទាន។ សមាសភាគនៃដំណើរការឥណទានមានដូចជា៖

- ហានិភ័យ
- ពេលវេលា

---

[7] អេង កែវពិសិដ្ឋ " *ការគ្រប់គ្រងឥណទាន"*(២០១២), ទំព័រ ៣

[8] ហ៊ីង ថូរ៉ាក់ស៊ី និងហ៊ាន សាហ៊ីប, (២០០៤), " *វចនានុក្រមបច្ចេកសព្ទសេដ្ឋកិច្ច".* ទំព័រ ១៧០-១៧១

[9] Robert Cole & Lon Mishler " *Consumer and Business Credit Management"*(1998), 11thEdition, Page 5-6

- ការធានា រឺវត្ថុបញ្ចាំ
- ការឯកភាពតាមច្បាប់
- ចំណាយលើប្រតិបត្តិការ
- អតិថរណា
- បន្ទុកហិរញ្ញវត្ថុ

**១.២.៣. មុខងារឥណទាន**

ការផ្តល់កម្ចីដល់សាធារណៈជន មានមុខងារប្លែកៗពីគ្នាទៅតាមប្រភេទនៃកម្ចី ឬតម្រូវការរបស់អតិថិជន។ ខាងក្រោមនេះជាមុខងាររួមរបស់ឥណទាន៖

- ផ្តល់មូលនិធិឲ្យអ្នកខ្ចី ដើម្បីពង្រីកមុខជំនួញ ឬអាជីវកម្ម និងបង្កើតកម្រិតជីវភាពតាមចំណូលអនាគតដែលសង្ឃឹមទុក។
- ធ្វើឲ្យធនាគារទទួលប្រាក់ចំណេញតាមរយៈ ការប្រើប្រាស់ប្រភពមូលធនហិរញ្ញវត្ថុរបស់ខ្លួន និងការបង្កើតទ្រព្យសម្បត្តិភាពទុនិកដោយសារតែការកើនឡើងនូវប្រាក់ចំណេញ។
- ទ្រទ្រង់ការអភិវឌ្ឍន៍សេដ្ឋកិច្ច តាមរយៈការប្រមូលផ្តុំមូលធន និងដាក់ឲ្យមានការចរាចរក្នុងផ្នែកផលិតកម្មដល់សង្គមតាមរយៈការបង្កើតនូវទ្រព្យសម្បត្តិ បង្កើតការងារ និងជម្រុញឲ្យមាននិរន្តភាពអាជីវកម្ម ដើម្បីស្រូបយកផលប្រយោជន៍ពីប្រភពធនធានធម្មជាតិរបស់ប្រទេសខ្លួន។
- ផ្តល់មូលធនឲ្យអ្នកប្រើប្រាស់សម្រាប់ទិញ លក់ទំនិញ ឬសេវាកម្ម។
- ផ្តល់ទុនដល់អាជីវករ សម្រាប់ទិញឧបករណ៍ និងមធ្យោបាយអាជីវកម្មរបស់ខ្លួន។
- កាត់បន្ថយការរកស៊ីចងការ ដែលមានការប្រាក់ខ្ពស់ហួសហេតុ។
- បង្កើតប្រសិទ្ធិភាពនៃការប្រើប្រាស់ឥណទានតាមគ្រួសារ។
- ផ្លាស់ប្តូរផ្នត់គំនិតក្នុងការទទួលខុសត្រូវ និងការប្រឹងប្រែងសម្រាប់ជោគវាសនារបស់ខ្លួន។
- បង្កើតផលិតផលក្នុងស្រុកតាមរយៈការផ្តល់សេវាឥណទាន។

### ១.២.៤. ប្រភេទឥណទាន[10]

ប្រតិបត្តិការឥណទានកើតឡើងនៅក្នុងទម្រង់ច្រើនផ្សេងៗពីគ្នា។ ការធ្វើចំណាត់ថ្នាក់នៃប្រភេទឥណទានគឺអាស្រ័យលើគោលបំណងនៃការប្រើប្រាស់ឥណទាន និងវិធីសាស្ត្រក្នុងការសងត្រលប់មកវិញ។ ឥណទាននៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុត្រូវបានគេបែងចែកជាពីរប្រភេទគឺ ឥណទានទោល(Individual loan) និងឥណទានក្រុម(Group loan)។

#### ១.២.៤.១. ឥណទានទោល ( Individual loan )

ឥណទានទោល (Individual loan) គឺជាការផ្តល់ឥណទានជូនអតិថិជនជាឯកត្តជន ដោយតម្រូវឲ្យមានទ្រព្យសម្បត្តិដាក់ធានា ដើម្បីការពារនៅពេលមានការខកខានមិនបានសងបំណុល។ ឥណទានប្រភេទនេះ គឺផ្តល់សម្រាប់មុខជំនួញខ្នាតតូច និង មធ្យម។

#### ១.២.៤.២. ឥណទានក្រុម ( Group Loan )

ឥណទានក្រុម គឺជាឥណទានសម្រាប់ផ្តល់ជូនប្រជាកសិករក្រីក្រ ដែលមានមុខជំនាញ ឬកសិកម្មតូចតាច ដោយមិនតម្រូវឲ្យដាក់ទ្រព្យសម្បត្តិធានាទេ (តែគ្រឹះស្ថានខ្លះតម្រូវឲ្យមានទ្រព្យធានា) ប៉ុន្តែអតិថិជនត្រូវបានចងគ្នាជាក្រុមពី បីទៅដប់នាក់។ ការចងគ្នាជាក្រុមបែបនេះ គឺសម្រាប់ឲ្យសមាជិកក្នុងក្រុម ធានាគ្នាទៅវិញទៅមក និងត្រូវចេញសងជូសគ្នា ប្រសិនបើសមាជិកណាម្នាក់ខកខានមិនបានសង។

## ១.៣. អត្ថប្រយោជន៍ឥណទាន[11]

### ១.៣.១. អត្ថប្រយោជន៍ចំពោះអ្នកប្រើប្រាស់

#### ក. ធ្វើឲ្យកើនឡើងនូវកម្រិតជីវភាពរស់នៅ

ជាទូទៅអ្នកប្រើប្រាស់ទទួលបានអត្ថប្រយោជន៍ពីការប្រើប្រាស់ឥណទាន ពីព្រោះពួកគេអាចប្រើចំណូលនៅពេលអនាគតរបស់ពួកគេ ដើម្បីធ្វើការទូទាត់លើទំនិញ និងសេវាដែលពួកគេមានតម្រូវការ។ ដូច្នេះពួកគេអាចបង្កើតកម្រិតជីវភាពនៃការរស់នៅរបស់ពួកគេនាពេលបច្ចុប្បន្ន។ ឧទាហរណ៍៖ គូស្វាមីភរិយាទើបតែរៀបការថ្មីៗមួយគូ អាចធ្វើការបញ្ជាទិញគ្រឿងសង្ហារឹម ដើម្បីរៀបចំតុបតែងផ្ទះរបស់ពួកគេ។ មួយវិញទៀត និស្សិតអាចទទួលបានកម្ចីដើម្បីបន្តការសិក្សានៅមហាវិទ្យាល័យ ដោយប្រើចំណូលរបស់ពួកគេនាពេលអនាគតសងត្រលប់ទៅម្ចាស់បំណុលវិញ។

[10] ម៉ៃ សុខដេដ្ឋា, ២០០៥, " ស្ថាប័នមីក្រូហិរញ្ញវត្ថុកម្ពុជា", ទំព័រ ៤២

[11] Robert Cole & Lon Mishler " *Consumer and Business Credit Management*"(1998), 11thEdition, Page 11-14

**ខ. ដោះស្រាយពេលមានអាសន្ន**

អ្នកប្រើប្រាស់ តែងតែត្រូវការប្រើប្រាស់ឥណទានជាចាំបាច់ នៅពេលដែលពួកគេជួបនូវភាពអាសន្ន ឬ វិបត្តិផ្សេងៗ ដូចជា បញ្ហាជួសជុលរថយន្ត បញ្ហាចូលមន្ទីរពេទ្យ និងគ្រោះថ្នាក់ដែលកើតឡើងមានតម្រូវការចំណាយបន្ទាន់។ កម្មវិធីឥណទាន ផ្តល់ជូនអ្នកប្រើប្រាស់នូវមធ្យោបាយសម្រាប់ចំណាយលើភាពអាសន្នទាំងអស់នោះ។

**គ. បង្កលក្ខណៈងាយស្រួល**

ឥណទានអាចបង្កលក្ខណៈងាយស្រួលផងដែរ ដល់អ្នកប្រើប្រាស់។ អ្នកប្រើប្រាស់អាចធ្វើដំណើរជុំវិញពិភពលោកដោយប្រើប័ណ្ណឥណទាន សម្រាប់ធ្វើការទូទាត់ថ្លៃប្រេង ថ្លៃឧស្ម័ន ថ្លៃសណ្ឋាគារ សំបុត្រយន្តហោះ និងវត្ថុអនុស្សាវរីយ៍ជាដើម។ ដូចនេះ តម្រូវការសាច់ប្រាក់ចំនួនច្រើនត្រូវបានកាត់បន្ថយ។ អ្នកធ្វើដំណើរមិនចាំបាច់មានលុយតាមខ្លួនក៏បានដែរ ប្រសិនបើប័ណ្ណឥណទានរបស់ពួកគេអាចប្រើប្រាស់បានគ្រប់គោលបំណងទាំងអស់។

**១.៣.២. អត្ថប្រយោជន៍ចំពោះអាជីវកម្ម**

**ក. ជួយពង្រីកទីផ្សារ**

អាជីវកម្មជាច្រើនពឹងផ្អែកទៅលើឥណទាន ដើម្បីពង្រីកទីផ្សារ និងស្វែងរកអ្នកប្រើប្រាស់របស់ពួកគេ។ ប្រសិនបើពួកគេផ្តល់ឱកាសសម្រាប់អតិថិជនរបស់ពួកគេ នោះនឹងមានមនុស្សជាច្រើនអាចចូលរួមទិញបាន។ អតិថិជនជាច្រើនខ្វះនូវសាច់ប្រាក់ដើម្បីចំណាយ ឬក៏ពួកគេចង់ជ្រើសរើសយកជម្រើសប្រើប្រាស់ឥណទាន ដែលពួកគេអាចសងត្រលប់វិញនាពេលក្រោយ។

**ខ. ទទួលបានការផ្គត់ផ្គង់សន្និធិ និងសម្ភារៈសម្រាប់លក់**

អាជីវកម្មមួយចំនួនធំ គឺបានពឹងផ្អែកលើកម្មវិធីឥណទានដែលផ្តល់ដោយអ្នកផ្គត់ផ្គង់របស់ពួកគេ ដើម្បីទទួលបានការផ្គត់ផ្គង់សន្និធិ និងតម្រូវការសម្ភារៈផ្សេងៗ ដើម្បីបំពេញប្រតិបត្តិការអាជីវកម្មរបស់ពួកគេ។ អាជីវកម្មអាចពង្រីកការផលិត និងសន្និធិទំនិញយ៉ាងច្រើន ប្រសិនបើពួកគេអាចទទួលបានការទិញដោយប្រើឥណទាន។

**គ. ការទទួលបានមូលនិធិហិរញ្ញវត្ថុ**

អាជីវកម្មជាច្រើនតែងតែមានតម្រូវការដើមទុនសម្រាប់ចាប់ផ្តើម ថែរក្សា និងពង្រីកនូវប្រតិបត្តិការរបស់ពួកគេរៀងៗខ្លួន។ ក្រុមហ៊ុន ឬសហគ្រាសជាច្រើនមានបទពិសោធន៍ លំហូរសាច់ប្រាក់មិនដូចគ្នាទេ ដែលការចំណាយគឺត្រូវឲ្យមានមូលនិធិ (សាច់ប្រាក់) មុនការកើតមានការលក់ផលិតផល និងសេវា ដូចជាការចំណាយទៅលើទីតាំងថ្មី បុគ្គលិកថ្មី និងការចំណាយលើផ្នែកទីផ្សារផ្សេងៗទៀត ដែលនឹងមិនអាចដំណើរការទៅបានទេ ប្រសិនបើគ្មានការផ្តល់កម្ចីអាជីវកម្ម។

### ១.៣.៣. អត្ថប្រយោជន៍ចំពោះសេដ្ឋកិច្ច

ក្នុងន័យនេះ ឥណទានគឺជាប្រេងរំអិលសម្រាប់ក្បាលម៉ាស៊ីនសេដ្ឋកិច្ច។ ឥណទានបង្កើតបានជាចលនាសាច់ប្រាក់ និងជាផ្នែកនៃផលិតកម្មនៅក្នុងការជម្រុញកំណើនសេដ្ឋកិច្ច។ ឥណទានតែងតែផ្តល់មធ្យោបាយ ដើម្បីសេរីភាពដល់កម្រិតសកម្មភាពសេដ្ឋកិច្ច ដោយធ្វើការកំណត់កម្រិតបន្ទុកហិរញ្ញវត្ថុ (អត្រាការប្រាក់) ខុសៗគ្នា។

តួនាទីរបស់ឥណទានមានសារៈសំខាន់ជាពិសេសនៅក្នុង គោលនយោបាយរូបិយវត្ថុ និង គោលនយោបាយសារពើពន្ធ ដែលមានឥទ្ធិពលលើការចំណាយ និងធ្វើការត្រួតពិនិត្យអត្រាការប្រាក់។ ជាទូទៅយើងហៅថា ឥទ្ធិពលម៉ាក្រូសេដ្ឋកិច្ច។

## ១.៤. គ្រោះថ្នាក់នៃការប្រើប្រាស់ឥណទានខុសគោលដៅ[12]

នៅក្នុងភាពជាក់ស្តែង ឥណទានអាចមានផលអាក្រក់នៅពេលដែលយើងប្រើប្រាស់វាមិនបានត្រឹមត្រូវ ហើយវាក៏បានចោទជាបញ្ហាជាច្រើនសម្រាប់អាជីវកម្ម អ្នកប្រើប្រាស់ និងសហគមន៍ទាំងមូលផងដែរ។ ភាគីអ្នកប្រើប្រាស់ឥណទានទាំងអស់ត្រូវដឹងថា ឥណទានដែលកំពុងប្រើ គឺសម្រាប់តែគោលបំណងផលិតភាពតែប៉ុណ្ណោះ និងត្រូវចេះបង្កើតការប្រុងប្រយ័ត្នជាមួយនឹងស្មារតីយកចិត្តទុកដាក់ខ្ពស់។

### ១.៤.១. គ្រោះថ្នាក់ក្នុងការប្រើប្រាស់ឥណទានសម្រាប់អ្នកប្រើប្រាស់

អ្នកប្រើប្រាស់អាចប្រើប្រាស់ឥណទានមិនពេញលក្ខណៈ និងទទួលមកវិញនូវបទពិសោធន៍មិនល្អ។ ដោយការប្រើឥណទានមិនបានល្អធ្វើឲ្យអ្នកប្រើប្រាស់មួយចំនួនមានបញ្ហា ជាយថាហេតុបានធ្វើឲ្យបាត់បង់លទ្ធភាពទូទាត់បំណុល។ ឥណទានវាជាអន្ទាក់មួយសម្រាប់អ្នកប្រើប្រាស់ដែលធ្វេសប្រហែស ហើយលទ្ធផលចុងក្រោយ និងឈានដល់បាត់បង់ទ្រព្យសម្បត្តិ ការក្ស័យធន មហន្ត-រាយចំណាងអាពាហ៍ពិពាហ៍ និងមានកម្រិតគុណភាពឥណទានទាប។ ទន្ទឹមនឹងនោះការដែលជាប់សន្យាជាច្រើននៃចំណូលអនាគតជាមួយឥណទាន ធ្វើឲ្យគេបាត់បង់ឱកាសសន្សំដែលជាគោលដៅយ៉ាងសំខាន់។

### ១.៤.២. គ្រោះថ្នាក់ក្នុងការប្រើប្រាស់ឥណទានសម្រាប់អាជីវកម្ម

ជំនួញគួរប្រុងប្រយ័ត្ននៅពេលប្រើ និងការបន្តប្រើឥណទាន។ នៅពេលដែលមានអតិថិជនមួយចំនួនបានទិញទំនិញ និងសេវាកម្ម ដោយប្រើឥណទាន ហើយមិនសងតាមកិច្ចព្រមព្រៀងនោះអាជីវកម្មនឹងបាត់បង់ចំណូលច្រើន។ បញ្ហានេះគឺ ភាគច្រើនកើតចំពោះអាជីវកម្មខ្នាតតូច ហើយមូល

[12] អេង កែវពិសិដ្ឋ "*ការគ្រប់គ្រងឥណទាន*"(២០១២), ទំព័រ ៣២-៣៥

ហេតុចំបងមួយក្នុងចំណោម មូលហេតុសំខាន់ គឺដោយសារសមត្ថភាពក្នុងការគ្រប់គ្រងនយោបាយឥណទានមិនបានល្អ។

ដូចនេះ អាជីវកម្មត្រូវប្រាកដថាអតិថិជនល្អទើបមានឱកាសប្រើប្រាស់កម្មវិធីឥណទាន។ ផ្នែកប្រមូលក៏ជាកត្តាមួយសំខាន់ផងដែរ ត្រូវធ្វើយ៉ាងណាឲ្យមានលំហូរសាច់ប្រាក់ជាវិជ្ជមានពីដំណើរការឥណទាន។ ចំណាយថ្លៃដើម និងការប្រមូលឥណទានត្រូវត្រួតពិនិត្យឲ្យបានច្បាស់ដើម្បីកុំឲ្យបាត់បង់ចំណូល។

### ១.៤.៣. ភាពចាំបាច់សម្រាប់ការអប់រំ

យើងត្រូវយល់ច្បាស់លាស់ថា ទាំងអ្នកផ្គត់ផ្គង់ និងអ្នកប្រើប្រាស់ត្រូវតែប្រុងប្រយ័ត្ន ពីព្រោះថាឥណទាន ជាផ្នែកមួយដ៏សំខាន់នៅក្នុងមធ្យោបាយដោះដូរ ក៏ដូចជាផ្នែកមួយយ៉ាងសខាន់នៃសេដ្ឋកិច្ច។

ដូចនេះ ការអប់រំដល់អ្នកប្រើប្រាស់គួរពាក់ព័ន្ធការបណ្តុះបណ្តាលស្តីអំពីថវិកាពីលក្ខខណ្ឌនៃកិច្ចសន្យា និងការស្ម័គ្រចិត្តសងលើកិច្ចសន្យាដែលបានព្រមព្រៀង។ សម្រាប់អាជីវកម្មត្រូវយល់ដឹងពីនយោបាយឥណទានដែលអាចសម្រេចបានថា តើគួរធ្វើការស៊ើបអង្កេតអ្នកស្នើសុំយ៉ាងដូចម្តេច? និង តើនយោបាយប្រមូលបែបណាដែលគួរជ្រើសយក?

## ១.៥. លក្ខណៈទូទៅនៃនីតិវិធីក្នុងការផ្តល់ឥណទាន

### ១.៥.១. និយមន័យ[13]

គោលបំណងនៃការផ្តល់ឥណទាន គឺធ្វើយ៉ាងណាឲ្យកម្ចីនោះទទួលបានប្រាក់ចំណេញ និងមានហានិភ័យទាបបំផុត។ ដូចនេះ គេទាមទារឲ្យមន្ត្រីទទួលបន្ទុកផ្នែកឥណទានទាំងអស់ត្រូវមានទេពកោសល្យ សមត្ថភាព និងជំនាញច្បាស់លាស់ក្នុងប្រតិបត្តិការងាររបស់ខ្លួន ដើម្បីទទួលបានភាពជោគជ័យនៅក្នុងអាជីពរបស់ខ្លួនផងដែរ។

### ១.៥.២. នីតិវិធីនៃការផ្តល់ឥណទាន[14]

នីតិវិធីក្នុងការផ្តល់ឥណទានមានដូចខាងក្រោម៖

-ដំណាក់កាលទី១៖ ទទួលពាក្យស្នើសុំខ្ចីឥណទាន។ នៅក្នុងដំណាក់កាលនេះ មន្ត្រីឥណទានត្រូវពិនិត្យមើល ពីលក្ខខណ្ឌទាមទារមួយចំនួន ដែលបានកំណត់ដោយច្បាប់ និងគោលនយោបាយឥណទានរបស់ធនាគារ។ ប្រសិនបើសំណើនេះប៉ះពាល់ដល់លក្ខខណ្ឌទាមទារណាមួយ មន្ត្រីឥណទាននឹងបដិសេធសំណើសុំខ្ចីនោះ។

---

[13] នុន សិរីមាលា និងសុខ ថានីន "*ការផ្តល់ឥណទានខ្នាតតូចបំផុត និងខ្នាតតូច*"ឆ្នាំ ២០១១, ទំព័រ២១

[14] Milland Sathye, "*Credit Analysis & Lending Management*",(2003),Page 21-24

-ដំណាក់កាលទី២៖ ទទួលឯកសារទាមទារ ឬ របាយការណ៍ហិរញ្ញវត្ថុ

– ចំពោះឥណទានប្រើប្រាស់ផ្ទាល់ខ្លួន៖ ឯកសារទាមទាររួមមាន ប័ណ្ណបើកបរ រថយន្តរបាយការណ៍ចំណូល (ប្រាក់ខែ) ភស្តុតាងដែលបង្ហាញពីប្រភពចំណូលផ្សេងទៀត របាយការណ៍លម្អិតពីការចំណាយ និងរបាយការណ៍លម្អិតពីទ្រព្យសកម្មផ្សេងទៀត។

– ចំពោះឥណទានអាជីវកម្ម៖ ត្រូវតែផ្តល់ឯកសារស្តីពីការផ្តល់សិទ្ធិអំណាច (Document of Constitution) ។ មានន័យថា អ្នកខ្ចីត្រូវតែជាម្ចាស់ក្រុមហ៊ុន ឬអ្នកតំណាងឲ្យក្រុមហ៊ុន ដែលទទួលសិទ្ធិអំណាច (ជាលាយលក្ខអក្សរអំពីក្រុមប្រឹក្សាភិបាល) និងឯកសារទាមទារមួយចំនួន ទៀតដូចជា តារាងតុល្យការ របាយការណ៍ចំណូលចំណាយ និងរបាយការណ៍លំហូរសាច់ប្រាក់ ដែលឯកសារទាំងនេះមានរយៈពេល បី ទៅ ប្រាំឆ្នាំ។ ឯកសារទាំងនេះ នឹងត្រូវយកទៅវិភាគដោយ មន្ត្រីឥណទាន។

- ដំណាក់កាលទី៣៖ ត្រួតពិនិត្យពាក្យស្នើសុំឥណទាន និងឯកសារ ឬរបាយការណ៍ហិរញ្ញវត្ថុ ឡើងវិញ។ បើមន្ត្រីឥណទានយល់ថានៅខ្វះព័ត៌មានមួយចំនួនទៀត ត្រូវប្រាប់ទៅអ្នកខ្ចីឲ្យយក ឯកសារបន្ថែមទៀតបាន។

- ដំណាក់កាលទី៤៖ នៅពេលព័ត៌មានត្រូវបានទទួល និងស្ថិតនៅក្នុងលំដាប់លំដោយ នោះ ការសម្រេចចិត្តថាត្រូវផ្តល់ ឬបដិសេធសំណើសុំខ្ចីឥណទានសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួនត្រូវបាន បង្កើតឡើង។ ក្នុងករណីឥណទានអាជីវកម្ម ត្រូវបន្តទៅដំណាក់កាលបន្តបន្ទាប់ទៀត ដែលសំខាន់ ជាងគេ គឺការចុះទៅពិនិត្យដល់ទីកន្លែងអាជីវកម្មអ្នកខ្ចី។

- ដំណាក់កាលទី៥៖ វាយតម្លៃលម្អិតពីបច្ចេកទេស និងចំនេះដឹងក្នុងការគ្រប់គ្រង ចាត់ចែង អាជីវកម្មនិងធនធានហិរញ្ញវត្ថុរបស់អ្នកខ្ចី។

- ដំណាក់កាលទី៦៖ វាយតម្លៃពីតម្រូវការហិរញ្ញវត្ថុរបស់អ្នកខ្ចី មានន័យថា មន្ត្រីឥណទានធ្វើ ការវាយតម្លៃពីទំហំទឹកប្រាក់ ដែលអ្នកខ្ចីបានស្នើសុំធៀបនឹងទំហំអាជីវកម្មរបស់អ្នកខ្ចី ថាតើទំហំ អាជីវកម្មសមស្របទៅនឹងទឹកប្រាក់ ដែលអ្នកខ្ចីបានស្នើសុំខ្ចីដែរឬទេ? និង មើលថាតើ អាជីវកម្មនឹង អាចរកចំណូលបានគ្រប់គ្រាន់ដើម្បីសងវិញឬទេ?

- ដំណាក់កាលទី៧៖ ករណីដំណើរការត្រូវបានយល់ព្រម ត្រូវផ្តល់ព័ត៌មានទៅអ្នកខ្ចីឲ្យមក កាន់ធនាគារដើម្បីចុះហត្ថលេខាលើឯកសារដែលពាក់ព័ន្ធ។ បើសំណើរត្រូវបានបដិសេធ ក៏ត្រូវផ្តល់ ព័ត៌មានទៅឲ្យអ្នកខ្ចីវិញដែរ ដោយបញ្ជាក់ពីមូលហេតុឲ្យបានច្បាស់លាស់។

- ដំណាក់កាលទី៨៖ ត្រូវតែច្បាស់ថា វត្ថុធានា និងឯកសារផ្សេងៗត្រូវចុះហត្ថលេខាយ៉ាង ត្រឹមត្រូវមុនពេលផ្តល់ប្រាក់កម្ចីដល់អ្នកខ្ចី។ដំណាក់កាលនេះ មន្ត្រីឥណទានត្រូវត្រួតពិនិត្យមើល

ឡើងវិញនូវវត្ថុធានា (ដើម្បីច្បាស់ថា វាពិតជាកម្មសិទ្ធិរបស់អ្នកខ្ចី) កិច្ចសន្យាដាក់វត្ថុធានា កិច្ចសន្យាខ្ចីប្រាក់ និងឯកសារសំខាន់ៗផ្សេងៗទៀតដែលពាក់ព័ន្ធ ដើម្បីសុវត្ថិភាព។

- ដំណាក់កាលទី៩៖ ពិនិត្យមើលគណនីជាប្រចាំ។ នៅក្នុងករណី ឥណទានតម្រូវឲ្យអ្នកខ្ចីផ្តល់របាយការណ៍ហិរញ្ញវត្ថុជាប្រចាំ មន្ត្រីឥណទានត្រូវត្រួតពិនិត្យមើលអតិថិជនបានផ្តល់ឯកសារទាំងនេះទៀងទាត់ ឬទេ?

- ដំណាក់កាលទី១០៖ បើការពិនិត្យគណនីរបស់អ្នកខ្ចីមានចំណុចមួយចំនួនដែលធនាគារមិនពេញចិត្តត្រូវតែចាត់វិធានការណ៍ជាបន្ទាន់ ដើម្បីកុំឲ្យឥណទានមានបញ្ហា។

ការអនុវត្តន៍នីតិវិធីទាំង ១០ ដំណាក់កាលនោះ អាចធានាយ៉ាងច្បាស់ថា គ្មានចំណុចណាមួយភ្លេចភ្លាំងឡើយនៅក្នុងដំណើរការនៃការផ្តល់ឥណទាន។

**១.៥.៣. គោលការណ៍នៃការផ្តល់ឥណទាន**[15]

ដោយឥណទានទាក់ទងនឹងការខ្ចីបុល ដោយការសងត្រលប់ទៅវិញទាំងដើមទាំងការតាមការកំណត់ ដូចនេះ គេត្រូវមានគោលការណ៍ដើម្បីធានាសុវត្ថិភាពទុន និងទ្រព្យធនរបស់អ្នកឲ្យខ្ចី។ គេចែកគោលការណ៍ឥណទានជា ៥ ផ្នែកដូចខាងក្រោម៖

**១.៥.៣.១. គោលការណ៍ឲ្យខ្ចីមានគោលដៅ និងផែនការ**

តាមគោលការណ៍នេះ អង្គភាពអាជីវកម្មទាំងអស់ ឬ ផ្នែកឯកជននៅក្នុងវិស័យសេដ្ឋកិច្ចចង់ខ្ចីប្រាក់ពីធនាគារ ឬ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដាច់ខាតត្រូវធ្វើពាក្យសុំខ្ចីដោយយកមូលហេតុច្បាស់លាស់ពីបំណង និងទិសដៅប្រើប្រាស់ប្រាក់កម្ចីនោះ ព្រមទាំងពេលវេលាដែលត្រូវសងប្រាក់វិញ។ ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុត្រូវធ្វើដំណើរការត្រួតពិនិត្យ ពាក្យសុំខ្ចីឲ្យបានល្អិតល្អន់សិនទើបសម្រេចឲ្យខ្ចី ឬ មិនឲ្យខ្ចី។ គោលការណ៍នេះ បង្ខំឲ្យអ្នកខ្ចីត្រូវរាយការណ៍ពីតួលេខ និងស្ថានភាពហិរញ្ញវត្ថុរបស់អង្គភាព ឬ គ្រួសាររបស់ខ្លួនឲ្យធនាគារ ឬគ្រឹះស្ថានហិរញ្ញវត្ថុដឹង។ ការត្រួតពិនិត្យផែនការ ឬគោលដៅប្រើប្រាស់ទុនជួបការលំបាកខ្លះ ព្រោះស្ថាប័នហិរញ្ញវត្ថុ និងរដ្ឋាភិបាលមិនអាចធ្វើអន្តរាគមន៍នៅក្នុងសកម្មភាពរបស់ពួកគេបានទេ។

**១.៥.៣.២. គោលការណ៍ឲ្យខ្ចីដោយសងវិញទាំងដើមទាំងការ**

នេះជាគោលការណ៍សំខាន់បំផុតរបស់ឥណទាន។ គោលការណ៍នេះ បង្ខំឲ្យអ្នកខ្ចីត្រូវគិតប្រើប្រាស់ទុនខ្ចីឲ្យមានប្រសិទ្ធិភាពបំផុតដើម្បីធ្វើយ៉ាងណាឲ្យផលិតកម្ម និង អាជីវកម្មរបស់គេបានចំណេញទើបមានលទ្ធភាពសងទាំងដើមទាំងការឲ្យម្ចាស់បំណុលវិញ។ គោលការណ៍នេះ មានន័យ

[15] រុន សិរីមាលា និងសុខ ថានីន "*ការផ្តល់ឥណទានខ្នាតតូចបំផុត និងខ្នាតតូច*" ឆ្នាំ ២០១១, ទំព័រ១៨-២១

ចំពោះអ្នកសុំខ្ចីប្រាក់ផង និងអ្នកឲ្យខ្ចីផងដោយផ្អែកលើមូលដ្ឋានកូនបំណុលត្រូវសងតាមពេលកំណត់ទាំងដើមទាំងការ។

### ១.៥.៣.៣. គោលការណ៍ឲ្យខ្ចីដោយមានការធានា

គោលការណ៍នេះ ទោះបីជាក្នុងទំហំទឹកប្រាក់ប៉ុណ្ណាក៏ដោយ អ្នកខ្ចីត្រូវមានការធានាលើបំណុលរបស់ខ្លួន ដូចជាធានាដោយសម្ភារៈ ទំនិញ បញ្ចាំដោយចលនទ្រព្យ ឬត្រូវបានធានាចេញសងដោយអ្នកធានា។ការអនុវត្តគោលការណ៍នេះ ត្រូវធ្វើឲ្យបានសមស្របទៅនឹងភាពជាក់ស្តែងណាមួយ។ គោលការណ៍ឥណទានទាំងបីដូចមានពោលខាងលើមានទំនាក់ទំនងគ្នាទៅវិញទៅមក ហើយឥណទាននោះត្រូវសើរើមើលតាមកាលវិភាគ ដែលបានកំណត់ទាល់តែដល់ពេលកំណត់ត្រូវសង។ បែបបទនៃការសើរើឥណទានមានច្រើនយ៉ាងតែគោលការណ៍ទូទៅមួយចំនួនដែលធនាគារច្រើនយកមកអនុវត្តមានដូចខាងក្រោមះ

១. អនុវត្តការសើរើឥណទានគ្រប់ប្រភេទទាំងអស់តាមការកំណត់។ ឧទាហរណ៍ សើរើម្តងក្នុងរយៈពេល ៣០ ថ្ងៃ ឬ ៩០ ថ្ងៃ។

២. ត្រូវរៀបចំយ៉ាងណា ដើម្បីធានាទិដ្ឋភាពសំខាន់ៗនៃឥណទាននីមួយៗ និងត្រូវបានពិនិត្យមើលយ៉ាងត្រឹមត្រូវ។ ទិដ្ឋភាពទាំងនេះមានដូចជាះ

ក. បញ្ជីសងបំណុលរបស់អ្នកខ្ចីប្រាក់ដើម្បីដឹងឲ្យប្រាកដថា កូនបំណុលបានសងត្រឹមត្រូវតាមការកំណត់។

ខ. គុណភាព និងលក្ខណៈនៃវត្ថុធានា។

គ. សំណុំឯកសារខ្ចីប្រាក់ត្រូវមានគ្រប់គ្រាន់ ដើម្បីឲ្យធនាគារមានសិទ្ធិអំណាចស្របច្បាប់ ក្នុងការប្តឹងទាមទារដកហូតវត្ថុបញ្ចាំ ក្នុងករណីអ្នកខ្ចីមិនព្រមសងបំណុលវិញ។ នោះធនាគារមានសិទ្ធិអំណាចស្របច្បាប់ក្នុងការប្តឹងទាមទារវត្ថុបញ្ចាំពីអ្នកខ្ចីប្រាក់ ប្រសិនបើមានការចាំបាច់។

ឃ. ធ្វើការវាយតម្លៃថា តើស្ថានភាពហិរញ្ញវត្ថុរបស់អ្នកខ្ចីមានការប្រែប្រួលដែរឬទេ? ដែលអាចធ្វើឲ្យតម្រូវការឥណទានរបស់អ្នកខ្ចីប្រាក់កើនឡើង ឬថយចុះ។

ង. ធ្វើការវាយតម្លៃ ថាតើស្ថានភាពហិរញ្ញវត្ថុរបស់អ្នកខ្ចីនោះ សមស្របទៅនឹងនយោបាយឥណទានដែលបានកំណត់ឬទេ? ហើយសមស្របទៅនឹងស្តង់ដា ដែលអ្នកត្រួតពិនិត្យឥណទានបានអនុវត្តចំពោះប្រតិបត្តិការផ្តល់កម្ចីឬទេ?

៣. សើរើមើលឲ្យបានញឹកញាប់បំផុតចំពោះឥណទានធំៗ ពីព្រោះបើចំណុចធំៗមិនអាចទារបាននោះវានឹងមានផលប៉ះពាល់ខ្លាំងទៅលើស្ថានភាពហិរញ្ញវត្ថុរបស់អង្គភាពទាំងមូល។

៤. ធ្វើការសើរើឲ្យបានញឹកញាប់បំផុតចំពោះបំណុលដែលមានបញ្ហា។

៥. បង្កើតការសើរើមើលឥណទានប្រសិនបើសេដ្ឋកិច្ចកំពុងធ្លាក់ចុះ ឬ បើសិនឧស្សាហកម្មដែលជារបរអាជីវកម្មរបស់អតិថិជនកំពុងជួបបញ្ហាដូចជា មានអ្នកប្រកួតប្រជែងថ្មី ឬការប្រែប្រួលបច្ចេកវិទ្យាជាដើម។

**១.៥.៣.៤. គោលការណ៍នៃការប្រមូលប្រាក់បំណុល**

ការប្រមូលបំណុល គឺធ្វើឡើងអាស្រ័យទៅនឹងកាលបរិច្ឆេទទូទាត់បំណុលដែលបានកំណត់។ អ្នកគ្រប់គ្រងឥណទានរក្សាទុកនូវរបាយការណ៍នៃបទពិសោធន៍កន្លងមក ក្នុងការទូទាត់សងរបស់កូនបំណុលនីមួយៗ។ ស្ថាប័នមីក្រូហិរញ្ញវត្ថុតែងតែអនុវត្តតាមវិធីនៅពេលដែលអតិថិជនមិនអាចមានលទ្ធភាពសងបំណុលវិញបាន។

នីតិវិធីទាំងនោះមានដូចជា៖

-បញ្ជូនភ្នាក់ងារឥណទានទៅដាស់តឿនដល់កន្លែង

-ផ្ញើរលិខិតបញ្ជាក់ពីការហួសពេលកំណត់សង

-ទូរស័ព្ទដាស់តឿនអតិថិជន

-ប្តឹងតាមនីតិវិធីទៅតុលាការ

**១.៥.៣.៥. គោលការណ៍ផាកពិន័យចំពោះការសងបំណុលយឺត និងការខកខានមិនបានសង**

ការខកខាន៖ អតិថិជនមិនអាចខកខាន (យឺតយ៉ាវ) ក្នុងការបង់ខាតប្រាក់តាមពេលវេលាដែលបានកំណត់ឡើងនោះឡើយ ប្រសិនបើមានការខកខានក្នុងការសងប្រាក់ចាប់ពីមួយថ្ងៃឡើងទៅ អតិថិជននោះត្រូវការផាកពិន័យលើការយឺតយ៉ាវនោះ។

ការផាកពិន័យ៖ អតិថិជនដែលសងយឺតយ៉ាវចាប់ពីមួយថ្ងៃឡើងទៅ នោះស្ថាប័ននឹងធ្វើការផាកពិន័យទៅតាមគោលការណ៍ដែលស្ថាប័ននីមួយៗបានកំណត់។

**១.៥.៤. ការវាយតម្លៃឥណទាន**[16]

ដើម្បីធ្វើឲ្យការផ្តល់កម្ចីដំណើរការទៅប្រកបដោយគុណភាព ទាមទារឲ្យយើងប្រើប្រាស់នូវការវិនិច្ឆ័យទៅលើចំណុចសំខាន់ៗចំនួន ៦ចំណុច គឺរួមមាន ចរិកលក្ខណៈ សមត្ថភាព ដើមទុន វត្ថុបញ្ចាំ លក្ខខណ្ឌ និងសុភវិនិច្ឆ័យ។

ចំណុចទាំងនេះនឹងជួយក្នុងការគ្រប់គ្រងឥណទាន បំពេញភារកិច្ចត្រួតពិនិត្យបានឆាប់រហ័សដើម្បីបញ្ជាក់ប្រសិនបើព័ត៌មានណាមួយមើលរំលង និងបញ្ជាក់ពីគុណភាពឥណទានដែលមាន តម្រូវការនៃការស៊ើបអង្កេត មុននឹងធ្វើការសម្រេចចិត្តផ្តល់ឥណទាន។

[16] Robert Cole & Lon Mishler *"Consumer and Business Credit Management"*(1998), 11th Edition, Page 168-170

**១.៥.៤.១. ចរិកលក្ខណ:**

ចរិកលក្ខណ: គឺជាចំនួនអរូបិយនៃឥរិយាបទរបស់បុគ្គលម្នាក់ៗដែលទាក់ទងនឹងសុចរិតភាព និងភាពខ្លាំងដែលប្រកបដោយសីលធម៌របស់មនុស្ស។ កត្តាដែលរាប់បញ្ចូលទៅក្នុងការកំណត់ពីចរិកលក្ខណ: រួមមានដូចជាទម្លាប់នៃការរស់នៅផ្ទាល់ខ្លួនរបស់បុគ្គល និងឥរិយាបទមួយចំនួនទៀតដូចជា ការផឹកស៊ី ការលេងល្បែងស៊ីសង និងសកម្មភាពមួយចំនួនទៀត។ ចរិកលក្ខណ: អាចនឹងត្រូវបានគេសម្តែងចេញតាមរយ:ឥរិយាបទនៃអាជីវកម្ម ( business or professional conduct) ដូចជាកាតព្វកិច្ចក្នុងការសងត្រឡប់ ទំនោរក្នុងការទាមទារដែលគ្មានការធានា ឬការប្រគល់ទំនិញត្រឡប់វិញដោយគ្មានមូលហេតុ និងការគោរពសិទ្ធិអ្នកដទៃ។ ចរិកលក្ខណ:នៃឥណទានគឺជាចំណុចសំខាន់ដែលបង្ហាញពីការប្តេជ្ញាចិត្តរបស់អតិថិជនក្នុងការសងត្រឡប់មកវិញតាមការព្រមព្រៀង។

ចរិកលក្ខណ: គឺជាកត្តាខាងក្នុងដែលមិនអាចវាស់បាន ឬក៏វាយតម្លៃដោយស្ថានភាពខាងក្រៅរបស់បុគ្គលមួយបានទេ។ ជាការពិតណាស់ វាមានការពិបាកសម្រាប់អ្នកគ្រប់គ្រងឥណទានក្នុងការធ្វើការសម្រេចចិត្ត និងវាយតម្លៃលើចរិកលក្ខណ:។ តែទោះបីយ៉ាងណាក៏ការស៊ើបអង្កេតឥណទាននៅតែអាចធ្វើការប្រមើលមើលបានដើម្បីទទួលបាននូវព័ត៌មានមួយជាក់លាក់។

**១.៥.៤.២. សមត្ថភាព**

សមត្ថភាព គឺជាលទ្ធភាពរបស់អ្នកស្នើសុំឥណទាន និងបញ្ជាក់ពីកាតព្វកិច្ចសងបំណុលទៅតាមគម្រោងផែនការ ដែលបានកំណត់។ ការវាស់វែងពីសមត្ថភាពរបស់អ្នកស្នើសុំ ជាទូទៅពាក់ព័ន្ធទៅនឹងចំណូល និងភាពមានការងារធ្វើរបស់អ្នកស្នើសុំនោះ។ ម្យ៉ាងទៀតលទ្ធភាពសងបំណុលរបស់ អ្នកស្នើសុំ គឺកំណត់ដោយកម្រិតចំណាយ និងភាពជំពាក់បំណុល។ ឧទាហរណ៍៖ អ្នកស្នើសុំឥណទានអាចមានចំណូលមិនគ្រប់គ្រាន់ ដើម្បីសងបំណុលដោយសារចំណូលទាប ឬបំណុលមានកម្រិតខ្ពស់។ សរុបមក ចំណូលត្រូវមានការព្យាករណ៍ទុក និងមាននិរន្តភាព។ សមត្ថភាពសងនឹងទទួលការគំរាមគំហែង បើសិនបុគ្គលម្នាក់គ្មានការងារធ្វើ ឬចំណូលទាប។

## ១.៦. វិធីសាស្ត្រសងរំលស់នៃឥណទាន[17]

### ១.៦.១. បំណុលដែលសងតែម្តងគត់នៅកាលអវសាន ( Pure Discount Loan )

បំណុលដែលសងតែម្តងគត់នៅកាលអវសាន គឺជាទម្រង់ដ៏សាមញ្ញបំផុតរបស់ឥណទាន។ ជាមួយនឹងកម្ចីប្រភេទនេះ អ្នកខ្ចីទទួលបានសាច់ប្រាក់នៅថ្ងៃនេះ ឬពេលបច្ចុប្បន្ន ហើយនឹងត្រូវ

[17] Prum Sokun "*Fundamentals of Corporate Finance I* ";Chapter 6, Page 18-22,2012 Second Edition

ទូទាត់សងទៅម្ចាស់បំណុលវិញនូវចំនួនសរុបនៃទឹកប្រាក់ (ការប្រាក់ បូកប្រាក់ដើម) នៅកាលកំណត់ណាមួយនាពេលអនាគតដែលបានព្រមព្រៀងគ្នាទុក(ដូចមានបង្ហាញនៅឧបសម្ព័ន្ធ១៥)[18]។

### ១.៦.២. បំណុលដែលសងតែការប្រាក់ ( Interest-Only Loan )

ប្រភេទទីពីរនៃការសងបំណុល គឺបំណុលដែលសងតែការប្រាក់ វាគឺជាវិធីសាស្ត្រម៉្យាងដែលអនុញ្ញាតឲ្យអ្នកខ្ចីបង់សងតែការប្រាក់ទៅតាមគ្រា ឬខែនីមួយៗហើយសងប្រាក់ដើមទាំងអស់នៅកាលកំណត់ណាមួយនាពេលអនាគតដែលបានព្រមព្រៀងគ្នាទុក (ដូចមានបង្ហាញនៅឧបសម្ព័ន្ធ ១៥)[19]។

### ១.៦.៣. បំណុលសងរំលស់

ជាមួយនឹងបំណុលដែលសងតែម្តងគត់នៅកាលអវសាន (Pure Discount Loan) និងបំណុលដែលសងតែការប្រាក់ ប្រាក់ដើមសរុបទាំងអស់ គឺត្រូវសងតែម្តងគត់នៅគ្រាណាមួយនាពេលអនាគត។ ជម្រើសនៃការសងបំណុលមួយទៀត គឺសងរំលស់ដែលការសងប្រភេទនេះ ម្ចាស់បំណុលតម្រូវឲ្យអ្នកខ្ចីប្រាក់ធ្វើការសងត្រឡប់វិញជាផ្នែកៗគ្រប់ពេលវេលាដែលបានកំណត់។ ការសងរំលស់មានពីរយ៉ាងគឺ:

ការសងរំលស់ប្រាក់ដើមស្មើៗគ្នាប្រចាំគ្រា និងសងរំលស់ដែលមានសំណាងស្មើៗគ្នា (ដូចមានបង្ហាញនៅឧបសម្ព័ន្ធ១៥[20])។

## ១.៧. ការគ្រប់គ្រងហានិភ័យឥណទាន

### ១.៧.១. និយមន័យ

[21]ហានិភ័យឥណទាន គឺជាប្រូបាប៊ីលីតេដែលអាចកើតឡើងចំពោះធនាគារ ដែលធ្វើឲ្យធនាគារទទួលរងនូវការខាតបង់ដោយសារអតិថិជនរបស់ខ្លួន មិនសងបំណុលតាមកិច្ចសន្យា ឬមិនអាចសងបំណុលបាន រឺសងមិនគ្រប់ចំនួនទឹកប្រាក់ទាំងដើម និងការប្រាក់។

[22]ហានិភ័យឥណទាន គឺជាកម្រិតនៃគ្រោះថ្នាក់ដែលកើតឡើងចំពោះប្រាក់កម្ចីរបស់ធនាគារដោយទទួលរងនៃការខាតបង់ដោយអតិថិជនរបស់ខ្លួន មិនសងបំណុលតាមកិច្ចសន្យា ឬសងមិនគ្រប់ចំនួនទឹកប្រាក់ទាំងដើមទាំងការប្រាក់។ ហានិភ័យនេះជាហានិភ័យដែលធនាគារយកចិត្តទុកដាក់ជាងគេ ព្រោះហានិភ័យនេះអាចធ្វើឲ្យធនាគារក្ស័យធនបាន។ ដូចនេះមុននឹងសម្រេចចិត្ត

[18] សម្រាប់ឧទាហរណ៍ជាតម្លៃលេខសូមមើលឧបសម្ព័ន្ធ ១៥ ទំព័រ i

[19] សម្រាប់ឧទាហរណ៍ជាតម្លៃលេខសូមមើលឧបសម្ព័ន្ធ១៥ ទំព័រ ii

[20] សម្រាប់ឧទាហរណ៍ជាតម្លៃលេខសូមមើលឧបសម្ព័ន្ធ១៥ ទំព័រ ii &iv

[21] សួន ចំរើន *"រូបិយវត្ថុ និងធនាគារ"*២០១១, ទំព័រ ១៥

[22] ងួន ហេង *"រូបិយវត្ថុ និងធនាគារ"*២០១១, ទំព័រ ៨២

ផ្តល់ឥណទានគេតែងតែសិក្សាទៅលើហានិភ័យជាចម្បង លុះត្រាតែធនាគារ យល់ឃើញថាគ្មានហានិភ័យ ឬមានហានិភ័យទាបទើបធនាគារផ្តល់ឥណទាន។

### ១.៧.២. មូលហេតុដែលបណ្តាលឲ្យមានហានិភ័យ[23]

#### ១.៧.២.១. មូលហេតុបណ្តាលមកពីអតិថិជន

- ការព្យាករណ៍ រឺការវាយតម្លៃលើការវិនិយោគនៅទាបៈ គំនិតក្នុងការវិនិយោគនៅស្ទើរ មិនទាន់មានសមត្ថភាពគ្រប់គ្រាន់ និងវិភាគឲ្យបានគ្រប់ជ្រុងជ្រោយ
- មិនសូវមានការពិចារណាឲ្យបានស៊ីជម្រៅទៅលើការវិនិយោគណាមួយ ឬចូលចិត្តការវិនិយោគណាដែលមានប្រាក់ចំណេញច្រើន
- អាចត្រូវដៃគូ ឬអ្នកវិនិយោគដទៃទៀតបោកប្រាស់
- ការប្រើប្រាស់លុយខុសគោលដៅ
- អតិថិជនខ្លះមានគោលបំណងមិនសងប្រាក់ធនាគារ ទោះបីជាមានលទ្ធភាពសងក៏ដោយ
- គ្រួសារ ឬសមាជិកណាមួយក្នុងគ្រួសារត្រូវការលុយក្នុងការមើលជម្ងឺ។

#### ១.៧.២.២. មូលហេតុបណ្តាលមកពីធនាគារ

- បុគ្គលិកពុំមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីវាយតម្លៃអតិថិជន ឬការវិនិច្ឆ័យមិនបានត្រឹមត្រូវ
- បុគ្គលិកមានចេតនាធ្វើឲ្យមានកំហុស
- បុគ្គលិកពុំមានភាពស្មោះត្រង់
- ភ្នាក់ងារឥណទានមិនបានយកចិត្តទុកដាក់ក្នុងការតាមដាន ត្រួតពិនិត្យបំណុលទាន់ពេលវេលា

#### ១.៧.២.៣. មូលហេតុដែលបណ្តាលមកពីសេដ្ឋកិច្ច សង្គម និងគ្រោះធម្មជាតិ

- សេដ្ឋកិច្ច : កាលណាមានវិបត្តិសេដ្ឋកិច្ចកើតឡើង នាំឲ្យបណ្តាក្រុមហ៊ុនសហគ្រាសប្រឈមមុខនឹងការក្ស័យធន ព្រោះថាតម្រូវការអតិថិជន មានការធ្លាក់ចុះដែលជាមូលហេតុធ្វើឲ្យចំណូលផ្ទាល់ខ្លួន និងចំណូលក្រុមហ៊ុនធ្លាក់ចុះ។ ដូច្នេះក្រុមហ៊ុនពុំមានលទ្ធភាពសងបំណុលធនាគារ។
- សង្គម : មានដូចជាសង្គ្រាម មានការប្រែប្រួលនៃសេដ្ឋកិច្ច ការផ្លាស់ប្តូររដ្ឋាភិបាលនយោបាយ។

---

[23] សួន ចំរើន *"រូបិយវត្ថុ និងធនាគារ"* ២០១១, ទំព័រ២៤

- គ្រោះធម្មជាតិ : ទឹកជំនន់ គ្រោះរាំងស្ងួត ភ្លើងឆេះព្រៃ ផ្ទុះ នាំឲ្យអតិថិជនបាត់បង់លទ្ធភាពសងដោយសារអាជីវកម្ម ឬមុខរបរត្រូវបានផ្អាកដំណើរការ[24]។

### ១.៧.៣. ផលប៉ះពាល់ដែលបណ្តាលឲ្យមានហានិភ័យឥណទាន[25]

នៅពេលដែលហានិភ័យមានទំហំកាន់តែធំឡើងៗនឹងនាំឲ្យមានផលប៉ះពាល់ ដូចខាងក្រោមៈ

- **បង្កើនចំណាយបន្ថែមសម្រាប់ប្រតិបត្តិការដូចជាៈ**
  - ភ្នាក់ងារចំណាយពេលច្រើន ដើម្បីតាមដាន
  - ភ្នាក់ងារមិនមានពេលសម្រាប់បញ្ចេញឥណទានថ្មីៗទៀត
  - រំលស់យានយន្ត ក្រដាសស្នាម ប្រេងឥន្ទនៈ ថ្លៃប្រថាប់ត្រា និងរត់ការផ្សេងៗកើនឡើង
- **ខូចកេរ្តិ៍ឈ្មោះធនាគារ**
  - ក្រមសីលធម៌ភ្នាក់ងារ អាចនឹងធ្លាក់ចុះពេលមានវិវាទកើតឡើង
  - បុគ្គលិកអាចមិនស្តាប់បង្គាប់អ្នកគ្រប់គ្រង ព្រោះអស់សង្ឃឹមក្នុងវិជ្ជាជីវៈ
  - អតិថិជនមិនមានជំនឿលើធនាគារ ហើយមិនហ៊ានមកដាក់ប្រាក់បញ្ញើ
  - អតិថិជនធ្លាប់សងទៀងទាត់ បែរជាមិនទៀងទាត់តាមគេឯង
- **សរុបលទ្ធផល**
  - បាត់បង់ទីផ្សារ
  - ចំណូលពីការប្រាក់ថយចុះ
  - គ្មានមូលនិធិសងការប្រាក់បញ្ញើ
  - ប្រាក់ចំនេញរបស់ធនាគារទាប
  - អតិថិជនដកប្រាក់បញ្ញើចេញពីធនាគារ
  - ក្ស័យធន
  - បុគ្គលិកគ្មានការងារធ្វើ។

### ១.៧.៤. យុទ្ធសាស្ត្រក្នុងការកាត់បន្ថយហានិភ័យឥណទាន[26]

- **ចំពោះអតិថិជន**
  - ធ្វើការវាយតម្លៃឲ្យត្រឹមត្រូវពីអតិថិជនដូចជាៈ

[24] សុខ ចំរើន និង ឡេង សុភក្រ្ត ឆ្នាំ២០១៣, ទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ ទំព័រ ៥៦-៥៧

[25] កាន់ ដានី និង ឡេង ណាឌី *"នីតិវិធីនៃការផ្តល់ឥណទានរបស់ធនាគារពាណិជ្ជក្រោងប្រទេសនៃកម្ពុជា"*, (FTB), 2012

[26] សួន ចំរើន *, ហិរញ្ញវត្ថុ"* ២០១១,ទំព័រ២៥

- គោលបំណងនៃការសុំខ្ចី
- វិភាគលើរបាយការណ៍ហិរញ្ញវត្ថុ
- ពិចារណាលើគោលជំហរអ្នកសុំខ្ចី (ប្រវត្តិរូប)
- ផែនការគម្រោង

– ត្រូវមានវត្ថុបញ្ចាំ រឺអ្នកធានា

– ផ្តល់យោបល់ក្នុងករណីផ្សេងៗដែលទាក់ទងនឹងការធ្វើអាជីវកម្មរបស់អតិថិជន

❖ **ចំពោះធនាគារ**

– ពង្រឹងសមត្ថភាពបុគ្គលិក ដែលមានចំណេះដឹងផ្នែកឥណទាន

- ជ្រើសរើសបុគ្គលិក ដែលមានចំនេះដឹងផ្នែកឥណទាន
- បណ្តុះបណ្តាលបន្ថែមដល់បុគ្គលិក

– ការដាក់ទោសចំពោះបុគ្គលិកដែលមានកំហុស

– ការលើកទឹកចិត្ត

❖ **ចំពោះសេដ្ឋកិច្ច-សង្គម**

– វិបត្តិសេដ្ឋកិច្ច

– អសន្តិសុខសង្គម

– គ្រោះថ្នាក់ធម្មជាតិ

## ១.៨. វិធីសាស្ត្រគិតការប្រាក់

### ១.៨.១. និយមន័យ

[27]ការប្រាក់ គឺជាចំនួននៃសាច់ប្រាក់ដែលអ្នកខ្ចីប្រាក់បង់ទៅឲ្យម្ចាស់បំណុលសម្រាប់ការប្រើប្រាស់បណ្តោះអាសន្ននៃប្រាក់របស់ម្ចាស់បំណុល។ ឬម៉្យាងទៀត ការប្រាក់គឺជាថ្លៃឈ្នួលដែលអ្នកខ្ចីបង់ទៅឲ្យម្ចាស់បំណុលសម្រាប់ការប្រើប្រាស់សាច់ប្រាក់។

[28]ការប្រាក់ គឺជាប្រាក់ដែលកូនបំណុលសងទៅម្ចាស់បំណុលជាថ្លៃឈ្នួលនៃការប្រើប្រាស់លុយរបស់គេ។

### ១.៨.២. ការប្រាក់ធម្មតា (Simple Interest)[29]

រូបមន្តសម្រាប់គណនាការប្រាក់ធម្មតាគឺ៖

[27] Timothy J. Beihler ”*The Mathematics of Money* “,2008,Page 3

[28] ព្រុំ សុគុណ " *គណិតវិទ្យាហិរញ្ញវត្ថុ*"២០១១, ទំព័រ២០

[29] ងួន ហោង "*រូបិយវត្ថុ និងធនាគារ*"២០១១, ទំព័រ ៣៣-៣៤

| ការប្រាក់ = ប្រាក់ដើម × អត្រាការប្រាក់ × រយៈពេល(គិតជាឆ្នាំ) |
|---|

ចំនួនប្រាក់សរុបពេលអនាគត = ប្រាក់ដើម + ការប្រាក់

= ប្រាក់ដើម + (ប្រាក់ដើម× អត្រាការប្រាក់× រយៈពេល)

= ប្រាក់ដើម + (១+ អត្រាការប្រាក់ × រយៈពេល)

ដូចនេះ គេបានរូបមន្តសម្រាប់កម្ចីធម្មតាចំនួនប្រាក់សរុប = $P\times(1+rt)$

ដែល P: ជាប្រាក់ដើម

r: ជាអត្រាការប្រាក់

t: ជារយៈពេល

ឧទាហរណ៍៖ អ្នកផ្តល់កម្ចីដល់គេ ១០០ ដុល្លារអាមេរិក សម្រាប់រយៈពេល ១ ឆ្នាំ ក្នុងអត្រាការប្រាក់ប្រចាំឆ្នាំ ៨ ភាគរយ។ តើអ្នកនឹងទទួលបានការប្រាក់ប៉ុន្មានត្រឡប់មកវិញ? តើមូលនិធិសរុបដែលនឹងទទួលបានពេលអនាគតស្មើប៉ុន្មាន?

- **ចម្លើយ**

ក. ការប្រាក់ដែលទទួលបានស្មើ

ការប្រាក់ = ១០០ × 0.0៨ × ១ = ៨ ដុល្លារអាមេរិក

ខ. ចំនួនមូលនិធិសរុបដែលនឹងទទួលបានពេលអនាគតស្មើ

ចំនួនសរុបពេលអនាគត = ១០០ × (១+0.0៨ x១) = ១០៨ ដុល្លារអាមេរិក

### ១.៨.៣. ការប្រាក់ផ្គួប ( Compound Interest )[30]

ការប្រាក់ផ្គួប គឺជាការប្រាក់មួយប្រភេទដែលធ្វើឲ្យសាច់ប្រាក់មានកំនើនលឿន ព្រោះវាជាការទទួលការប្រាក់លើការប្រាក់។ ដោយសារតែគិតជាការប្រាក់ផ្គួប ការប្រាក់ដែលទទួលបាននៅចុងឆ្នាំ នឹងបូកបញ្ចូលទៅក្នុងប្រាក់ដើម ដែលអាចឲ្យអ្នកទទួលបានការប្រាក់លើការប្រាក់ដែលបានបូកបញ្ចូលទៅក្នុងប្រាក់ដើមនៅឆ្នាំបន្ទាប់។

ធនាគារជាធម្មតា បង់ការប្រាក់ផ្គួបឲ្យអ្នកដាក់ប្រាក់បញ្ញើ ដែលបើកគណនីសន្សំនៅធនាគារ។ ការប្រាក់ដែលអ្នកដាក់ប្រាក់បញ្ញើទទួលបាននឹងត្រូវបញ្ចូលទៅក្នុងប្រាក់ដើមតាមរយៈដែលបានកំណត់ ហើយការប្រាក់នេះនឹងទទួលបានការប្រាក់បន្ថែមទៀត។

រូបមន្ត៖

[30] ងួន ហោង "*រូបិយវត្ថុ និងធនាគារ*"២០១១, ទំព័រ ៦៣-៦៤

$$Fv = P \times (1 + r)^t$$

ដែល Fv : ប្រាក់សរុបពេលអនាគត

P : ជាប្រាក់ដើម

r : ជាអត្រាការប្រាក់

t : ជារយៈពេល

ឧទាហរណ៍ ៖ អ្នកផ្តល់កម្ចីដល់គេ ១០០ ដុល្លារអាមេរិក សម្រាប់រយៈពេល១០ឆ្នាំ ក្នុងអត្រាការប្រាក់ផ្គួបប្រចាំឆ្នាំ ៨ ភាគរយ។ តើមូលនិធិសរុបដែលនឹងទទួលបានពេលអនាគតស្មើប៉ុន្មាន?

❖ **ចម្លើយ**

មូលនិធិសរុបដែលនឹងទទួលបានពេលអនាគតស្មើ

Fv = ១០០ x ( ១ + 0.0៨ )$^{១0}$ = ២១៥.៨៩ ដុល្លារអាមេរិក

## ១.៩. វិធីសាស្ត្រដោះស្រាយឥណទានមានបញ្ហា[31]

បំណុលមានបញ្ហា កើតឡើងដោយសារតែការខ្វះសាច់ប្រាក់របស់កូនបំណុលក្នុងការទូទាត់សង។ គេមានវិធីសាស្ត្រជាច្រើន ដើម្បីដោះស្រាយជាមួយកូនបំណុលមានបញ្ហា ដូចខាងក្រោម៖

- **ការដោះស្រាយជាមួយអតិថិជន**

នៅពេលដែលកើតមានឡើងនូវឥណទានមានបញ្ហា វិធីសាស្ត្រដំបូងនោះ គឺដោះស្រាយជាមួយអតិថិជនផ្ទាល់ ដោយពិនិត្យមើលទៅលើឥណទានដែលមានបញ្ហានោះ តើវាបណ្តាលមកពីមូលហេតុអ្វី? ហើយមន្ត្រីឥណទានត្រូវប្រមូលព័ត៌មានអំពីអតិថិជនរបស់ខ្លួនបន្ថែមទៀត នឹងរកមូលហេតុដែលបង្កបញ្ហានោះ។ មន្ត្រីឥណទាន ត្រូវដោះស្រាយដោយសម្រួលជាមួយកូនបំណុល តែបើកូនបំណុលនោះនៅតែមិនព្រមសង មន្ត្រីឥណទានត្រូវនិយាយប្រាប់គាត់ពីការប្តឹងឡើងទៅតុលាការ ដើម្បីរឹបអូសនូវវត្ថុបញ្ចាំនោះ។ ប៉ុន្តែបើកូនបំណុលនៅតែមិនព្រមសងទៀត មន្ត្រីឥណទានត្រូវពឹងផ្អែកទៅលើរដ្ឋអំណាច ព្រោះថានៅពេលផ្តល់កម្ចីឲ្យអតិថិជនមានការទទួលដឹងឮពីខាងរដ្ឋអំណាចមានដូចជា ប្រធានភូមិ ប្រធានឃុំ ឬចៅសង្កាត់ជាដើម។ ផ្ទុយទៅវិញបើកូនបំណុលមានបញ្ហានោះបង្កឡើងដោយគ្រោះធម្មជាតិវិញនោះ គឺគេអាចជួយសម្រួលពន្យាពេលទូទាត់សងដល់គាត់បាន។

[31] ចាប់ សុវណ្ណលីដា និងឡង់ សុធីរ៉ា "*ឥណទានមុខជំនួញខ្នាតមធ្យម*", ២០១២,ទំព័រ២១

- **ការផ្តល់លទ្ធភាពជូនអតិថិជន**

ការផ្តល់លទ្ធភាពដល់កូនបំណុលទូទាត់សងនៅពេលគាត់ប្រមូលទិន្នផលបាន។ មន្ត្រីឥណទានត្រូវសាកសួរកូនបំណុលអំពីមូលហេតុរបស់គេម្នាក់ ហើយត្រូវប្រមូលព័ត៌មានថា តើពេលណាទើបគាត់ប្រមូលផលបាន និងមានលទ្ធភាព អាចសងបំណុលទាន់ពេលវេលាដែលបានព្រមព្រៀងគ្នា។

- **ការផាកពិន័យឲ្យបានខ្លាំង**

ការផាកពិន័យ ក៏ជាបញ្ហាមួយយ៉ាងសំខាន់របស់ធនាគារ ក្នុងការទប់ស្កាត់កុំឲ្យអតិថិជនសងប្រាក់យឺតយ៉ាវ ដែលជាទម្លាប់អាក្រក់មួយក្នុងការទូទាត់ ហើយការផាកពិន័យនោះក៏មាននៅគ្រប់ធនាគារ ឬស្ថាប័នដែរ។ គេយល់ឃើញថា ការដាក់កម្រិតនៃការផាកពិន័យនេះធ្វើឲ្យអតិថិជនមានការប្រុងប្រយ័ត្ន និងមិនហ៊ានគេចវេសពីការសងបំណុលឡើយ។ ការផាកពិន័យនោះ មានដូចជាការផាកពិន័យជាប្រាក់ ឬរឹបអូសយកទ្រព្យដាក់បញ្ចាំរបស់កូនបំណុល។

## ១.១០. តួនាទីឥណទានក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ[32]

ឥណទាន បាននឹងកំពុងក្លាយជាផ្នែកមួយ មិនអាចជៀសផុតក្នុងការរស់នៅប្រចាំថ្ងៃរបស់យើង។ ការប្រើប្រាស់ឥណទានអាចជាផលល្អ និងអាក្រក់ផងដែរ គឺអាស្រ័យលើមូលហេតុនៃតម្រូវការ និងលទ្ធផលទូទាត់របស់អ្នកខ្ចីតាមពេលកំណត់។

ឥណទានបានផ្តល់អត្ថប្រយោជន៍ជាច្រើនសម្រាប់ អ្នកប្រើប្រាស់ ការធ្វើជំនួញ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចដូចជាបង្កើនកម្រិតជីវភាពរស់នៅ ដោះស្រាយពេលមានអាសន្ន បង្កើនលទ្ធភាពទីផ្សារជាដើមដោយ យោងលើឥណទានជាប្រេងរំអិលសម្រាប់ក្បាលម៉ាស៊ីនសេដ្ឋកិច្ច។ ដូច្នេះឥណទានតែងផ្តល់មធ្យោបាយដើម្បីស្ថេរភាពដល់កម្រិតសកម្មភាពសេដ្ឋកិច្ចដោយធ្វើការកំណត់កម្រិតបន្ទុកហិរញ្ញវត្ថុ (អត្រាការប្រាក់) ខុសៗគ្នា ហើយជាពិសេសវាមានសារៈសំខាន់នៅក្នុងគោលនយោបាយហិរញ្ញវត្ថុដើម្បីរក្សាលំនឹងថ្លៃនៅលើទីផ្សារ ដែលមានឥទ្ធិពលការចំណាយ និងធ្វើការត្រួតពិនិត្យអត្រាការប្រាក់។

[32] Cole, R. & Mishler,L. (1998.˝*Consumer and Business Credit Management* ˝11thEdition, Page 11

# ជំពូកទី២
# ស្ថានភាពទូទៅរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត

## ២.១. ប្រវត្តិរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត

អម្រឹត គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឈានមុខគេនៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលទទួលបាននូវការគាំទ្រ និងមានទំនុកចិត្តពីស្ថាប័នជាតិ អន្តរជាតិ និងអតិថិជនរបស់ខ្លួនផងដែរ។ ឆ្លើយតបនឹងតម្រូវការសេវាហិរញ្ញវត្ថុលើគ្រប់រូបភាពរបស់ប្រជាពលរដ្ឋបច្ចុប្បន្ន អម្រឹតបានបង្កើតនូវសេវាហិរញ្ញវត្ថុច្រើនប្រភេទ ជាពិសេសការផ្តល់ឥណទានខ្នាតតូច ដល់ប្រជាពលរដ្ឋនៅទីជនបទ និងឥណទានខ្នាតមធ្យមសម្រាប់សហគ្រិនខ្នាតតូច និងមធ្យមផងដែរ។ មិនតែប៉ុណ្ណោះ អម្រឹត បានបង្កើតឲ្យមានសេវាផ្សេងៗទៀតដូចជា ប្រាក់បញ្ញើ និងសេវាផ្ទេរប្រាក់ក្នុងស្រុក ដើម្បីឆ្លើយតបនិងបំពេញតម្រូវការរបស់ប្រជាពលរដ្ឋទាំងអ្នកនៅទីប្រជុំជន និងជនបទនៅបណ្តាខេត្ត និងរាជធានីក្នុងប្រទេសកម្ពុជាឲ្យកាន់តែមានភាពងាយស្រួល។

អម្រឹត ដែលត្រូវបានស្គាល់ពីមុនថា "អ៊ីអឹមតេ" ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឈានមុខគេនៅកម្ពុជា ។ អម្រឹតមានសាវតាប្រវត្តិសាស្ត្រដូចតទៅះ

ឆ្នាំ១៩៩១ : GRET ដែលជាអង្គការក្រៅរដ្ឋាភិបាលរបស់ប្រទេសបារាំង រៀបចំគម្រោងពិសោធន៍មួយ ក្នុងការផ្តល់មីក្រូឥណទានដល់ប្រជាពលរដ្ឋនៅកម្ពុជានៅជនបទ។ ដំណាក់កាលពិសោធន៍លើកទីមួយត្រូវបានចាប់ផ្តើមអនុវត្តដោយមានផលិតផលតែមួយគត់ ដែលត្រូវបានគេស្គាល់ថា ឥណទានក្រុមធានាគ្នា។ តំបន់ប្រតិបត្តិការដែល អម្រឹត បានចូលទៅធ្វើការផ្តល់ឥណទានមុនដំបូងគេបង្អស់ គឺខេត្តចំនួនបីប៉ុណ្ណោះ។ ខេត្តបីនោះគឺមានខេត្តពីរ នៅខាងលិចទន្លេមេគង្គ ហើយខេត្តទាំងពីរនោះទៀត គឺនៅខាងលិចរាជធានីភ្នំពេញ។ ខេត្តទាំនោះ មានខេត្តកណ្តាល និងខេត្តកំពង់ស្ពឺ។ ចំណែកខេត្តមួយទៀតនោះ គឺមានទីតាំងនៅខាងកើតទន្លេមេគង្គគឺខេត្តព្រៃវែង។ ក្នុងចំណោមខេត្តទាំងបីនោះ អម្រឹតបានបើកបេឡាឥណទានសាកល្បងជូនប្រជាពលរដ្ឋបានខ្ចីប្រាក់ គឺមានចំនួនត្រឹមតែ៥បេឡាឥណទានតែប៉ុណ្ណោះ។ បេឡាទាំងនោះ គឺមានពីរបេឡានៅខេត្តកណ្តាល ៖ ១បេឡានៅស្រុកពញាឮ គឺនៅបេឡាអំពិលរូង (ដែលបេឡានេះគឺមានភូមិរណបចំនួនពីរទៀតគឺភូមិត្រពាំងពន្រ្ទា និងភូមិក្បាលអូ) និង ១បេឡាទៀតនៅស្រុកកណ្តាលស្ទឹង គឺបេឡាភារី (ដែលបេឡានេះ គឺមានភូមិរណបចំនួនពីរទៀត គឺភូមិអង្រ្គង និងភូមិជ្រឡាំង)។ ចំនែកនៅខេត្តកំពង់ស្ពឺវិញ គឺមានតែមួយបេឡាគត់នៅបេឡាក្រហែងស្រុកសំរោងទងនៃខេត្តកំពង់ស្ពឺ។ ក្រៅពីនោះ GRET បានបើកបេឡាចំនួនពីរទៀតនៅស្រុកបាភ្នំ នៃខេត្តព្រៃវែងគឺ៖ បេឡាចក និង បេឡាត្នោត ដែលបេឡានេះ មានភូមិរណបចំនួនបីទៀត គឺភូមិអង្កាញ់ ភូមិឃ្លាំង និងភូមិត្រពាំងសាលា។ ក្នុង

ចំណោមបេឡាឥណទានភូមិដែលបើកដំបូងគេនៅឆ្នាំ១៩៩១នោះ បេឡាបែកថ្លាងនៅស្រុកពញាឮ នៃខេត្តកណ្ដាល បានបើកមុនគេបង្អស់។ នៅក្នុងឆ្នាំដដែល អង្គការនេះបានធ្វើសកម្មភាពក្នុងការផ្ដល់ប្រាក់កម្ចីជូនប្រជាពលរដ្ឋដោយមានការសហការជាមួយក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ក្រោយពីពេល ហ្គ្រេត (GRET) បានប្រារព្ធធ្វើសិក្ខាសាលាមួយនៅខែឧសភា ក្នុងឆ្នាំ១៩៩១ ដោយពេលនោះមានសិក្ខាកាមចូលរួមចំនួនប្រមាណតែ៥០នាក់តែប៉ុណ្ណោះ។ អង្គសិក្ខាសាលានៅពេលនោះ គឺបានសម្រេច និងធ្វើការប្ដេជ្ញាដោយផ្ដោតមុខព្រួញ និងកំណត់គោលដៅតែមួយគត់ គឺការផ្ដល់ឥណទានជូនប្រជាពលរដ្ឋ ដែលការផ្ដល់ឥណទាននោះ ត្រូវតែមានចីរភាព និងនិរន្តរភាពយូរអង្វែង។ ការផ្ដល់ឥណទានរបស់ហ្គ្រេត (GRET) នៅពេលនោះ ត្រូវតែធ្វើឲ្យមានការរីកចម្រើនដល់អ្នកខ្ចី និងបង្កភាពងាយស្រួលដល់អ្នកខ្ចី។ ហើយនីតិវិធីក្នុងការផ្ដល់ឥណទាននៅពេលនោះគឺហ្គ្រេត (GRET) បានអនុវត្តនីតិវិធីក្នុងការផ្ដល់ឥណទានតាមធនាគារ Grameen Bank គឺបង្កើតក្រុមសាមគ្គីដោយធានាគ្នាដើម្បីខ្ចីប្រាក់។ ទឹកប្រាក់កម្ចី ដែលផ្ដល់ឲ្យសមាជិកក្រុមម្នាក់ៗបានខ្ចីខ្ពស់បំផុត មានត្រឹមតែ ៣០,០០០រៀល គត់តែប៉ុណ្ណោះ ស្មើប្រហែលតែ ៣០ដុល្លារសហរដ្ឋអាមេរិកគត់ (ជាប្រាក់ដុល្លារអាមេរិកនៅឆ្នាំនោះ)។ ដោយក្នុងមួយគ្រួសារអាចខ្ចីប្រាក់បានតែម្នាក់ប៉ុណ្ណោះហើយក្នុងមួយក្រុមៗ មានសមាជិកកំណត់ឲ្យខ្ចី មានចំនួនត្រឹមតែប្រាំនាក់តែប៉ុណ្ណោះ (មិនអាចច្រើនជាងប្រាំនាក់ ហើយក៏មិនឲ្យតិចជាប្រាំនាក់ដែរ) ដោយធានាគ្នាទៅវិញទៅមកក្នុងការខ្ចីប្រាក់សាមគ្គីពី GRET ។ ចំពោះ រយៈពេលនៃការខ្ចីនៅពេលនោះ មានរយៈពេលត្រឹមតែ ១០ខែតែប៉ុណ្ណោះក្នុងមួយវគ្គៗ។

ឆ្នាំ១៩៩៥ : ការចាប់ផ្ដើមនៃដំណាក់កាលទីពីរ ឥណទានក្រុមធានាគ្នាត្រូវបានកែប្រែស្ថិតក្រោមនីតិថ្មី ខណៈដែលផលិតផលឥណទានឯកជនត្រូវបានចាប់ផ្ដើមបង្កើតឲ្យមាន។ ទន្ទឹមនឹងគ្នានេះដែល GRET រៀបចំផែនការប្រែក្លាយគម្រោងនោះទៅជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

ឆ្នាំ១៩៩៦ : ការចាប់ផ្ដើមបង្កើតឈ្មោះ ឥណទានមូលដ្ឋានជនបទ (អឺ អឹម តេ)។

ឆ្នាំ១៩៩៨ : បញ្ចប់ដំណាក់កាលពិសោធន៍លើកទីមួយ។ រាល់សកម្មភាពទាំងអស់ផ្ទេរទៅដំណាក់កាលពិសោធន៍ទីពីរ។ ខណៈដែល អឺ អឹម តេ ចាប់ផ្ដើមធ្វើប្រតិបត្តិការដោយពឹងផ្អែកលើខ្លួនឯង រចនាសម្ព័ន្ធចាត់តាំងថ្មី ត្រូវបានរៀបចំឡើង ដោយការផ្ទេរការទទួលខុសត្រូវលើការគ្រប់គ្រងពីជំនាញបច្ចេកទេសទៅឲ្យបុគ្គលិកក្នុងស្រុក។

ឆ្នាំ១៩៩៩ : អឺ អឹម តេ ខ្ចីប្រាក់ពីធនាគារជាលើកដំបូង។

ឆ្នាំ២០០០ : អឺ អឹម តេ ក្លាយខ្លួនជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត មានឈ្មោះថា "ឥណទានមូលដ្ឋានជនបទ អិល ធី ឌី" ដោយមានដើមទុនចុះបញ្ជីចំនួន ៣៣០ លានរៀល ដែលទទួលបានពីភាគទុនិកចំនួនពីគឺ GRET និង SIDI ។

ឆ្នាំ២០០១ : អ៊ី អឹម តេ ទទួលអាជ្ញាប័ណ្ណគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុពីធនាគារជាតិកម្ពុជា។

ឆ្នាំ២០០២ : អ៊ី អឹម តេ ទទួលយកជាផ្លូវការនូវភាគហ៊ុនិកថ្មីចំនួនពីរទៀតគឺ Proparco និង La Fayette Participations និងពិចារណាលើការវិនិយោគចំពោះប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យាថ្មី។ អ៊ី អឹម តេ ចាប់ផ្តើមបង្កើតផលិតផលប្រាក់បញ្ញើមានវិញ្ញាបនបត្រនៅសាខាចំនួនពីរ។

ឆ្នាំ២០០៣ : អ៊ី អឹម តេ រៀបចំឡើងវិញនូវប្រភពឥណទានអាជីវកម្មឯកត្តជន ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារ និងបញ្ចុះអត្រាការប្រាក់ពី ៤% មកនៅចន្លោះពី ៣% ទៅ ៣.៥% ដោយយោងទៅតាមទំហំឥណទាន។ ធ្វើសេចក្តីសន្និដ្ឋានលើការគ្រាំទ្របច្ចេកទេសពីបរទេសអចិន្ត្រៃយ៍។ I&P ចូលរួមជាមួយ អ៊ី អឹម តេ ជាភាគទុនិកថ្មី។

ឆ្នាំ២០០៤ : អ៊ី អឹម តេ ត្រូវបានប្តូរឈ្មោះជា "អម្រឹត" នៅថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ២០០៤។

ឆ្នាំ២០០៥ : អម្រឹត ប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យាថ្មីមួយ ដែលមានឈ្មោះថា "Microbanker Windows Version" ។ អម្រឹត បំបែកឥណទានឯកត្តជនទៅជា (១) ឥណទានអាជីវកម្ម (២) ឥណទានសម្រាប់ការអប់រំ (៣) ឥណទានសម្រាប់កែលំអផ្ទះ (៤) ឥណទានសម្រាប់ការប្រើប្រាស់ក្នុងគ្រួសារ។ អម្រឹតចាប់ផ្តើមអនុវត្តប្រតិបត្តិការ ការិយាល័យជួរមុខ ដែលជាប្រតិបត្តិការផ្នែកធនាគារយ៉ាងសាមញ្ញ ពោល គឺអតិថិជនជាអ្នកខ្ចីតាមបណ្តាខេត្តរបស់គ្រឹះស្ថាន។

ឆ្នាំ២០០៦ : Advans S.A (ពីមុនជា LFI) ក្លាយជាភាគទុនិក។

ឆ្នាំ២០០៧ : បុគ្គា ដែលជាក្រុមហ៊ុនវិនិយោគរបស់បុគ្គលិកក្លាយជាភាគទុនិក។

ឆ្នាំ២០០៨ : SIDI និង I&P ចាកចេញប៉ុន្តែភាគទុនិកថ្មីចំនួនបីរូបមាន Proparco, FMO និង Oikocredit ចូលមកវិញ។

ឆ្នាំ២០០៩ : គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត ទទួលអាជ្ញាប័ណ្ណ ទទួលប្រាក់បញ្ញើពីសាធារណៈជន នៅខែមករា ឆ្នាំ២០០៩។ នៅជំណាច់ឆ្នាំនេះដែរ សាខាទាំងអស់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត ត្រូវបានរៀបចំរួចជាស្រេច ដើម្បីទទួលប្រាក់បញ្ញើពីសាធារណៈជន។

ឆ្នាំ២០១២ : ម្ចាស់ភាគហ៊ុន Oikocredit បានចាកចេញពីសមាជិកភាគហ៊ុន ហើយភាគហ៊ុនទាំងស្រុងបានទទួលទិញបន្តដោយ Advans SA ។

ឆ្នាំ២០១៥ : ម្ចាស់ភាគហ៊ុន Proparco និង GRET បានចាកចេញពីសមាជិកភាគហ៊ុនហើយភាគហ៊ុនទាំងស្រុងត្រូវបានទទួលទិញដោយ Advans, FMO និង BOTTAព្រមទាំងភាគ ទុនិកថ្មីគឺ IFC។

## ២.២. ប្រវត្តិរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹតសាខាស្រុកបាភ្នំ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹតសាខាស្រុកបាភ្នំ ជាសាខាមួយក្នុងចំណោមសាខាដទៃទៀត ដែលអាចបម្រើសេវាកម្មជូនអតិថិជន និងស្ថិតនៅក្រោមការគ្រប់គ្រងរបស់លោកប្រធានសាខា និង រចនាសម្ព័ន្ធគ្រប់គ្រងទាំងឡាយតាមនាយកដ្ឋានជំនាញរបស់ការិយាល័យកណ្តាល។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹតសាខាស្រុកបាភ្នំ បានចាប់បដិសន្ធិឡើងដំបូងនៅថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៩៨ ស្នាក់ការដំបូងនៅផ្ទះបុគ្គលិក បន្ទាប់មកក៏ផ្លាស់មកផ្សារឈើកាច់ ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០០៥ ហើយក៏ផ្លាស់មកទីតាំងបច្ចុប្បន្ន នៅថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៣។

## ២.៣. អត្តសញ្ញាណរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត

### ២.៣.១. រូបសញ្ញា

- អក្សរអម្រឹតពណ៌បៃតង
- អក្សរនៅជាមួយអ្នកដើម្បីអ្នកនៅពីក្រោមអម្រឹត
- សញ្ញាស្នាមញញឹមដែលភ្ជាប់ពីជើងត

### ២.៣.២. អត្ថន័យនៃរូបសញ្ញា

- **អម្រឹត** មានអត្ថន័យជាភាសាខ្មែរថា "ភាពយូរអង្វែងមិនចេះស្លាប់ ឬជាទឹកទិព្វ" និងមានន័យជាទំនៀមទម្លាប់ថា "ភាពចម្រុងចម្រើន និងត្រជាក់ត្រជុំ" ។
- **នៅជាមួយអ្នក ដើម្បីអ្នក** មានន័យថា ទោះជាទៅដល់ទីណាក៏ដោយ គ្រប់ពេលវេលា និងមានទំនាក់ទំនងយ៉ាងជិតស្និតរវាងអម្រឹត ជាមួយអតិថិជនតាមរយៈការផ្តល់ និងបម្រើសេវាជូនពួកគាត់ជានិរន្ត ក្នុងគោលបំណងជួយលើកស្ទួយកម្រិតជីវភាពឲ្យកាន់តែប្រសើរឡើង។
- **សញ្ញាស្នាមញញឹម** ដែលភ្ជាប់ពីជើងអក្សរ "ត" នៃឈ្មោះអម្រឹត សញ្ញានេះបង្ហាញពីទំនាក់ទំនងភាពជោគជ័យ ឬភាពរីករាយរបស់ អតិថិជនទៅនឹងសេវាហិរញ្ញវត្ថុរបស់គ្រឹះស្ថានអម្រឹត។
- ពណ៌បៃតង : តំណាងឲ្យភាពស្រស់ស្រាយរបស់អតិថិជនក្នុងការប្រើប្រាស់សេវាហិរញ្ញវត្ថុរបស់គ្រឹះស្ថានអម្រឹត។
- ពណ៌មាស : តំណាងឲ្យសមិទ្ធិផលដ៏ត្រចះត្រចង់ដែលអតិថិជនទទួលបានពីការវិនិយោគរបស់ខ្លួន។

## ២.៤. ទីតាំងរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត

### ២.៤.១. ទីតាំងសាខាទូទាំង២៤ខេត្ត-ក្រុង

អម្រឹត តែងតែធ្វើដំណើរទៅមុខ ថែមទៀតដើម្បីនាំមកជូនលោកអ្នក នូវប្រតិបត្តិការកាន់តែងាយស្រួលជាងមុន ហេតុនេះហើយយើងបានបង្កើតនូវបណ្តាញ សាខាប្រតិបត្តិការដ៏ទូលំទូលាយពេញក្នុងខេត្ត ក្រុងជាច្រើនរបស់ប្រទេសកម្ពុជា។ គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦ អម្រឹត ធ្វើប្រតិបត្តិការ នៅតាមបណ្តាញសាខាចំនួន ១៤១ ការិយាល័យ នៅទូទាំងរាជធានី/ខេត្តចំនួន២៥ ដែលនេះមានន័យថាដរាបណាមានអតិថិជននៅទីណា នោះប្រាកដជាមានបុគ្គលិករបស់អម្រឹត នៅជិតអតិថិជនដែរ។ បណ្តាញប្រតិបត្តិការ អម្រឹតមានទីតាំងស្ថិតនៅកន្លែងងាយស្រួលសម្រាប់អតិថិជន និងមានសេវាដ៏ប្រសើរដល់ទីកន្លែង។



### ២.៤.២. ទីតាំងរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត សាខាស្រុកបាភ្នំ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត សាខាស្រុកបាភ្នំ មានទីតាំងស្ថិតនៅភូមិ ឈើកាច់ ឃុំ ឈើកាច់ ស្រុក បាភ្នំ ខេត្ត ព្រៃវែង ព្រះរាជាណាចក្រកម្ពុជា។

Mr. Yean Yat , Acting Branch Manager

Mobile: +885 (0) 96 61 42 447

Email: pvbpdm@amret.com.kh



## ២.៥. ភាគទុនិក ដើមទុន និងប្រភពហិរញ្ញវត្ថុ

### ២.៥.១. ភាគហ៊ុនិក ដើមទុន

អម្រឹតមានក្រុមនៃភាគទុនិក ដែលបានរៀបចំបង្កើតជាក្រុមប្រឹក្សាភិបាល។ សមាជិកនៃក្រុមប្រឹក្សាភិបាលបានជ្រើសរើស និងតែងតាំងដោយភាគទុនិក ដោយមានការអនុញ្ញាតពីធនាគារកណ្តាលដោយយោងតាមលក្ខណៈគុណសម្បត្តិ របស់ពួកគេជំនាញបន្ថែមនិង បទពិសោធន៍ ជាពិសេសវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ។ សមាជិកនៃក្រុមប្រឹក្សាភិបាលបានបែងចែកគណៈកម្មការជាពីរ គឺគណៈកម្មការសវនកម្ម គណៈកម្មការគ្រប់គ្រងហានិភ័យទូទៅ និងគណៈកម្មការទូទាត់សំណង។

ក្នុងខែមិថុនា លើកទី៣០ ឆ្នាំ២០១៦ អម្រឹត មានបុគ្គលិកប្រហែលចំនួន ៣,៦០០នាក់ ដែលក្នុងនោះ បានបែងចែកជាបីក្រុម ដោយក្រុមរបស់គាត់មានតួនាទីក្នុងហ៊ុនផ្សេងៗពីគ្នាគឺៈ ក្រុមបុគ្គលិកគ្រប់គ្រង ក្រុមបុគ្គលិកប្រតិបត្តិការ និងក្រុមបុគ្គលិកផ្គត់ផ្គង់។ ក្រុមបុគ្គលិកគ្រប់គ្រងមានសមាជិកចំនួន ១៤ នាក់ ភាគច្រើននៃពួកគាត់ត្រូវបានដំឡើងឋានៈតាមរយៈស្នាដៃការងារ និងមួយចំនួនទៀតត្រូវបានជ្រើសរើសពីខាងក្រៅ ដើម្បីបំពេញតម្រូវការរបស់ស្ថាប័ន។ បុគ្គលិកគ្រប់គ្រងបានបញ្ចប់ បរិញ្ញាបត្រជាន់ខ្ពស់ និង មានបទពិសោធន៍យូរឆ្នាំជាមួយវិស័យហិរញ្ញវត្ថុ។ ប្រធានសាខាភាគច្រើនពួកគាត់បានបញ្ចប់បរិញ្ញាបត្រផ្នែករដ្ឋបាលអាជីវកម្ម ដែលស្របគ្នាជាមួយនាយកសាខាខេត្ត និងបុគ្គលិកគ្រប់គ្រងត្រូវបំពេញថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែករដ្ឋបាលអាជីវកម្ម ដែលជាតម្រូវការរបស់ស្ថាប័ន។ ក្រុមបុគ្គលិកសវនកម្មផ្ទៃក្នុងគឺ ឋិតក្រោមការគ្រប់គ្រងផ្ទាល់របស់ប្រធានគណៈកម្មការសវនកម្ម។ បុគ្គលិកសវនកម្មផ្ទៃក្នុងត្រូវធ្វើរបាយការណ៍ផ្ទាល់ជូនគណៈកម្មការសវនកម្ម។

តារាងទី១ ទំហំទុននៃភាគទុនិកនីមួយៗដូចខាងក្រោមៈ

| ភាគទុនិក | ចំនួនភាគហ៊ុន | ភាគរយ (%) | តម្លៃចរិក 1,360,000/១ហ៊ុន(000) រៀល |
|---|---|---|---|
| Advans Luxembourg | **4,416** | **52.78%** | **6,005,760** |
| IFC Member of the World Bank | **1,673** | **19.99%** | **2,275,280** |
| FMO Netherlands | **1,673** | **19.99%** | **2,275,280** |
| LFP French Invest. Co. | **340** | **4.06%** | **462,400** |
| Botta Cambodia | **265** | **3.17%** | **360,400** |
| **Total** | **8,367** | **100%** | **11,379,120** |

### ២.៩.២.ប្រភពហិរញ្ញវត្ថុ

មូលនិធិទុនបម្រុងបានបង្កើតឡើងចាប់តាំងពីឆ្នាំ ១៩៩៨ ដោយបូកបន្ថែមប្រាក់ចំណេញរក្សាទុក ដែលចេះតែកើនឡើងរហូតដល់ ៣០៦,៥៨០ លានរៀល។ ប្រភពហិរញ្ញវត្ថុបានពីម្ចាស់បំណុលមួយចំនួនដូចខាងក្រោម៖

តារាងទី២ : ប្រភពហិរញ្ញវត្ថុរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

| ម្ចាស់មូលធន | ចំនួនទឹកប្រាក់ (លានរៀល) |
|---|---|
| UNICEP | 215,410 |
| UNDP | 205,580 |
| AFD | 2,502,000 |
| USAID | 572,235 |
| MAF | 514,400 |
| CGAP | 75,000 |
| AFD (For MIS) | 49,686 |

## ២.៦. រចនាសម្ព័ន្ធគ្រប់គ្រងរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត សាខាស្រុកបាភ្នំ



## ២.៧. ទស្សនៈវិស័យ បេសកកម្ម និងវប្បធម៌រួម

### ២.៧.១. ទស្សនៈវិស័យ

ជាស្ថាប័នហិរញ្ញវត្ថុឈានមុខ ដែលរួមចំណែកក្នុងការកែលម្អជីវភាពប្រជាពលរដ្ឋឲ្យល្អប្រសើរ និងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកម្ពុជា។

### ២.៧.២. បេសកកម្ម

ផ្តល់សេវាកម្មហិរញ្ញវត្ថុជាច្រើនប្រភេទដល់ប្រជាពលរដ្ឋ ដែលមានប្រាក់ចំណូលទាប និងសហគ្រាសខ្នាតតូចបំផុត តូច និង មធ្យមដោយធានាបាននូវលទ្ធផលប្រតិបត្តិការកម្រិតខ្ពស់ ផ្នែកហិរញ្ញវត្ថុ និងសង្គម។ អម្រឹតប្រកាន់ខ្ជាប់ជានិច្ចនូវគោលការណ៍សីលធម៌វិជ្ជាជីវៈ សង្គមច្បាប់ និងបរិស្ថាន ប្រកបដោយកម្រិតខ្ពស់។

### ២.៧.៣. វប្បធម៌រួម

វប្បធម៌រួមរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត គឺជំនឿ តម្លៃ និងទម្លាប់ដែលកំណត់ឡើងដោយគ្រឹះស្ថាន ហើយត្រូវបានបុគ្គលិកយល់ថាគួរតែគោរព និងអនុវត្តន៍តាមៈ

- ភាពស្មោះត្រង់ : ជាតម្រូវការចាំបាច់របស់អម្រឹត
- ទំនាក់ទំនងល្អ : ប្រកបដោយសេចក្តីថ្លៃថ្នូររវាងបុគ្គលិក និងផ្នែកខាងក្រៅ
- មានការលះបង់ខ្ពស់ចំពោះការងារ : ជាគុណសម្បត្តិដ៏ធំមួយរបស់បុគ្គលិកឆ្នើម
- មានតម្លាភាព : ធ្វើឲ្យមានការទុកចិត្តគ្នា
- ការសម្រេចចិត្ត : ភាគច្រើនត្រូវធ្វើឡើងតាមរយៈការចូលរួមយោបល់
- ភាពទៀងទាត់ និងម៉ឺងម៉ាត់ : ជាជំហររបស់បុគ្គលិក
- មិនបក្សពួកនិយម ឬគ្រួសារនិយម : ធ្វើឲ្យមានល្បាយស្មើភាពគ្នាក្នុងស្ថាប័ន
- សីលធម៌រស់នៅល្អ : នាំមកនូវសេចក្តីថ្លៃថ្នូរ
- សមត្ថភាព និងគុណភាពក្នុងការងារ គឺការបង្ហាញស្នាដៃរបស់បុគ្គលិក
- សន្សំសំចៃ និងរក្សាសម្បត្តិរួម : ជាការរួមចំណែកកាត់បន្ថយចំណាយ
- មិនប្រកាន់ខ្លួន និងមើលបំណាំគ្នា : ជាកត្តាធានាសន្ទុះការងារ។

## ២.៨. ផលិតផល និងសេវាកម្មទូទៅរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត

១. ផលិតផលឥណទាន

ក. ឥណទានក្រុមធានា

ខ. ឥណទានបុគ្គល

- ឥណទានអាជីវកម្ម

- ឥណទានកែលម្អគេហដ្ឋាន
- ឥណទានសម្ភារៈប្រើប្រាស់
- ឥណទានឡជីវឧស្ម័ន
- ឥណទានកសិកម្ម
- ឥណទានសហគ្រាសខ្នាតតូច និងមធ្យម

២. ផលិតផលប្រាក់បញ្ញើ

- គណនីរីកវាយ
- គណនីប្រាថ្នា
- គណនីកើនទ្រព្យ
- គណនីពាណិជ្ជ

៣. ផលិតផលផ្ទេរប្រាក់រវាងសាខា

៤. សេវាទូទាត់វិក្កយប័ត្រ

៥. សេវាកម្មសន្សំចល័ត

# ជំពូកទី៣

# ឥណទានខ្នាតតូច និងខ្នាតមធ្យមរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត សាខាស្រុកបាត់

## ៣.១. ទីផ្សារគោលដៅសម្រាប់ឥណទានខ្នាតតូច និងខ្នាតមធ្យម

ផលិតផលនេះត្រូវបានយកចិត្តទុកដាក់ ជាពិសេសសម្រាប់បម្រើតម្រូវការទីផ្សារ ទៅតាមកម្រិតដែលអាចទទួលយកបានរបស់អតិថិជនគ្រប់រូបនៅកម្ពុជា នៅទីជនបទ ទីប្រជុំជន ទីក្រុង និងតំបន់នានាទៀតនៅក្នុងប្រទេសកម្ពុជា។ ទីផ្សារគោលដៅរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គឺប្រជាជនកម្ពុជាគ្រប់រូប ដែលស្ថិតក្នុងសហគមន៍សេដ្ឋកិច្ចចាប់ពីកម្រិតទាបបំផុតឡើងទៅ លក្ខណៈជាគ្រួសារ (ឯកត្តជន) ឬចងក្រងជាក្រុមដែលសកម្មភាពមុខរបរអនុលោមទៅតាមលក្ខណៈវិនិច្ឆ័យរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

ក្រុមគោលដៅសម្រាប់ទីផ្សារឥណទានខ្នាតតូច និងមធ្យមរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត៖

- មុខរបរមានទីតាំងនៅព្រះរាជាណាចក្រកម្ពុជា ដែលមានស្ថានភាពល្អនៅក្នុងទីផ្សារ ហើយមុខរបរមានសក្តានុពល
- មានកេរ្តិ៍ឈ្មោះ និងមានទំនាក់ទំនងល្អ
- សកម្មភាពមុខរបរស្របច្បាប់
- លំហូរសាច់ប្រាក់មានស្ថេរភាព

## ៣.២. ឥណទានខ្នាតតូច និងខ្នាតមធ្យម

ឥណទានខ្នាតតូច និងខ្នាតមធ្យម គឺជាប្រភេទសេវាប្រាក់កម្ចី ដែលផ្តល់ជូនលក្ខណៈបុគ្គលទៅដល់ម្ចាស់សហគ្រាសខ្នាតតូច និងមធ្យម (សហគ្រាសជំនួញ ផលិតកម្មសេវាកម្ម និងកសិកម្ម) ដែលមានបំណងប្រើប្រាស់ឥណទាននេះសម្រាប់ធ្វើជាទុនវិនិយោគ ឬជាទុនបង្វិល ក្នុងការបង្កើតអាជីវកម្មថ្មី ឬពង្រីកអាជីវកម្មរបស់ខ្លួនដែលមានស្រាប់។

### ៣.២.១. ផលិតផលឥណទានខ្នាតតូច

#### ៣.២.១.១. ទំហំឥណទាន

ឥណទានខ្នាតតូច សម្រាប់ឥណទានទោលដែលមានទំហំដូចខាងក្រោម៖

- ឥណទានជាប្រាក់រៀល : ទំហំប្រាក់ខ្ចីចាប់ពី ៤០០,០០០រៀល ដល់ ៨,០០០,០០០ រៀល។

- ឥណទានជាប្រាក់ដុល្លារអាមេរិច : ទំហំប្រាក់ខ្ចីចាប់ពី ១០០ដុល្លារ ដល់ ២,០០០ ដុល្លារ។

ឥណទានខ្នាតតូច សម្រាប់ឥណទានក្រុមដែលមានទំហំដូចខាងក្រោម៖

- ឥណទានជាប្រាក់រៀល : ទំហំប្រាក់ខ្ចីចាប់ពី ១០០,០០០ រៀល ដល់ ២,២០០,០០០ រៀល។
- ឥណទានជាប្រាក់ដុល្លារអាមេរិច : ទំហំប្រាក់កម្ចីចាប់ពី ២៥ ដុល្លារ ដល់ ៥៥០ ដុល្លារអាមេរិច។

**៣.២.១.២. ការកំណត់ថ្លៃ**

**ក.អត្រាការប្រាក់**

អត្រាការប្រាក់ត្រូវបានកំណត់ទៅតាមទំហំឥណទាន និងប្រភេទផលិតផលឥណទាន។

➢ **ឥណទានជាប្រាក់រៀល**

- អត្រាការប្រាក់ចន្លោះពី ២.៤% ទៅ ១.៩% ក្នុងមួយខែលើសមតុល្យឥណទាន សម្រាប់ឥណទានដែលមានទំហំពី ៥០០,០០០រៀល ដល់ ១,២០០,០០០រៀល។
- អត្រាការប្រាក់ចន្លោះពី ១.៩% ទៅ ១.៧% ក្នុងមួយខែលើសមតុល្យឥណទាន សម្រាប់ឥណទានដែលមានទំហំពី ១,២០០,១០០រៀល ដល់ ៤,០០០,០០០រៀល។
- អត្រាការប្រាក់ចន្លោះពី ១.៧% ទៅ ១.៥% ក្នុងមួយខែលើសមតុល្យឥណទាន សម្រាប់ឥណទានដែលមានទំហំពី ៤,០០០,១០០រៀល ដល់ ៨,០០០,០០០រៀល។

➢ **ឥណទានជាប្រាក់ដុល្លា**

- អត្រាការប្រាក់ចន្លោះពី ២.៤% ទៅ ១.៩% ក្នុងមួយខែលើសមតុល្យឥណទាន សម្រាប់ឥណទានដែលមានទំហំពី ១០០ដុល្លារ ដល់ ៣,០០០ដុល្លារ។
- អត្រាការប្រាក់ចន្លោះពី ១.៩% ទៅ ១.៧% ក្នុងមួយខែលើសមតុល្យឥណទាន សម្រាប់ឥណទានដែលមានទំហំពី ៣,០០១ដុល្លារ ដល់១,០០០ដុល្លារ ។
- អត្រាការប្រាក់ចន្លោះពី ១.៧% ទៅ ១.៥% ក្នុងមួយខែលើសមតុល្យឥណទាន សម្រាប់ឥណទានដែលមានទំហំពី ១,០០១ដុល្លារ ដល់ ២,០០០ដុល្លារ។

**ខ. រយៈពេលខ្ចី**

រយៈពេលខ្ចីនៃឥណទាន ប្រែប្រួលទៅតាមទំហំប្រាក់កម្ចីដែលអតិថិជនបានខ្ចី។

➢ **ឥណទានជាប្រាក់រៀល**

- រយៈពេលខ្ចីអតិបរមា ២៤ខែ សម្រាប់ឥណទាន ដែលមានទំហំរហូតដល់ ៤,០០០,០០០រៀល។
- រយៈពេលខ្ចីអតិបរមា ៣៦ខែ សម្រាប់ឥណទាន ដែលមានទំហំរហូតដល់ ២០,០០០,០០០រៀល។
- រយៈពេលខ្ចីអតិបរមា ៤៨ខែ សម្រាប់ឥណទាន ដែលមានទំហំរហូតដល់ ៨០,០០០,០០០រៀល។

➢ **ឥណទានជាប្រាក់ដុល្លារ**

- រយៈពេលខ្ចីអតិបរមា ២៤ខែ សម្រាប់ឥណទាន ដែលមានទំហំរហូតដល់ ២,០០០ ដុល្លារ។
- រយៈពេលខ្ចីអតិបរមា ៣៦ខែ សម្រាប់ឥណទាន ដែលមានទំហំរហូតដល់ ៥,០០០ ដុល្លារ។
- រយៈពេលខ្ចីអតិបរមា ៤៨ខែ សម្រាប់ឥណទាន ដែលមានទំហំរហូតដល់២០,០០០ ដុល្លារ។

### ៣.២.២. ផលិតផលឥណទានខ្នាតមធ្យម

#### ៣.២.២.១. ទំហំឥណទាន

ចំពោះឥណទានខ្នាតមធ្យម គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹតផ្តល់ជូនអតិថិជនតែជាប្រាក់ដុល្លារ។ អម្រឹតផ្តល់ជូនចំពោះអតិថិជននូវទំហំឥណទានចាប់ពី ២០,០០០ដុល្លារ រហូតដល់ ៧០,០០០ដុល្លារ។

#### ៣.២.២.២. ការកំណត់ថ្លៃ

**ក. អត្រាការប្រាក់**

- អត្រាការប្រាក់ចន្លោះពី ១.៤% ក្នុងមួយខែលើសមតុល្យឥណទានសម្រាប់ឥណទាន ដែលមានទំហំពី ២០,០០០ដុល្លារ ដល់ ៥០,០០០ដុល្លារ។
- អត្រាការប្រាក់ចន្លោះពី ១.២% ក្នុងមួយខែលើសមតុល្យឥណទានសម្រាប់ឥណទានដែលមានទំហំពី ៥០,០០១ដុល្លារ ដល់ ៧០,០០០ដុល្លារ។

**ខ. រយៈពេលខ្ចី**

ចំពោះរយៈពេលខ្ចី គ្រឹះស្ថានផ្តល់ជូនរយៈពេលអតិបរមា ៥ឆ្នាំ គ្រប់ទំហំឥណទាន

#### ៣.២.៣. ការផ្លាស់ប្តូរអត្រាការប្រាក់លើឥណទាន

នាពេលបច្ចុប្បន្នរដ្ឋាភិបាលបានតម្រូវឲ្យគ្រប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជាយកអត្រាការប្រាក់ខ្ពស់បំផុតត្រឹម ១៨% ក្នុងមួយឆ្នាំ។ ដូច្នេះហើយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹតកំណត់យកអត្រាការប្រាក់ពីអតិថិជនត្រឹម ១.៥%ក្នុងមួយខែ លើគ្រប់ទំហំឥណទានទាំងអស់ ដែលចាប់ផ្តើម អនុវត្តពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៧។

### ៣.៣. ការកំណត់ទំហំឥណទាន និងថ្លៃសេវា

#### ៣.៣.១. ការកំណត់ទំហំឥណទាន

ការកំណត់ទំហំឥណទានត្រូវផ្អែកទៅលើទ្រព្យធានា និងលទ្ធផលសង។ ទ្រព្យធានាមានដូចជា ប្លង់ដី ផ្ទះ និងអាគារជាដើម ហើយលទ្ធភាពសងវិញ គឺពិនិត្យលើស្ថានភាពហិរញ្ញវត្ថុរបស់អតិថិជនដែលផ្អែកលើសកម្មភាពជំនួញ សមត្ថភាព ជំនាញ ភាពប៉ិនប្រសប់ ការទទួលខុសត្រូវ និងហានិភ័យដែលអាចជួបប្រទះ។

#### ៣.៣.២. ថ្លៃសេវា

- អតិថិជនត្រូវបង់សេវាពត៌មាន CBC ( CREDIT BRUEAU CAMBODIA ) នូវពេលដែលអតិថិជនត្រូវបានអនុម័តថាអាចទទួលបានឥណទាន។ សេវានេះគិតទៅតាមទំហំឥណទាន និងអតិថិជនដូចខាងក្រោម៖
  - កម្ចីចាប់ពី ៥០០ដុល្លារ ដល់ ១០,០០០ដុល្លារ គិតថ្លៃចំពោះ
    - អ្នកខ្ចី ២.៥ ដុល្លារ
    - អ្នករួមខ្ចី និងអ្នកធានា ០.១៨ ដុល្លារ
  - កម្ចីចាប់ពី ១០,០០១ដុល្លា ដល់ ៧០,០០០ ដុល្លារ គិតថ្លៃចំពោះអ្នកខ្ចី អ្នករួមខ្ចី និងអ្នកធានាដូចគ្នាគឺ ៣.៥ ដុល្លារ
- ក្នុងករណីដែលអតិថិជនសម្រេចយកអត្រាការប្រាក់ទាបជាងអត្រាកំណត់អតិថិជនត្រូវបង់ថ្លៃសេវាប្រតិបត្តិការ ១% លើទំហំឥណទានសរុប។

### ៣.៤. ការគ្រប់គ្រងឥណទានខ្នាតតូច និងមធ្យម

#### ៣.៤.១. ការវាយតម្លៃក្នុងការផ្តល់ឥណទាន

មុននឹងសម្រេចផ្តល់ឥណទានដល់អតិថិជន មន្ត្រីឥណទានត្រូវធ្វើការវាយតម្លៃទៅលើ៖

##### ៣.៤.១.១. អត្តចរិតរបស់អតិថិជន

អត្តចរិតរបស់អតិថិជន គឺសំដៅទៅលើថា តើអ្នកស្នើសុំខ្ចីជាអតិថិជនប្រភេទណា? ជាប្រភេទខ្ចីស្រួលសងពិបាក ឬក៏អត់ ដោយមើលទៅលើអាកប្បកិរិយា ការគិត សកម្មភាព ភាពស្មោះ

ត្រង់ និងការទទួលខុសត្រូវរបស់អតិថិជនព្រោះវាជាកត្តាដ៏ចម្បង និងសំខាន់ក្នុងការធ្វើឲ្យមានគុណភាពនៃប្រាក់កម្ចី។

#### ៣.៤.១.២. ដើមទុន

ដើមទុន សំដៅទៅលើដើមទុនផ្ទាល់ខ្លួនរបស់អតិថិជន ក្នុងការចូលរួមគម្រោងវិនិយោគ។ ជាទូទៅគ្រឹះស្ថានតែងតម្រូវឲ្យអតិថិជនត្រូវមានសាច់ប្រាក់ផ្ទាល់ខ្លួន ដើម្បីចូលរួមក្នុងគម្រោងវិនិយោគយ៉ាងហោចណាស់៣០%នៃទុនវិនិយោគទាំងអស់។

#### ៣.៤.១.៣. សមត្ថភាពសង

សមត្ថភាពសង វាយតម្លៃលំហូរសាច់ប្រាក់របស់អតិថិជន ប្រាក់ចំណូលពីមុខរបរនិង ប្រភពចំណូលផ្សេងៗ ដើម្បីធ្វើការប៉ាន់ស្មានតម្រូវការឥណទាន រយៈពេលឥណទាន និងលទ្ធភាពសងប្រាក់។

#### ៣.៤.១.៤. ទ្រព្យធានា

ទ្រព្យធានា គឺជាទ្រព្យសម្បត្តិផ្សេងៗដូចជា ដី ផ្ទះ ដែលតម្រូវសម្រាប់ដាក់ជាទ្រព្យបំណុលឲ្យទៅគ្រឹះស្ថាន។ ជាទូទៅគ្រឹះស្ថានតម្រូវឲ្យអតិថិជន ត្រូវមានទ្រព្យធានាយ៉ាងហោចណាស់ ១៥០%នៃកម្ចី។

#### ៣.៤.១.៥. លក្ខខណ្ឌ

លក្ខខណ្ឌ ជាកត្តាផ្សេងៗដែលអាចជះឥទ្ធិពលដល់អាជីវកម្ម ចរិក លទ្ធភាពសងរបស់អតិថិជនជាដើម។

### ៣.៤.២. នីតិវិធីក្នុងការផ្តល់ឥណទាន

នីតិវិធីក្នុងការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត សាខាស្រុកបាភ្នំមានដូចខាងក្រោម៖

#### ៣.៤.២.១. ការដាក់ពាក្យសុំចុះឈ្មោះខ្ចីប្រាក់

ជាដំបូង អ្នកដាក់ពាក្យសុំខ្ចីប្រាក់ត្រូវមកជួបភ្នាក់ងារបម្រើអតិថិជន (Customer Service) នៅតាមសាខាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត ដើម្បីឲ្យភ្នាក់ងារបម្រើអតិថិជន ធ្វើការពន្យល់ពីគោលការណ៍ នីតិវិធីឥណទាន និងលក្ខខណ្ឌរួមស្តីពីការខ្ចីប្រាក់ឲ្យបានច្បាស់លាស់ ទៅអ្នកចុះឈ្មោះសុំខ្ចីប្រាក់រួមមាន ទំហំរបស់ឥណទាន របៀបសង អត្រាការប្រាក់ អ្នកធានា រួចផ្តល់ពាក្យសុំខ្ចីនិងជម្រាបជូនអតិថិជនស្តីពីលិខិតស្នាមចាំបាច់ដែលជាតម្រូវការរបស់គ្រឹះស្ថាន។

ក្រោយពីទទួលពាក្យសុំខ្ចីប្រាក់ ដែលបានបំពេញបានត្រឹមត្រូវដោយអតិថិជន ភ្នាក់ងារបម្រើអតិថិជនត្រូវប្រមូលឯកសារ ដែលបាននោះដាក់ក្នុងប្រអប់ឯកសាររបស់ភ្នាក់ងារឥណទានទទួល

ខុសត្រូវ។ គួរកត់សម្គាល់ផងដែលថា អ្នកស្នើសុំខ្ចីប្រាក់អាចទំនាក់ទំនងដាក់ពាក្យជាមួយភ្នាក់ងារឥណទានក្នុងពេលដែល ភ្នាក់ងារឥណទានចុះធ្វើការនៅតាមមូលដ្ឋាន។

### ៣.៤.២.២. ការចុះទៅពិនិត្យដល់ផ្ទះអតិថិជន និងការវាយតម្លៃឥណទាន

ការចុះទៅពិនិត្យដល់ផ្ទះអតិថិជន ធ្វើឡើងក្រោយពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលបានពាក្យសុំចុះឈ្មោះខ្ចីប្រាក់របស់អតិថិជន។ ភ្នាក់ងារឥណទានត្រូវចុះទៅជួបអតិថិជនដល់ទីលំនៅ និងអ្នករួមខ្ចី ដើម្បីសាកសួរព័ត៌មានតម្រូវការខ្ចីប្រាក់។ នៅពេលសាកសួរ ភ្នាក់ងារឥណទានរបស់គ្រឹះស្ថានត្រូវយកចិត្តទុកដាក់ផ្តោតអារម្មណ៍ក្នុងការសាកសួរប្រមូលព័ត៌មានពីអ្នកខ្ចី ដែលទាក់ទងនឹងព័ត៌មានទូទៅ ព័ត៌មានហិរញ្ញវត្ថុ គោលបំណង និងតម្រូវការនៃការប្រើប្រាស់ប្រាក់កម្ចី កិច្ចសន្យាដាក់ធានា សាកសួរអំពីកត្តាទាំងឡាយ ដែលអាចជះឥទ្ធិពលបង្កហានិភ័យ។ ភ្នាក់ងារឥណទានក៏ត្រូវពន្យល់ឲ្យបានច្បាស់លាស់ពីគោលការណ៍ និង នីតិវិធីឥណទាន ដោយរាប់បញ្ចូលទាំងកិច្ចសន្យាខ្ចីប្រាក់ កិច្ចសន្យាធានា ឬកិច្ចសន្យាព្រមព្រៀងធានា។

ភ្នាក់ងារឥណទានត្រូវធ្វើការត្រិះរិះពិចារណា សិក្សាវិភាគ និងវាយតម្លៃព័ត៌មានដែលប្រមូលបានទាំងនោះ ថាតើពិតជាត្រឹមត្រូវ សម្រាប់ធ្វើការវាយតម្លៃឥណទានហើយឬនៅ? ករណីដែលអតិថិជនផ្តល់ព័ត៌មានមិនគ្រប់គ្រាន់ ភ្នាក់ងារឥណទាន អាចចុះស្រាវជ្រាវប្រមូលព័ត៌មានបន្ថែមពីខាងក្រៅ ឬពីអាជ្ញាធរមូលដ្ឋានផងដែរ ប៉ុន្តែត្រូវរក្សាអាថ៌កំបាំងវិជ្ជាជីវៈ ជៀសវាងការបង្កឲ្យកើតមានផលមិនល្អ។ ក្រោយពីធ្វើការវាយតម្លៃលទ្ធភាពរបស់អ្នកខ្ចីប្រាក់រួច ភ្នាក់ងារឥណទានត្រូវតែបញ្ជាក់ជូនអតិថិជនអំពីលទ្ធភាព ដែលអាចទទួលឥណទានបាន លក្ខខណ្ឌឥណទាននិងបណ្តុះវិន័យឥណទាន។

### ៣.៤.២.៣. ការរៀបចំឯកសារខ្ចីប្រាក់

ការរៀបចំឯកសារខ្ចីប្រាក់អាចប្រព្រឹត្តទៅបានបន្ទាប់ពីមានការព្រមព្រៀងពីអតិថិជន។ ភ្នាក់ងារឥណទានត្រូវរៀបចំឯកសារសម្រាប់អតិថិជនខ្ចីប្រាក់ក្នុងនោះរួមមាន ទម្រង់សម្ភាសន៍ កំណត់ហេតុវាយតម្លៃទ្រព្យសម្បត្តិដាក់ធានា គម្រោងជំនួញ និងឲ្យអតិថិជនដាក់ពាក្យសុំខ្ចីប្រាក់។ ភ្នាក់ងារឥណទានអាចសរសេរយោបល់ និងសំណើរបស់ខ្លួនដើម្បីស្នើសុំការអនុម័ត ប្រសិនបើអ្នកខ្ចី អ្នករួមខ្ចី ឬអ្នកធានាយល់ព្រមដាក់ទ្រព្យធានារបស់ពួកគេធានាប្រាក់កម្ចី ដែលទ្រព្យសម្បត្តិទាំងនោះត្រូវបានឆ្លុះបញ្ចាំងក្នុងគម្រោងជំនួញ។

### ៣.៤.២.៤. ការអនុម័តឥណទាន

ឥណទានដែលអនុម័តត្រូវតែមានយោបល់ និងសំណើរពីភ្នាក់ងារឥណទានទទួលខុសត្រូវ មានសេចក្តីបញ្ជាក់ពីប្រធានការិយាល័យស្រុក ខណ្ឌ ឬភ្នាក់ងារឥណទាន និងពីនាយក នាយិការ

គ្រឹះស្ថានលើពាក្យសុំខ្ចីប្រាក់រួមជាមួយគម្រោងជំនួញ និងឯកសារសម្គាល់របស់អតិថិជនខ្លះទៀត ផ្ញើទៅនាយកដ្ឋានឥណទាន។ ក្រោយពីត្រួតពិនិត្យហើយ នាយកដ្ឋានឥណទានដាក់សំណើសុំឥណទានជូននាយកប្រតិបត្តិឥណទានដើម្បីពិនិត្យ និងបញ្ជូនទៅគណៈកម្មាធិការឥណទាន។

### ៣.៤.២.៥. ការរៀបចំកិច្ចសន្យា

ភ្នាក់ងារឥណទាន ត្រូវទៅជួបអ្នកដាក់ពាក្យខ្ចីដល់ផ្ទះម្តងទៀត បន្ទាប់ពីឥណទានបានអនុម័តហើយ ដើម្បីរៀបចំកិច្ចសន្យាក្នុងនោះមាន កិច្ចសន្យាបរិភោគ កិច្ចសន្យាដាក់ទ្រព្យធានា និងលិខិតផ្សេងៗទៀតដែលទាក់ទង។ ភ្នាក់ងារឥណទានត្រូវទទួលខុសត្រូវលើការរៀបចំឯកសារទាំងអស់។ បន្ទាប់ពីមានការព្រមព្រៀងហើយអតិថិជន និងអ្នកដែលទាក់ទងទាំងអស់ត្រូវផ្តិតមេដៃ ឬចុះហត្ថលេខានៅចំពោះមុខភ្នាក់ងារឥណទាន។ ចំពោះឯកសារណាដែលត្រូវបញ្ជាក់ពីអាជ្ញាធរ អតិថិ-ជនត្រូវរត់ការសុំបញ្ជាក់ ចុះហត្ថលេខា និងបោះត្រាពីអាជ្ញាធរដោយខ្លួនឯង។ ក្រោយពីឯកសារទាំងអស់នោះបានបំពេញត្រឹមត្រូវគ្រប់គ្រាន់ និងបានចុះហត្ថលេខាបញ្ជាក់ចប់សព្វគ្រប់រួចរាល់ហើយ ភ្នាក់ងារឥណទានត្រូវយកឯកសារទាំងនោះមកការិយាល័យ ហើយប្រគល់ទៅឲ្យប្រធានភ្នាក់ងារឥណទាន។

### ៣.៤.២.៦. ការបញ្ចេញឥណទាន

គ្រប់ឯកសារទាំងអស់ដែលទាក់ទងនឹងការគ្រប់គ្រងឥណទាន ត្រូវតែរៀបចំឲ្យបានគ្រប់គ្រាន់ និងត្រឹមត្រូវសិនមុនពេលដែលបញ្ចេញឥណទាន រួចត្រូវបញ្ជូនទៅឲ្យបេឡាធិការរៀបចំប្រាក់ ហើយរងចាំអតិថិជនមកបើកប្រាក់។ អតិថិជនត្រូវមកជួបបេឡាធិការដើម្បីបើកប្រាក់។ មុនពេលបើកប្រាក់បេឡាធិការត្រូវរំលឹកអតិថិជនឡើងវិញ អំពីគោលការណ៍សំខាន់ៗដូចជា របៀបសងប្រាក់ និងការពិន័យលើការសងយឺតយ៉ាវ និងប្រាប់អតិថិជនពីច្បាប់នៃការគ្រប់គ្រងទទួលប្រាក់ដូចជា អតិថិជនត្រូវពិនិត្យ និងរាប់ប្រាក់ឲ្យបានត្រឹមត្រូវមុនពេលចាកចេញ។ អតិថិជនត្រូវផ្តិតមេដៃលើលិខិតដកប្រាក់ទើបអាចទទួលប្រាក់បាន។

## ៣.៤.៣. លក្ខខណ្ឌក្នុងការផ្តល់ឥណទាន

ដើម្បីអាចដាក់ពាក្យស្នើរសុំឥណទានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹតបានអតិថិជនត្រូវមានលក្ខខណ្ឌដូចខាងក្រោមៈ

- ត្រូវមានទីលំនៅពិតប្រាកដនៅកន្លែងដែលអម្រឹតធ្វើប្រតិបត្តិការ
- មានអាយុចាប់ពី ១៨ ដល់ ៦២ឆ្នាំ
- មានស្ថានភាពសុខភាពល្អ
- មានទ្រព្យធានា

- មានអាជីវកម្ម ឬមុខរបរច្បាស់លាស់
- អ្នករួមខ្ចី
- មានសាក្សី
- មានអ្នកធានា
- មានឯកសារផ្លូវការ
- ស្ថានភាពគ្រួសារល្អ
- មិនស្ថិតនៅក្នុងបញ្ជីបដិសេធ។

### ៣.៤.៤. ការសងត្រលប់មកវិញនៃឥណទាន

#### ៣.៤.៤.១. ការគណនាការប្រាក់

ក. រូបមន្តគ្រឹះសម្រាប់គណនាការប្រាក់សាមញ្ញគឺ

$$I = (P \times r \times t)$$

- I = ការប្រាក់
- P = ចំនួនទឹកប្រាក់ដើមជាក់ស្តែង
- r = អត្រាការប្រាក់គិតក្នុងមួយគ្រា
- t = ចំនួនគ្រាដែលត្រូវគិតការប្រាក់

**ឧទាហរណ៍** : លោក A បានខ្ចីប្រាក់ពីគ្រឹះស្ថានចំនួន ១,០០០,០០០ រៀល សម្រាប់រយៈពេល ១ឆ្នាំ ដោយគិតអត្រាការប្រាក់ ១.៥% ក្នុងមួយខែ។ តើលោកត្រូវបង់ការប្រាក់សរុបប៉ុន្មាន?

**ដំណោះស្រាយ**

តាមរូបមន្ត $I = (P \times r \times t)$

នាំឲ្យការប្រាក់សរុប = ១,០០០,០០០×១.៥%×១២

=

១៨០,០០០ រៀល

ខ. រូបមន្តគណនាការប្រាក់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

$$I = (P \times r \times t)\frac{12}{365}$$

- I = ការប្រាក់
- P = ចំនួនទឹកប្រាក់ដើមជាក់ស្តែង
- r = អត្រាការប្រាក់គិតក្នុងមួយគ្រា

- t = ចំនួនគ្រាដែលត្រូវគិតការប្រាក់

### ៣.៤.៤.២. របៀបសងប្រាក់

ការសងត្រឡប់មកវិញនៃឥណទានត្រូវបានអនុវត្តទៅតាមតារាងកាលវិភាគសងប្រាក់ដែលបានចែងក្នុងកិច្ចសន្យាខ្ចីប្រាក់។ អម្រឹតផ្តល់ជូនអតិថិជនរបស់ខ្លួននូវជម្រើស ៣ ក្នុងការសងប្រាក់ដែលមានដូចជា៖

- **សងការប្រាក់ និងប្រាក់ដើមរំលស់រៀងរាល់ខែ** គឺជារបៀបសងប្រាក់មួយប្រភេទដែលអតិថិ-ជនត្រូវបង់ចំនួនទឹកប្រាក់ថេរប្រចាំគ្រា ដែលក្នុងនោះរួមមានប្រាក់ដើមដែលបានរំលស់ និងការប្រាក់ដែលត្រូវបង់។

**ឧទាហរណ៍** : លោក សុខបានខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួន $3,000 ក្នុងអត្រាការប្រាក់ 2.5% ក្នុងមួយខែ សម្រាប់រយៈពេល ១ឆ្នាំ។ ចូរធ្វើតារាងសងរំលស់ ការប្រាក់ និងប្រាក់ដើមរំលស់រៀងរាល់ខែ។

**ដំណោះស្រាយ**

បម្រាប់ : (r) អត្រាការប្រាក់ ២.៥% ក្នុង១ខែ

(t) រយៈពេលខ្ចី ១ឆ្នាំ (១២ខែ)

(P) ប្រាក់ដែលខ្ចី $៣,០០០

- រកប្រាក់ដែលត្រូវបង់ក្នុងមួយខែៗ

តាមរូបមន្ត

$$C = \frac{P}{\left[\frac{1-\frac{1}{(1-r)^t}}{r}\right]}$$

$$C = \frac{3,000}{\left[\frac{1-\frac{1}{(1+0.025)^{12}}}{0.025}\right]} = 292.46$$

- ការប្រាក់ត្រូវបង់ក្នុងខែទីមួយ

តាមរូបមន្ត $I = (P \times r \times t)$

$I = (3,000 \times 0.025 \times 1) = 75$

⇨ ប្រាក់ដើមដែលបានរំលស់ក្នុងខែទី ១ = 292.46 – 75 = 217.46

- ការប្រាក់ត្រូវបង់ក្នុងខែទី២

$I = (3,000 - 217.46) \times 0.025 = 69.56$

**តារាងទី៤ :** តារាងបង់រំលស់ ការប្រាក់ និងប្រាក់ដើមរំលស់រៀងរាល់ខែ

| ចំនួនខែ | ប្រាក់ដើមដែលជំពាក់ | ប្រាក់ដើមត្រូវសង | ការប្រាក់ត្រូវសង | ប្រាក់សរុបត្រូវសង | សមតុល្យចុងគ្រា |
|---|---|---|---|---|---|
| 1 | 3,000.00 | 217.46 | 75.00 | 292.46 | 2,782.54 |
| 2 | 2,782.54 | 222.90 | 69.56 | 292.46 | 2,559.64 |
| 3 | 2,559.64 | 228.47 | 63.99 | 292.46 | 2,331.17 |
| 4 | 2,331.17 | 234.18 | 58.28 | 292.46 | 2,096.99 |
| 5 | 2,096.99 | 240.04 | 52.42 | 292.46 | 1,856.96 |
| 6 | 1,856.96 | 246.04 | 46.42 | 292.46 | 1,610.92 |
| 7 | 1,610.92 | 252.19 | 40.27 | 292.46 | 1,358.74 |
| 8 | 1,358.74 | 258.49 | 33.97 | 292.46 | 1,100.24 |
| 9 | 1,100.24 | 264.95 | 27.51 | 292.46 | 835.29 |
| 10 | 835.29 | 271.58 | 20.88 | 292.46 | 563.71 |
| 11 | 563.71 | 278.37 | 14.09 | 292.46 | 285.35 |
| 12 | 285.35 | 285.33 | 7.13 | 292.46 | 0.00 |
| សរុប | | 3,000 | 509.52 | 3509.52 | |

- **រំលស់ដើមថេរ** គឺជារបៀបសងប្រាក់មួយប្រភេទ ដែលបង្កើតឡើងសម្រាប់ផ្តល់ជូនអតិថិជនដែលជាពាណិជ្ជករ អាជីវករ និយោជិកជាដើម ដែលពួកគាត់មានប្រាក់ចំណូលទៀងទាត់ប្រចាំខែ និងត្រូវការទុនដើម្បីប្រើប្រាស់។ ការសងប្រភេទនេះអតិថិជនត្រូវបង់នូវប្រាក់ដើមថេរជារៀងរាល់គ្រា ដែលចំនួនទឹកប្រាក់ដែលត្រូវបង់សរុបម្តងៗស្មើនឹងប្រាក់ដើមដែលត្រូវរំលស់បូកនិងការប្រាក់។

  **ឧទាហរណ៍** : លោក ចិត្របានខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួន $3,000 ក្នុងអត្រាការប្រាក់ 1.5% ក្នុងមួយខែ សម្រាប់រយៈពេល 2 ឆ្នាំ។ ចូរធ្វើតារាងសងរំលស់ដើមថេរ។

**ដំណោះស្រាយ**

បម្រាប់ : (r) អត្រាការប្រាក់ ១.៥% ក្នុង១ខែ

(t) រយៈពេលខ្ចី ២ឆ្នាំ (២៤ខែ)

(P) ប្រាក់ដែលខ្ចី $៣,០០០

- រកប្រាក់ដើមដែលត្រូវបង់ក្នុងមួយខែៗ

ប្រាក់ដើមដែលត្រូវបង់ = $\frac{\text{ប្រាក់ជំពាក់សរុប}}{\text{រយៈពេលខ្ចី}} = \frac{3,000}{24} = 125$

- រកការប្រាក់ក្នុងខែទី១

តាមរូបមន្ត $I = (P \times r \times t)$

$$I = 3,000 \times 0.015 \times 1 = 45$$

- រកការប្រាក់ក្នុងខែទី ២

$$I = (3,000 - 125) \times 0.015 = 43.13$$

- រកប្រាក់ដែលបង់សរុបក្នុងខែទី១

ប្រាក់ដែលត្រូវបង់សរុប = ប្រាក់ដើមដែលរំលស់ + ការប្រាក់

= 125 + 45 = 170

- រកប្រាក់ដែលបង់សរុបក្នុងខែទី២

= 125 + 43.13 = 168.13

**តារាងទី៥** : តារាងបង់រំលស់ដើមថេរ

| ចំនួនខែ | ប្រាក់ដើមដែលជំពាក់ | ប្រាក់ដើមត្រូវសង | ការប្រាក់ | ប្រាក់ត្រូវសងសរុប | សមតុល្យចុងគ្រា |
|---|---|---|---|---|---|
| 1 | 3,000 | 125 | 45.00 | 170.00 | 2,875 |
| 2 | 2,875 | 125 | 43.13 | 168.13 | 2,750 |
| 3 | 2,750 | 125 | 41.25 | 166.25 | 2,625 |
| 4 | 2,625 | 125 | 39.38 | 164.38 | 2,500 |
| 5 | 2,500 | 125 | 37.50 | 162.50 | 2,375 |
| 6 | 2,375 | 125 | 35.63 | 160.63 | 2,250 |
| 7 | 2,250 | 125 | 33.75 | 158.75 | 2,125 |
| 8 | 2,125 | 125 | 31.88 | 156.88 | 2,000 |
| 9 | 2,000 | 125 | 30.00 | 155.00 | 1,875 |
| 10 | 1,875 | 125 | 28.13 | 153.13 | 1,750 |
| 11 | 1,750 | 125 | 26.25 | 151.25 | 1,625 |
| 12 | 1,625 | 125 | 24.38 | 149.38 | 1,500 |
| 13 | 1,500 | 125 | 22.50 | 147.50 | 1,375 |

| | | | | | |
|---|---|---|---|---|---|
| 14 | 1,375 | 125 | 20.63 | 145.63 | 1,250 |
| 15 | 1,250 | 125 | 18.75 | 143.75 | 1,125 |
| 16 | 1,125 | 125 | 16.88 | 141.88 | 1,000 |
| 17 | 1,000 | 125 | 15.00 | 140.00 | 875 |
| 18 | 875 | 125 | 13.13 | 138.13 | 750 |
| 19 | 750 | 125 | 11.25 | 136.25 | 625 |
| 20 | 625 | 125 | 9.38 | 134.38 | 500 |
| 21 | 500 | 125 | 7.50 | 132.50 | 375 |
| 22 | 375 | 125 | 5.63 | 130.63 | 250 |
| 23 | 250 | 125 | 3.75 | 128.75 | 125 |
| 24 | 125 | 125 | 1.88 | 126.88 | |
| **Total** | | **3000.00** | **562.50** | **3,562.50** | |

- **សងបត់បែន** គឺជារបៀបសងមួយទៀតដែលបង្កើតឡើង ដើម្បីជួយសម្រួលទៅដល់កសិករ និងអ្នកជំនួញ ដែលអនុញ្ញាតឲ្យអតិថិជនសងត្រឡប់មកវិញនូវប្រាក់ដើមនៅតាមដំណាក់កាល ឬការចរចារ ដោយយោងទៅលើសាច់ប្រាក់ជាក់ស្តែងរបស់ខ្លួន។

**ឧទាហរណ៍ :** លោក សីហាបានខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួន $ 10,000 ក្នុង អត្រាការប្រាក់ 1.5% ក្នុងមួយខែសម្រាប់រយៈពេល 18 ខែ ដោយធ្វើការសងប្រាក់ដើមរាល់៦ខែម្តង។ ចូរធ្វើតារាងសងរំលស់។

## ដំណោះស្រាយ

បម្រាប់ : (r) អត្រាការប្រាក់ ១.៥% ក្នុង១ខែ

(t) រយៈពេលខ្ចី ១៨ខែ

(P) ប្រាក់ដែលខ្ចី $១០,០០០

ដោយសងប្រាក់ដើមរាល់៦ ខែម្តង

យើងបាន

$$\text{ប្រាក់ដើមត្រូវសងម្តងៗ} = \frac{\text{ប្រាក់ជំពាក់}}{\text{រយៈពេលសង}} = \frac{10,000}{3} = 3,333.33$$

- រកការប្រាក់

I = 10,000 x 0.015 x 1 = 150

**តារាងទី៦** : តារាងបង់រំលស់ (បត់បែន)

| ចំនួនខែ | ប្រាក់ដើមត្រូវសង | ការប្រាក់ | ប្រាក់បង់សរុប | សមតុល្យចុងគ្រា |
|---|---|---|---|---|
| 1 | - | 150 | 150 | 10,000 |
| 2 | - | 150 | 150 | 10,000 |
| 3 | - | 150 | 150 | 10,000 |
| 4 | - | 150 | 150 | 10,000 |
| 5 | - | 150 | 150 | 10,000 |
| 6 | 3,333.33 | 150 | 3,483.33 | 6,666.67 |
| 7 | - | 100.00 | 100.00 | 6666.67 |
| 8 | - | 100.00 | 100.00 | 6666.67 |
| 9 | - | 100.00 | 100.00 | 6666.67 |
| 10 | - | 100.00 | 100.00 | 6666.67 |
| 11 | - | 100.00 | 100.00 | 6666.67 |
| 12 | 3,333.33 | 100.00 | 3,433.33 | 3,333.33 |
| 13 | - | 50.00 | 50.00 | 3,333.33 |
| 14 | - | 50.00 | 50.00 | 3,333.33 |
| 15 | - | 50.00 | 50.00 | 3,333.33 |
| 16 | - | 50.00 | 50.00 | 3,333.33 |
| 17 | - | 50.00 | 50.00 | 3,333.33 |
| 18 | - | 50.00 | 3,383.33 | - |
| Total | | 1,500 | 11,800 | |

#### ៣.៤.៤.៣. ការសងត្រឡប់មកវិញនៃឥណទាន

ភ្នាក់ងារឥណទានត្រូវធ្វើការវិភាគ និងវាយតម្លៃលទ្ធភាពសងរបស់អតិថិជនដើម្បីឲ្យប្រាកដថា ឥណទានត្រូវបានសងត្រឡប់មកវិញទាំងដើមទាំងការបានទាន់ពេលវេលា។ ការវាយតម្លៃប៉ាន់-ស្មានលទ្ធភាពសងបំណុល ផ្អែកសំខាន់បំផុតលើចំណូលបច្ចុប្បន្នរបស់អ្នកខ្ចីជាមូលដ្ឋាន គឺមិនផ្អែកទៅលើចំណូលដែលនឹងកើតមាន ឬប៉ាន់ស្មានលំហូរសាច់ប្រាក់ដែលនឹងទទួលបាននៅពេល

អនាគតទេ។ ប្រសិនបើចំណូលសំខាន់ៗពីមុខរបរមិនគ្រប់គ្រាន់សម្រាប់សងបំណុលទេនោះ អាចវិភាគលើចំណូលផ្សេងៗតែត្រូវធ្វើការសិក្សាឲ្យបានលំអិតធ្វើយ៉ាងណាបង្ហាញឲ្យឃើញថា អ្នកខ្ចីពិតជាមានលទ្ធភាពអាចសងបំណុលបានទាំងស្រុង។

ករណីអតិថិជនសងបំណុលបញ្ចប់មុនកាលបរិច្ឆេទកិច្ចសន្យាខ្ចីប្រាក់ ការប្រាក់ត្រូវកាត់បន្ថយត្រូវគណនាសមាមាត្រទៅនឹងចំនួនថ្ងៃដែលសងដាច់មុនកាលកំណត់នោះ។

#### ៣.៤.៤.៤. ការធ្វើតារាងកាលវិភាគសងប្រាក់ឡើងវិញ

ការធ្វើតារាងវិភាគសងប្រាក់ឡើងវិញ អាចអនុញ្ញាតឲ្យបានចំពោះអតិថិជនដែលសងបំណុលប្រាក់ដើមលើសពីចំនួនកំណត់ក្នុងតារាងសងប្រាក់តែប៉ុណ្ណោះ ដោយកាត់បន្ថយរយៈពេលខ្ចី ឬរក្សារយៈពេលខ្ចីនៅដដែល ប៉ុន្តែកាត់បន្ថយចំនួនទឹកប្រាក់ដែលត្រូវសង។

#### ៣.៤.៤.៥. ការផ្តល់ឥណទានបន្ថែម

ការផ្តល់ឥណទានបន្ថែមលើសមតុល្យឥណទានចាស់ត្រូវបានអនុញ្ញាតដោយអនុលោមទៅតាមនីតិវិធី និងសិទ្ធក្នុងការអនុម័តឥណទានលុះត្រាតែៈ

- អតិថិជនមានមុខរបររីកចម្រើន ចំណូលកើនឡើង ឬផ្តល់ឥណទានលើកមុនមិនទាន់អស់លទ្ធភាពហើយមុខរបរមានសក្តានុពល។
- អតិថិជនត្រូវការដើមទុនពង្រីកមុខរបរបន្ថែម និង មានទ្រព្យសម្បត្តិធានាគ្រប់គ្រាន់។

### ៣.៤.៥. ការខកខានសង និងការពិន័យ

#### ៣.៤.៥.១. ការខកខានសង

ឥណទានមួយត្រូវបានចាត់ទុកថាខកខានមិនបានសងតាមកិច្ចសន្យា កាលណាដល់ពេលវេលាសងហើយអ្នកខ្ចីមិនបានសងទាន់ពេលវេលាដូចបានចែងក្នុងកិច្ចសន្យា និងតារាងកាលវិភាគសងប្រាក់។ រយៈពេលខកខានសងប្រាក់ គឺជាចំនួនថ្ងៃដែលខកខានមិនបានសងតាមតារាងកិច្ចសន្យារាប់ចាប់ពីថ្ងៃយឺតដំបូង ហើយរយៈពេលនេះនឹងត្រូវបានកាត់បន្ថយក្នុងករណីទំហំទឹកប្រាក់បានសងសមាមាត្រទៅនឹងទឹកប្រាក់នៃចន្លោះរយៈពេលយឺតយ៉ាវសងនោះ។

- ❖ ចំពោះការខកខានសងចែកចេញជា ២គឺៈ
  - ការខកខានសងកម្រិតស្រាល គឺជាការខកខានសងប្រាក់ ឬទឹកប្រាក់មិនគ្រប់ចំនួនហួសកាលកំណត់នៃកិច្ចសន្យារយៈពេលតិចជាង៣០ថ្ងៃ។
  - ការខកខានសងកម្រិតធ្ងន់ គឺជាការខកខានសងប្រាក់ ឬទឹកប្រាក់សងមិនគ្រប់ចំនួនហួសកាលកំណត់នៃសន្យារយៈពេលចាប់ពី ៣០ថ្ងៃ។

#### ៣.៤.៥.២. ការពិន័យ

ការខកខានសងប្រាក់បំណុលចាប់ពីរយៈពេល ០៥ថ្ងៃឡើងទៅត្រូវបានគិតអត្រាពិន័យ ០.២%។ ការពិន័យត្រូវបានគណនាដោយយក ចំនួនទឹកប្រាក់ សរុបដែលខកខានមិនបានសងគុណនឹងអត្រា០.២%ទៅតាមចំនួនថ្ងៃដែលយឺតយ៉ាវ។

រូបមន្តគណនាប្រាក់ពិន័យ

$$\mathbf{P} = \mathbf{OA} \times 0.2\% \times \mathbf{NOD}$$

- P ប្រាក់ពិន័យ (Penalty)
- OA ប្រាក់ខកខានមិនបានសង (Overdue Amount)
- 0.2% អត្រាពិន័យ
- NOD ចំនួនថ្ងៃដែលយឺតយ៉ាវ ( Number of Overdue Days)

### ៣.៤.៦. ការធ្វើចំណាត់ថ្នាក់ឥណទាន និងសំវិធានធន

#### ៣.៤.៦.១. ការធ្វើចំណាត់ថ្នាក់ឥណទាន

ការចាត់ថ្នាក់ឥណទានត្រូវបានគេចែកចេញជា ៤ថ្នាក់គឺ៖

១. បំណុលស្តង់ដារ : ទ្រព្យសកម្មប្រភេទនេះត្រូវបានធានាទាំងស្រុងដោយទ្រព្យសម្បត្តិ និងសមត្ថភាពទូទាត់សងរបស់អ្នកខ្ចីនាពេលបច្ចុប្បន្ន និង ជាទ្រព្យសកម្ម ដែលកំពុងដំណើរការអនុលោមតាមកិច្ចសន្យា និងរំពឹងថានៅតែបន្តដំណើរការបែបនេះរហូត។

២. បំណុលក្រោមស្តង់ដា : ទ្រព្យសកម្មប្រភេទនេះមិនត្រូវបានការពារគ្រប់គ្រាន់ដោយទ្រព្យសម្បត្តិ និងសមត្ថភាពសងបំណុលរបស់អ្នកខ្ចីឡើយ ជាពិសេសប្រភពធនធានចម្បងសម្រាប់សងបំណុលមិនគ្រប់គ្រាន់ ដើម្បីសងបំណុលដែលការបង់ការប្រាក់ និងប្រាក់ដើមហួសកាលកំណត់ដូចខាងក្រោម៖

- ហួសការកំណត់ធំជាង ៣០ថ្ងៃតិចជាង៦០ថ្ងៃ នៅក្នុងករណីដែលបំណុលមានកាលកំណត់ជាក់លាក់មួយឆ្នាំ ឬតិចជាងមួយឆ្នាំ។
- ហួសកាលកំណត់ធំជាង ៣០ថ្ងៃតិចជាង១៨០ថ្ងៃ នៅក្នុងករណីដែលបំណុលមានកាលកំណត់ជាក់លាក់ច្រើនជាងមួយឆ្នាំ។

៣. បំណុលសង្ស័យ : ទ្រព្យសកម្មប្រភេទនេះ មានចំណុចខ្សោយដូចឥណទានក្រោមស្តង់ដារ ដោយបូកបន្ថែមលក្ខខណ្ឌដែលឥណទានមិនបានធានាបានល្អ។ យោងតាមហេតុការណ៍ជាក់ស្តែង ស្ថានភាព និងតម្លៃចំណុចខ្សោយទាំងនោះបានសង្ស័យថា ឥណទានទាំងនោះមិនអាចប្រមូលបានមកវិញទាំងស្រុងទេ។ លទ្ធផលបាត់បង់មានកម្រិតខ្ពស់ ប៉ុន្តែ

ដោយសារតែមានការរង់ចាំមើលព្រឹត្តិការណ៍ជាក់លាក់ និងសមស្របណាមួយដែលនឹងកាត់បន្ថយកម្រិតបាត់បង់នោះនូវបរិមាណពិតប្រាកដនៃបំណុលដែលត្រូវបាត់បង់ មិនអាចកំណត់បានទាំងស្រុង ហើយជាឥណទានដែលហួសកាលកំណត់សងដូចខាងក្រោម៖

- ហួសកាលកំណត់ធំជាង ៦០ថ្ងៃតិចជាង៩០ថ្ងៃ នៅក្នុងករណីដែលបំណុលមានកាលកំណត់ជាក់លាក់មួយឆ្នាំ ឬតិចជាងមួយឆ្នាំ។
- ហួសកាលកំណត់ធំជាង ១៨០ថ្ងៃតិចជាង៣៦០ថ្ងៃ នៅក្នុងករណីដែលបំណុលមានកាលកំណត់ជាក់លាក់ច្រើនជាងមួយឆ្នាំ។

៤. បំណុលបាត់បង់ : ជាទ្រព្យសកម្មទាំងឡាយដែលត្រូវបានចាត់ទុកថាមិនអាចប្រមូលបានមកវិញ ឬនៅមានតម្លៃតិចតួច ត្រូវបានចាត់ថ្នាក់ជាបំណុលបាត់បង់។ វាជាឥណទានដែលហួសកាលកំណត់សងចំនួន ៣៦០ថ្ងៃ ឬលើសពីនេះ។

**៣.៤.៦.២. ការធ្វើសំវិធានធន**

ការធ្វើសំវិធានធន ជាការបម្រុងទុក ឬរំពឹងទុកជាមុននូវទំហំឥណទានដែលមិនដំណើរការ ឬខូចខាត បាត់បង់ ដើម្បីការពារហានិភ័យឥណទានរបស់ស្ថាប័នដោយតម្រូវទៅតាមច្បាប់ ឬសេចក្តីប្រកាសរបស់ធនាគារជាតិ។

សំវិធានធនត្រូវបានបែងចែកជា ២ គឺ សំវិធានធនទូទៅ និងសំវិធានធនជាក់លាក់។

**ក. សំវិធានធនទូទៅ** ត្រូវបានគណនាដោយយកឥណទានមិនដំណើរការទាំងអស់ដកចេញនូវចំនួនសំវិធានធនជាក់លាក់៖

| សំវិធានធនទូទៅ = ឥណទានមិនដំណើរការទាំងអស់ - សំវិធានធនជាក់លាក់ |
|---|

- សម្រាប់ឥណទានថ្នាក់ "ធម្មតា" : ១%នៃឥណទានដុល

**ខ. សំវិធានធនជាក់លាក់** សំវិធានធនជាក់លាក់ត្រូវបានអនុវត្តចំពោះបំណុលយឺតយ៉ាវចាប់ពីចំណាត់ថ្នាក់ដូចខាងក្រោម៖

- ក្រោមស្តង់ដារ ១០% នៃឥណទានដុល
- សង្ស័យ ៣០% នៃឥណទានដុល
- បាត់បង់ ១០០% នៃឥណទានដុល

### ៣.៤.៧. ហានិភ័យឥណទាន

#### ៣.៤.៧.១ និយមន័យហានិភ័យឥណទាន

ហានិភ័យឥណទាន គឺសំដៅលើហានិភ័យនៃការខាតបង់ដោយសារអតិថិជនដែលជាអ្នកខ្ចីមិនមានលទ្ធភាពក្នុងការបំពេញកាតព្វកិច្ចសងប្រាក់ទៅតាមកិច្ចសន្យារបស់ខ្លួន។ ហានិភ័យឥណទាន គឺជាហានិភ័យមួយប្រភេទដែលគ្រប់ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងអស់តែងយកចិត្តទុកដាក់ជាងគេ ព្រោះវាអាចជម្រុញឲ្យស្ថាប័នទាំងនោះក្ស័យធនបាន។ ដូចនេះមុននឹងសម្រេចចិត្តផ្តល់ឥណទានគ្រប់ស្ថាប័នទាំងនោះគេ តែងតែសិក្សាទៅលើហានិភ័យឥណទានជាចម្បងរហូតដល់គេរកឃើញថាគ្មានហានិភ័យ ឬហានិភ័យទាបទើបគេព្រមផ្តល់កម្ចីឲ្យ។

សរុបមកហានិភ័យឥណទាន គឺជាអ្វីទាំងឡាយណាដែលអាចកើតឡើងចំពោះធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលធ្វើឲ្យធនាគារ និងគ្រឹះស្ថានទាំងនោះទទួលរងនូវការខូចខាតដោយសារអតិថិជនរបស់ខ្លួនមិនបានសងបំណុលតាមកិច្ចសន្យា ឬមិនអាចសងបំណុលបាន ឬសងមិនគ្រប់ចំនួនទាំងប្រាក់ដើម និងការប្រាក់។

#### ៣.៤.៧.២. មូលហេតុនៃហានិភ័យឥណទាន

ហានិភ័យ គឺជាហេតុការណ៍ដែលកើតឡើងជាយថាហេតុដែលយើងមិនអាចស្មានដល់។ យោងតាមការសិក្សាស្រាវជ្រាវកន្លងមកបានបង្ហាញឲ្យឃើញថាហានិភ័យឥណទានអាចកើតឡើងអាស្រ័យដោយកត្តា ៣យ៉ាង៖

**ក. កត្តាអតិថិជន**

- ការយល់ពីលក្ខខណ្ឌឥណទានខុស ការមិនយកចិត្តទុកដាក់របស់អតិថិជន ដែលធ្វើឲ្យមិនដឹងពីលក្ខខណ្ឌនានាដូចជា មិនបានដឹងពីគម្រោងនៃការសងបំណុល បាត់វិក្ក័យបត្រ ឬវិក្កយបត្រផ្ញើរមិនបានដល់។
- អ្នកខ្ចីមានគំនិតផ្តេកផ្តួលមិនចង់សងបំណុលបានបង្កើតនូវវប្បធម៌មើលបំណាំគ្នាកេងប្រវ័ញ្ចពេលវេលាសងការប្រាក់។ មិនគោរពតាមកិច្ចសន្យា ឬកិច្ចព្រមព្រៀង និងព្យាយាមបង្កើតបញ្ហាដើម្បីពន្យាពេលនៃការសង។
- អ្នកខ្ចីរួមគំនិតគ្នាជាក្រុម ឬជាមួយអ្នកធានាក្នុងការចែកឥណទាន បន្លំឯកសារដើម្បីទទួលបានឥណទានក្នុងគោលបំណងយកទៅប្រើប្រាស់ ខុសពីទិសដៅជំនួញដោយសារខ្លួនកំពុងជួបវិបត្តិហិរញ្ញវត្ថុជាមួយម្ចាស់បំណុលផ្សេង។
- អតិថិជនមានប្រវត្តិរស់នៅមិនចុះសម្រុងជាមួយសង្គម ប្រព្រឹត្តល្បែងស៊ីសង អំពើអបាយមុខដែលបណ្តាលឲ្យអន្តរាយទ្រព្យសម្បត្តិ។

- ក្រុមគ្រួសារមានវិបត្តិ និងមានបំណងគេចវេស។ អតិថិជនមានឆន្ទៈក្នុងការសង ប៉ុន្តែដោយសារបញ្ហាកើតឡើងដូចជា សមាជិកគ្រួសារមានជំងឺ មុខរបរមានបញ្ហាដែលជាមូលហេតុនាំឲ្យអតិថិជនបាត់បង់លទ្ធភាពក្នុងការសងបំណុល។
- អាចត្រូវដៃគូ ឬអ្នកវិនិយោគដទៃទៀតបោកប្រាស់។ នៅពេលខ្លះដោយសារវិនិយោគគិន ឬសហគ្រិនទុកចិត្តទៅដៃគូវិនិយោគខ្លាំងពេក ធ្វើឲ្យពួកគេប្រឈមមុខនឹងការខាតបង់ដោយសារតែដៃគូវិនិយោគបោកប្រាស់ និងកេងផលចំណេញនៅក្នុងមុខរបរ។
- ការប្រើប្រាស់ប្រាក់ខុសគោលដៅ ៖ អតិថិជនមួយចំនួនប្រើប្រាស់ឥណទានដែលបានផ្តល់ឲ្យខុសគោលដៅ ដោយមិនយកឥណទានទាំងនោះទៅប្រើប្រាស់ទៅតាមគោលបំណងដែលខ្ចីទេ តែបែរជាយកកម្ចីទាំងនោះទៅប្រព្រឹត្តល្បែង ឬអំពើខុសច្បាប់ផ្សេងៗ។
- មុខរបរចម្បងដួលរលំ ឬមានបញ្ហាធ្ងន់ធ្ងរ (គ្មានចំណូល ឬក្ស័យធន) មុខរបរបន្ទាប់បន្សំ មិនអាចទ្រទ្រង់ចំណាយបាន ដែលបណ្តាលឲ្យប៉ះពាល់ដល់ការសងត្រឡប់។
- អតិថិជនមានទំនាស់ក្នុងគ្រួសារធ្ងន់ធ្ងរ មានការបែកបាក់គ្នា ហើយម្នាក់ៗមិនទទួលខុសត្រូវលើបំណុលដែលកំពុងជំពាក់។
- ប្តី ឬប្រពន្ធ ឬអ្នករួមខ្ចី បាត់បង់ជីវិតដោយសារជំងឺ ឬដោយសារគ្រោះថ្នាក់ផ្សេងៗ-ល-។

**ខ. កត្តាគ្រឹះស្ថានផ្ទាល់**

- កើតឡើងដោយអ្នកឲ្យខ្ចី និងបុគ្គលិកដែលពាក់ព័ន្ធមិនបានយកចិត្តទុកដាក់ទៅលើការងាររបស់ខ្លួន ដូចជាភ្នាក់ងារឥណទានវាយតម្លៃប្រាក់កម្ចីមិនបានត្រឹមត្រូវ និងសិក្សាមិនបានល្អិតល្អន់ពីប្រវត្តិ និងអត្តចរិតអ្នកខ្ចី លំហូរសាច់ប្រាក់ លទ្ធភាពសង និងហានិភ័យដែលពាក់ព័ន្ធផ្សេងៗ។
- ភ្នាក់ងារឥណទានមិនបានយកចិត្តទុកដាក់បំពេញឯកសារឥណទាន ឲ្យបានត្រឹមត្រូវឬមិនបានបង្កើតជាកិច្ចព្រមព្រៀងនានា ដើម្បីជំនួយ និងភស្តុតាងក្នុងការដោះស្រាយបំណុលអាចនឹងកើតមានឡើង។
- ភ្នាក់ងារ ធ្វើរបាយការណ៍ ដែលមិនឆ្លុះបញ្ចាំង ពីស្ថានភាពជាក់ស្តែងរបស់អតិថិជន
- ភ្នាក់ងារឥណទានមិនបានយកចិត្តទុកដាក់ក្នុងការតាមដាន និងត្រួតពិនិត្យបំណុលឲ្យទាន់ពេលវេលា។

**គ. កត្តាសង្គម និងធម្មជាតិ**

- សង្គមៈ សង្គ្រាម ការប្រែប្រួលសេដ្ឋកិច្ច ការផ្លាស់ប្តូររដ្ឋាភិបាល នយោបាយសេដ្ឋកិច្ច

- វិបត្តិសេដ្ឋកិច្ច៖ កាលណាមានវិបត្តិសេដ្ឋកិច្ចកើតឡើងនាំឲ្យក្រុមហ៊ុន សហគ្រាស អាជីវកម្ម ត្រូវប្រឈមមុខនឹងក្ស័យធន ព្រោះថាតម្រូវការអតិថិជនមានការធ្លាក់ចុះដែលជាហេតុបណ្ដាលឲ្យចំណូលផ្ទាល់ខ្លួន និង ចំណូលក្រុមហ៊ុនធ្លាក់ចុះដូចក្រុមហ៊ុនមិនមានលទ្ធភាពសងបំណុលមកធនាគារវិញ។
- គ្រោះធម្មជាតិ ៖ ខ្យល់ព្យុះ គ្រោះរាំងស្ងួត ទឹកជំនន់ ភ្លើងឆេះផ្ទះ និងបាតុភូតធម្មជាតិ នាំឲ្យអតិថិជនបាត់បង់លទ្ធភាពសងដោយសារតែអាជីវកម្មត្រូវបានផ្អាកដំណើរការ។

### ៣.៤.៧.៣. វិធីសាស្ត្រកាត់បន្ថយហានិភ័យឥណទាន

ដើម្បីគ្រប់គ្រងឥណទានឲ្យមានប្រសិទ្ធិភាព អម្រឹតជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលជាអ្នកផ្ដល់ឥណទានមានវិធីសាស្ត្រយ៉ាងហ្មត់ចត់ក្នុងការការពារហានិភ័យនេះ ដោយសិក្សាទៅលើចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម៖

**ក. ចំពោះអតិថិជន**

មន្ត្រីឥណទានត្រូវតាមដានឲ្យបានជិតដល់ចំពោះអតិថិជនរបស់ខ្លួន ដោយធ្វើការកំណត់ជាបីដំណាក់កាលដូចជា ៖

១. មុនពេលផ្ដល់ឥណទាន : មន្ត្រីឥណទាន ត្រូវប្រមូលពត៌មានអំពីអតិថិជនឲ្យបានច្បាស់លាស់ ដោយធ្វើការស៊ើបសួរព័ត៌មានពីអាជ្ញាធរមានសមត្ថកិច្ច អ្នកជិតខាង ក៏ដូចជាអតិថិជនផ្ទាល់ទាក់ទងទៅនឹងគោលបំណងសុំខ្ចីឥណទាន ទ្រព្យធានា ចំណូលចំណាយ ស្ថានភាពគ្រួសារជាដើម ហើយធ្វើការវាយតម្លៃលើព័ត៌មាននោះថាតើមានភាពលម្អៀងគ្នាដែរ ឬទេ?

២. អំឡុងពេលផ្ដល់ឥណទាន : ផ្ដល់ឥណទានដែលទាក់ទងនឹងអត្រាការប្រាក់ របៀបសងប្រាក់ រយៈពេលខ្ចី ការផាកពិន័យ និងព័ត៌មានផ្សេងៗដែលទាក់ទងនឹងការប្រើប្រាស់សេវាឥណទាន។

៣. ក្រោយពេលផ្ដល់ឥណទាន : មន្ត្រីឥណទានត្រូវតាមដានអតិថិជនខ្លួនថាតើការធ្វើអាជីវកម្មគាត់មានការរីកចម្រើន ឬទេ? មើលថាទ្រព្យធានារបស់គាត់មានការលក់ដូរ ឬមានការផ្ទេរកម្មសិទ្ធិដែរទេ? ហើយតើគាត់មានការជំពាក់បំណុលថែមទៀតជាមួយគ្រឹះស្ថានផ្សេងទៀត ឬទេ។

**ខ. ចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ**

- ប្រធានសាខាត្រូវពង្រីក ការអនុវត្តរបស់មន្ត្រីឥណទានក្នុងរបាយការណ៍កម្ចីយឺតយ៉ាវ
- ប្រធានសាខាត្រូវចុះត្រួតពិនិត្យផ្ទាល់ លើស្ថានភាពជាក់ស្ដែងរបស់អតិថិជននីមួយៗមុននឹងធ្វើការសម្រេចចិត្ត

- ធ្វើការជ្រើសរើសបុគ្គលិកដែលមានចំណេះដឹងទាក់ទងនឹងឥណទាន
- ធ្វើការបណ្តុះបណ្តាលបន្ថែមដល់បុគ្គលិក
- ដាក់ទោសចំពោះបុគ្គលិកដែលសាងកំហុសដដែលៗ
- ធ្វើការលើកទឹកចិត្តបន្ថែមដូចជា ផ្តល់ប្រាក់បន្ថែមលើប្រាក់បៀវត្ស ឬដំឡើងតំណែងដល់បុគ្គលិកណាដែលបំពេញការងារបានល្អ។

**៣.៤.៧.៤. វិធីសាស្រ្តដោះស្រាយបំណុលមានបញ្ហា**

ដំណើរការនៃការដោះស្រាយ បំណុលមានបញ្ហា គឺជាដំណាក់កាលមួយដ៏សំខាន់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្នុងការគ្រប់គ្រងផលបត្ររបស់ខ្លួន។ ដូច្នេះរាល់ការយឺតយ៉ាវរបស់អតិថិជនគ្រឹះស្ថានត្រូវមានចំណាត់ការ ឬការដោះស្រាយប្រមូលបំណុលយឺតយ៉ាវទាំងនោះត្រឡប់មកវិញ។ ចំណាត់ការរបស់គ្រឹះស្ថាន គឺមានចាប់ពីស្រាល រហូតដល់ករណីធ្ងន់ធ្ងរ គឺអាស្រ័យទៅតាមប្រភេទនៃការយឺតយ៉ាវ ដែលមានដូចជា៖

ក. ការយឺតយ៉ាវ ចាប់ពី ០ - ៣១ ថ្ងៃ

- ផ្តល់ដំណឹងដល់អតិថិជន
- បើយឺតយ៉ាវឬជាទម្លាប់ធ្វើការប្រមាន ឬធ្វើការផាកពិន័យ
- ទាក់ទងទៅអ្នកធានា ឬអាជ្ញាធរ ធ្វើការដោះស្រាយ
- ធ្វើកិច្ចសន្យាសងប្រាក់

ខ. ការយឺតយ៉ាវ ចាប់ពី ៣១ - ៩០ ថ្ងៃ

- ឲ្យមន្រ្តីឥណទានចុះទៅសួរបញ្ហាបំណុលជាមួយអតិថិជន
- បើមានការគេចវេសមិនព្រមជួបមន្រ្តីឥណទានអាចទៅរកអាជ្ញាធរ ឬអ្នកធានា
- ត្រូវពឹងពាក់អាជ្ញាធរឲ្យអញ្ជើញអតិថិជនដើម្បីធ្វើការដោះស្រាយ
- ធ្វើកិច្ចព្រមព្រៀងពេលវេលាសងឲ្យបានជាក់លាក់
- ត្រូវផាកពិន័យទៅតាមកម្រិតស្រាល ឬធ្ងន់តាមស្ថានភាពជាក់ស្តែង

គ. ការយឺតយ៉ាវ ចាប់ពី ៩០ -១៨០ ថ្ងៃ

- ពិនិត្យមើលជាក់ស្តែងដល់ផ្ទះអតិថិជន
- ទាក់ទងដោយផ្ទាល់ជាមួយអតិថិជនលើបញ្ហាសងប្រាក់
- វាយតម្លៃថាតើអតិថិជនមានលទ្ធភាពសង ឬគ្មាន

- ក្នុងករណីដែលមានការគេចវេសមិនចង់សងប្រាក់ គ្រឹះស្ថានមានសិទ្ធិដាក់ពាក្យបណ្តឹងទៅ អាជ្ញាធរមូលដ្ឋានដើម្បីធ្វើការដោះស្រាយ ឬពិភាក្សាអំពីទ្រព្យធានារបស់អតិថិជន។

ឃ. ការយឺតយ៉ាវ ចាប់ពី ១៨០ - ៣៦០ ថ្ងៃ

- គ្រឹះស្ថានធ្វើការប្តឹងទៅដល់តុលាការ ដើម្បីបានសិទ្ធិលក់ទ្រព្យធានា ដែលអតិថិជនបានដាក់ធានាក្នុងការខ្ចី។

### ៣.៤.៧.៥. ការវាស់វែងអត្រាហានិភ័យឥណទាន

#### ក. អត្រាហានិភ័យឥណទាន

អត្រាហានិភ័យឥណទាន (PAR) ត្រូវបានគណនាតាមរូបមន្តដូចខាងក្រោម៖

$$\text{PAR}=\frac{\text{សមតុល្យឥណទានដែលខកខានមិនបានសងតាមកិច្ចសន្យា(ប្រាក់ដើម)}}{\text{សមតុល្យឥណទានសរុប(ប្រាក់ដើម)}}\times ១០០$$

ការកំណត់បទដ្ឋានហានិភ័យ សម្រាប់វាយតម្លៃគុណភាពឥណទានដូចខាងក្រោម៖

- PAR រហូតដល់ ១% ការអនុវត្តត្រូវបានចាត់ទុកថាល្អណាស់
- PAR ធំជាង ១% រហូតដល់ ២% ការអនុវត្តត្រូវបានចាត់ទុកថាល្អ
- PAR ធំជាង ២% រហូតដល់ ៣% ការអនុវត្តត្រូវបានចាត់ទុកថាមធ្យម
- PAR ធំជាង ៣% រហូតដល់ ៥% ការអនុវត្តត្រូវបានចាត់ទុកថា នៅមានការខ្វះខាតត្រូវកែលម្អ
- PAR ធំជាង ៥% ការអនុវត្តត្រូវបានចាត់ទុកថា ខ្សោយត្រូវមានវិធានការ។

#### ខ. អត្រានៃការសងត្រឡប់មកវិញ

ឥណទានដែលខកខានមិនបានសងតាមកិច្ចសន្យា ត្រូវបានវាស់វែងគុណភាពនៃការសងត្រឡប់មកវិញតាមអត្រាដូចបានគណនាដោយប្រើរូបមន្ត ៖

$$\text{អត្រាការសងមកវិញ}=\frac{\text{សរុបទឹកប្រាក់ដែលត្រូវសងហើយបានសង(ឥណទានសកម្ម)}}{\text{សរុបទឹកប្រាក់ដែលត្រូវសង(ឥណទានសកម្ម)}}\times ១០០$$

### គ. បំណុលលុបចេញពីបញ្ជី

បំណុលដែលបាត់បង់ (Loss) ដែលបានធ្វើសំវិធានធនជាក់លាក់ ១០០% នឹងត្រូវបានលុបចេញពីបញ្ជី (Write-off) ដោយស្វ័យប្រវត្តិបន្ទាប់ពីហួសរយៈពេល ៣៦០ថ្ងៃនៃកាលបរិច្ឆេទសងប្រាក់ចុងក្រោយ។ អត្រាបំណុលលុបចេញពីបញ្ជីត្រូវបានគណនាតាមរូបមន្តដូចខាងក្រោម៖

$$\text{អត្រាបំណុលលុបចេញពីបញ្ជី} = \frac{\text{សរុបបំណុលលុបចេញពីក្នុងគ្រា} - \text{ប្រមូលបំណុលលុបចេញពីបញ្ជីក្នុងគ្រា}}{\text{សមតុល្យមធ្យមនៃឥណទានក្នុងគ្រា}} \times 100$$

ការកំណត់បទដ្ឋាន សម្រាប់វាយតម្លៃគុណភាពបំណុលលុបចេញពីបញ្ជីដូចខាងក្រោម៖

- អត្រាស្មើ 0% ត្រូវបានចាត់ទុកថា អនុវត្តបានល្អណាស់
- អត្រាធំជាង 0% រហូតដល់ ១% ត្រូវបានចាត់ទុកថា អនុវត្តបានល្អ
- អត្រាធំជាង ១% រហូតដល់ ១.៥% ត្រូវបានចាត់ទុកថា អនុវត្តបានមធ្យម
- អត្រាធំជាង ១.៥% រហូតដល់ ២% ត្រូវបានចាត់ទុកថាអនុវត្តនៅមានការខ្វះខាតត្រូវកែលម្អ
- អត្រាធំជាង ២% ត្រូវបានចាត់ទុកថា អនុវត្តអន់ខ្សោយត្រូវមានវិធានការ។

## ៣.៥. លទ្ធផលឥណទាននៃការស្រាវជ្រាវ

### ៣.៥.១. សមតុល្យឥណទានសរុបរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត សាខាស្រុកបាត់ដំបង ចាប់ពីឆ្នាំ ២០១៤ ដល់ ២០១៦

តារាងបង្ហាញពីបម្រែបម្រួលនៃទំហំឥណទានដែលបានបញ្ចេញគិតជាប្រាក់រៀល

| ឥណទាននិងបុរេប្រទានអតិថិជន | ២០១៤ | ២០១៥ | ២០១៦ |
|---|---|---|---|
| | KHR | KHR | KHR |
| សមតុល្យឥណទានសរុប-ដុល | ១២,៣៣៣,៦៥៥,០០០ | ១៥,៧៩៣,៣០៦,០០០ | ២១,៩៥៦,៧៧២,០០០ |
| បម្រែបម្រួលឥណទានជាសាច់ប្រាក់ | - | ៣,៤៥៩,៦៥១,០០០ | ៦,១៦៣,៤៦៦,០០០ |
| អត្រាបម្រែបម្រួលនៃឥណទានសរុប-ដុល | - | ២៨.០៥% | ៣៩.០៣% |

**ដ្យាក្រាមបង្ហាញពីបម្រែបម្រួលនៃទំហំឥណទានដែលបានបញ្ចេញ**




តាមតារាងសមតុល្យឥណទានខាងលើ បានបង្ហាញឲ្យឃើញថា ចំនួនឥណទានសរុបដែលបានបញ្ចេញដោយ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត សាខាស្រុកបាភ្នំ ក្នុងឆ្នាំ ២០១៤ ដល់ឆ្នាំ ២០១៦ មានដូចខាងក្រោម៖

- នៅឆ្នាំ ២០១៤ ឥណទានដែលបានបញ្ចេញមានចំនួន ១២,៣៣៣,៦៥៥,០០០ រៀល បើប្រៀបធៀបទៅនឹងឆ្នាំ ២០១៥ ឥណទានដែលបានបញ្ចេញមានចំនួន ១៥,៧៩៣,៣០៦,០០០រៀល។ ដូចនេះ យើងឃើញថាពីឆ្នាំ២០១៤ ដល់ឆ្នាំ ២០១៥ ឥណទានដែលបានបញ្ចេញមានការកើនឡើងចំនួន ៣,៤៥៩,៦៥១,០០០រៀល ត្រូវនឹង ២៨.០៥%។
- នៅឆ្នាំ ២០១៦ ឥណទានដែលបានបញ្ចេញមានចំនួន ២១,៩៥៦,៧៧២,០០០ រៀល បើប្រៀបធៀបទៅនឹងឆ្នាំ ២០១៥ ឥណទានដែលបានបញ្ចេញមានចំនួន ១៥,៧៩៣,៣០៦,០០០រៀល។ ដូចនេះ យើងឃើញថាពីឆ្នាំ ២០១៥ ដល់ឆ្នាំ ២០១៦ ឥណទានដែលបានបញ្ចេញមានការកើនឡើង ចំនួន ៦,១៦៣,៤៦៦,០០០ រៀល ត្រូវនឹង ៣៩.០៣%។

ការកើនឡើងនេះ បណ្តាលមកពីការខិតខំប្រឹងប្រែងរបស់គ្រឹះស្ថាន ជាពិសេសមន្ត្រីផ្នែកឥណទាន ក្នុងការរៀបចំយុទ្ធសាស្ត្រដើម្បីទាក់ទាញអតិថិជនថ្មីបន្ថែម និងរក្សាអតិថិជនចាស់ឲ្យបានជាអតិបរិមា។

### ៣.៥.២. ទំហំឥណទានដែលបានលុបចេញពីបញ្ជី

តារាងអត្រាឥណទាន និងបុរេប្រទានដែលខាតបង់ពីឆ្នាំ ២០១៤ ដល់ ២០១៦

| ឥណទាននិងបុរេប្រទានអតិថិជន | ២០១៤ | ២០១៥ | ២០១៦ |
|---|---|---|---|
| | KHR | KHR | KHR |
| សមតុល្យឥណទានសរុប-ដុល | ១២,៣៣៣,៦៥៥,០០០ | ១៥,៧៩៣,៣០៦,០០០ | ២១,៩៥៦,៧៧២,០០០ |
| ទំហំឥណទានដែលបានលុបចេញពីបញ្ជី | - | - | ៨,៥៨២,០៨០ |
| អត្រាឥណទានដែលខាតបង់ | - | - | ០.០៣៩% |

តាមទិន្នន័យខាងលើបង្ហាញឲ្យឃើញថា នៅចន្លោះពីឆ្នាំ ២០១៤ ដល់ ២០១៦ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត សាខាស្រុកបាភ្នំបានធ្វើការលុបបំណុលចេញពីបញ្ជីតែម្តងប៉ុណ្ណោះនៅក្នុងឆ្នាំ ២០១៦ ដែលមានទំហំទឹកប្រាក់ដែលត្រូវបានលុបចេញមានចំនួន ៨,៥៨២,០៨០ រៀល ដែលគិតជាអត្រាស្មើនឹង ០.០៣៩% ដែលអត្រានេះត្រូវបានចាត់ទុកថាមានការអនុវត្តបានល្អ ដោយពឹងផ្អែកលើការកំណត់បទដ្ឋានសម្រាប់ការវាយតម្លៃគុណភាពបំណុលដែលលុបចេញពីបញ្ជី។

## ៣.៦. **ការវិភាគ** SWOT

### ៣.៦.១. **ចំណុចខ្លាំង**

តាមរយៈការសិក្សាស្រាវជ្រាវពីការគ្រប់គ្រងឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត សាខាស្រុកបាភ្នំ យើងសង្កេតឃើញថា គ្រឹះស្ថានមានចំណុចខ្លាំងជាច្រើនដែលអាចធ្វើឲ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនេះមានភាពរីកចម្រើន ដែលក្នុងនោះមានដូចជា៖

- គ្រឹះស្ថានមានការទទួលស្គាល់ច្រើនពីអតិថិជនគ្រប់មជ្ឈដ្ឋាន
- គ្រឹះស្ថានមានភាគទុនិក និងភាគហ៊ុនិកដ៏រឹងមាំដែលជាដៃគូច្រើនពីបរទេស
- គ្រឹះស្ថានមានសាច់ប្រាក់គ្រប់គ្រាន់សម្រាប់ផ្តល់កម្ចីដល់អតិថិជន
- មានវិធីសាស្ត្រច្រើនដើម្បីជាជម្រើសដល់អតិថិជនក្នុងការខ្ចីសង
- ប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាខ្ពស់ក្នុងការគ្រប់គ្រងទិន្នន័យ
- មានការគ្រប់គ្រងល្អ ជាពិសេសសម្បូរដោយបុគ្គលិកដែលមានចំណេះ ជំនាញ និងបទពិសោធន៍ខ្ពស់
- មានការបណ្តុះបណ្តាលដល់បុគ្គលិកបន្ថែម
- មានសាខាច្រើនដែលផ្តល់ភាពងាយស្រួលក្នុងការផ្តល់សេវាដល់អតិថិជនគ្រប់ទីកន្លែង

- មានការយកចិត្តទុកដាក់ចំពោះអតិថិជនចាស់ និងថ្មី
- ផ្តល់ព័ត៌មានថ្មីៗដែលទាក់ទងនឹងផលិតផល និងសេវាដែលខ្លួនមានដល់អតិថិជនចាស់

### ៣.៦.២. ចំណុចខ្សោយ

ទន្ទឹមនឹងការរីកចម្រើន និងចំណុចខ្លាំងជាច្រើន គ្រឹះស្ថានក៏នៅមានចំណុចខ្សោយមួយចំនួនផងដែរ ដូចជា៖

- គ្រឹះស្ថានមានលក្ខខណ្ឌ និងមានដំណាក់កាលច្រើនក្នុងការផ្តល់កម្ចីទៅឲ្យអតិថិជន
- ទំហំកម្ចីនៅមានកម្រិតនៅឡើយ
- ផ្តល់កម្ចីតែជាប្រាក់រៀល និងប្រាក់ដុល្លារ
- ពុំទាន់មានសេវាកម្មកាត ATM នៅតាមបណ្តាសាខា

### ៣.៦.៣. ឱកាស

ចំណុចដែលជាឱកាសរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត មានដូចជា៖

- ដោយហេតុថាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត ជាគ្រឹះស្ថានមួយដែលមានបណ្តាញពេញផ្ទៃប្រទេស បានធ្វើឲ្យរាល់សេវាកម្មរបស់គ្រឹះស្ថាននេះមានភាពងាយស្រួលក្នុងការទៅដល់ប្រជាពលរដ្ឋស្ទើរគ្រប់តំបន់ ដែលធ្វើឲ្យប្រជាពលរដ្ឋទាំងនោះមានការយល់ដឹង ហើយស្គាល់គ្រឹះស្ថាននេះកាន់តែច្បាស់
- គ្រឹះស្ថានមានសេវាកម្មផ្ទេរប្រាក់ដែលផ្តល់ភាពងាយស្រួលដល់អតិថិជន ធ្វើឲ្យអតិថិជនងាកមកប្រើសេវាកម្មរបស់ខ្លួនវិញ
- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលទទួលប្រាក់បញ្ញើ ជាហេតុធ្វើឲ្យមានការកើនឡើងនូវទុនសម្រាប់ផ្តល់ឥណទានដើម្បីបំពេញនូវរាល់តម្រូវការរបស់អតិថិ-ជន
- ពេលមានការកើនឡើងនូវការគាំទ្រពីអតិថិជនកាន់តែច្រើន គ្រឹះស្ថានអាចអភិវឌ្ឍន៍ខ្លួនក្លាយជាធនាគារ ដែលបម្រើសេវាកាន់តែទូលំទូលាយដល់អតិថិជន។

### ៣.៦.៤. ការគំរាមគំហែង

ក្រៅពីចំណុចមានឱកាស គ្រឹះស្ថានក៏ប្រឈមមុខនឹងការគំរាមគំហែងបណ្តាល មកពីកត្តាផ្សេងៗដែលរួមមាន ៖

- ការកើនឡើងនូវធនាគារ ក៏ដូចជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បានធ្វើឲ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹតមានដៃគូប្រកួតប្រជែងកាន់តែច្រើន

- ការប្រែប្រួលរបបនយោបាយ ជាកត្តាដែលប៉ះពាល់ដល់ស្ថេរភាពហើយអាចបណ្តាលឲ្យមានហានិភ័យ
- កង្វះខាតនូវសេវាកម្មដើម្បីផ្តល់ជូនអតិថិជនតាមតម្រូវការ
- ការប្រកួតប្រជែងលើអត្រាការប្រាក់ទាំងប្រាក់បញ្ញើ និងប្រាក់កម្ចី
- ការបិទបាំងក្លែងបន្លំព័ត៌មានពីសំណាក់អតិថិជន និងអាជ្ញាធរ ធ្វើឲ្យឥណទានដែលបានបញ្ចេញទៅអាចខូច នាំឲ្យគ្រឹះស្ថានមានការខាតបង់។

# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការចុះកម្មសិក្សាស្រាវជ្រាវ និងវិភាគទៅលើស្ថានភាពជាក់ស្តែងនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត សាខាស្រុកបាត្តំ ក្រោមប្រធានបទស្តីពី " ការគ្រប់គ្រងឥណទានខ្នាតតូច និងខ្នាតមធ្យម" យើងសង្កេតឃើញថា គ្រឹះស្ថានមានការកើនឡើងនូវអតិថិជនក៏ដូចជា ការផ្តល់ឥណទានរបស់ខ្លួនពីមួយឆ្នាំទៅមួយឆ្នាំ។ ស្របនឹងការកើនឡើងនូវទំហំឥណទានដែលគ្រឹះស្ថានបានបញ្ចេញ ការខូចខាតនូវឥណទានទាំងនោះមានទំហំតិចតួចដែលមិនមានការជះឥទ្ធិពលអាក្រក់ដល់គ្រឹះស្ថានឡើយ។ ហើយវាបានបញ្ជាក់ឲ្យឃើញថាគ្រឹះស្ថានបានអនុវត្តទៅតាមគោលការណ៍របស់ខ្លួនបានយ៉ាងល្អ ដើម្បីបញ្ចេញឥណទានទៅដល់អតិថិជន និងធ្វើការពង្រឹងសមត្ថភាពរបស់ខ្លួនក្នុងគោលបំណងដើម្បីកាត់បន្ថយកម្រិតហានិភ័យឥណទានឲ្យនៅទាបបំផុត។ នៅក្នុងដំណើរការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានការអនុវត្តបានយ៉ាងត្រឹមត្រូវច្បាស់លាស់គ្រប់គ្រាន់តាមគោលការណ៍ និងនីតិវិធីឥណទានពីមន្ត្រីឥណទាន និងទទួលបានការអនុម័តផ្តល់ឥណទានពីប្រធានភ្នាក់ងារឥណទាន។ មុននឹងធ្វើការសម្រេចចិត្តផ្តល់ឥណទានភ្នាក់ងារមន្ត្រីឥណទានត្រូវចុះទៅដល់ទីកន្លែងរបស់អតិថិជន ដើម្បីធ្វើការត្រួតពិនិត្យដោយផ្ទាល់ទៅលើទ្រព្យសម្បត្តិដែលត្រូវដាក់ធានា និងសង្កេតមើលពីជីវភាពរស់នៅរបស់អតិថិជនក្នុងគោលបំណងធ្វើឲ្យប្រាកដពីការគ្រប់គ្រងព័ត៌មានដែលមានរបស់អ្នកខ្ចី។ ការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត គឺប្រកបដោយសុក្រឹតភាព មិនមានការរើសអើងចំពោះអតិថិជនណាមួយឡើយ។ ដោយមានការសហការគ្នាជាមួយនឹងភាគីដែលពាក់ព័ន្ធដូចជា ផ្នែកឥណទាន ផ្នែកគណនេយ្យ និងផ្នែកទីផ្សារបានធ្វើឲ្យការគ្រប់គ្រងឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត ទទួលបានជោគជ័យ។

សរុបសេចក្តីមក ការគ្រប់គ្រងឥណទានខ្នាតតូច និងខ្នាតមធ្យមនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត សាខាស្រុកបាត្តំ ទទួលបានជោគជ័យទៅបានអាស្រ័យលើអ្នកគ្រប់គ្រង និងបុគ្គលិកទាំងអស់មានការសហការគ្នាបានយ៉ាងល្អ ដែលធ្វើឲ្យគ្រឹះស្ថានកាន់តែមានភាពរីកចម្រើននៅពេលបច្ចុប្បន្ន និងទៅអនាគត ហើយក៏ដើម្បីជួយលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដែលមានតម្រូវការមូលធន ក៏ដូចជាប្រព័ន្ធសេដ្ឋកិច្ច និងប្រព័ន្ធហិរញ្ញវត្ថុនៅកម្ពុជាឲ្យមានភាពរីកចម្រើន។

## ២. ការផ្តល់អនុសាសន៍

តាមការសិក្សាដោយផ្ទាល់នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត សាខាស្រុកបាត្តំ បានបង្ហាញពីចំណុចខ្លាំង និងចំណុចខ្សោយមួយចំនួន។ ទោះបីជាគ្រឹះស្ថានមានចំណុចខ្លាំងក្នុងការប្រកបអាជីវកម្មរបស់ខ្លួនជាច្រើនក៏ដោយ ក៏គ្រឹះស្ថាននៅតែមានចំណុចដែលត្រូវកែសម្រួល និងត្រួតពិនិត្យសារ

ជាថ្មីទៅតាមតម្រូវការរបស់អតិថិជននាពេលបច្ចុប្បន្ន។ ដូច្នេះដើម្បីជួយជាគំនិតដល់ការអភិវឌ្ឍន៍របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត សាខាស្រុកបាភ្នំ ឲ្យកាន់តែមានភាពជោគជ័យ និងមានការទទួលស្គាល់កាន់តែច្រើនពីសំណាក់អតិថិជនលើអាជីវកម្មរបស់ខ្លួនថែមមួយកម្រិតទៀតនោះ គ្រឹះស្ថានគួរតែមានគោលការណ៍មួយចំនួនបន្ថែមទៀតដូចជាៈ

- គ្រឹះស្ថានគួរតែបង្កើតផលិតផលឥណទានបន្ថែមទៀតដើម្បីទាក់ទាញអតិថិជនថ្មី
- បង្កើតការផ្សព្វផ្សាយឲ្យធំទូលាយជាងមុន ដើម្បីឲ្យសាធារណៈជនបានស្គាល់កាន់តែច្បាស់អំពីការផ្តល់សេវា និងផលិតផលរបស់ខ្លួន
- គួរតែកាត់បន្ថយចំណាយសោហ៊ុយឥណទាន និងចំណាយលើការរៀបចំឯកសាផ្សេងៗ ដើម្បីទាកទាញអតិថិជនឲ្យប្រើសេវាឥណទានរបស់គ្រឹះស្ថានកាន់តែច្រើន
- បន្ថែមរយៈពេលខ្លីឲ្យមានរយៈពេលវែងជាងរយៈពេលបច្ចុប្បន្ន ដើម្បីឲ្យអតិថិជនមានពេលវេលាគ្រប់គ្រាន់ក្នុងការសងត្រឡប់មកវិញ
- ធ្វើការបណ្តុះបណ្តាល និងហ្វឹកហាត់បន្ថែមទៅលើភ្នាក់ងារឥណទានចំពោះគោលការណ៍ថ្មីៗ ដើម្បីបង្កើតសមត្ថភាពការងាររបស់ខ្លួន។

ជាទីបញ្ចប់ទោះបីជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹតមានចំណុចខ្លាំង ឬក៏ចំណុចខ្សោយក៏ដោយ ក៏គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត នូវតែមានការរីកចម្រើន។ ហើយសង្ឃឹមថា រាល់គ្រប់យោបល់ទាំងអស់នេះ និងមិនផ្តល់នូវផលប៉ះពាល់អ្វីដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត ឡើយ ហើយវានឹងក្លាយជាប្រយោជន៍សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងការកែលម្អរលើចំណុចខ្សោយរបស់ខ្លួន។ ទោះវាត្រឹមត្រូវ ឬមានការខុសឆ្គងយ៉ាងណាក៏សូមចាត់ទុកជាចំណុចនៃការពិចារណា ដើម្បីឲ្យសាខាកាន់តែមានភាពល្អប្រសើរ និងជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលនាំមុខក្នុងប្រទេសកម្ពុជា។

# ឯកសារយោង

## ឯកសារជាភាសាខ្មែរ


- ហ៊ីង ថូរ៉ាក់ស៊ីន និង ហ៊ាន សាហ៊ីប, "វចនានុក្រមបច្ចេកស័ព្ទសេដ្ឋកិច្ច"
- ធនាគារជាតិនៃកម្ពុជា, ២០០៨ "ច្បាប់ក្រមអនុវត្តចំពោះធនាគារ និង ហិរញ្ញវត្ថុ"
- អេង កែវពិសិដ្ឋ " ការគ្រប់គ្រងឥណទាន" (២០១២)
- ហ៊ីង ថូរ៉ាក់ស៊ី និងហ៊ាន សាហ៊ីប(២០០៨) " វចនានុក្រមបច្ចេកស័ព្ទសេដ្ឋកិច្ច"
- ម៉ៃ សុខជេដ្ឋា ,២០០៥, "ស្ថាប័នមីក្រូហិរញ្ញវត្ថុកម្ពុជា"
- រុន សិរីមាលា និងសុខ ថានីន " ការផ្តល់ឥណទានខ្នាតតូចបំផុត និងខ្នាតតូច" (២០១១)
- សួន ចំរើន " រូបិយវត្ថុ និងធនាគារ" (២០១១)
- ងួន ហេង " រូបិយវត្ថុ និងធនាគារ"(២០១១)
- សុខ ចំរើន និង ឡេង សុភក្រ្ត,(២០១៣), "ទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ"
- កាន់ ដានី និង ឡេង ណាឌី " នីតិវិធីនៃការផ្តល់ឥណទានរបស់ធនាគារពាណិជ្ជក្រោមប្រទេសនៃកម្ពុជា", (FTB),២០១២
- ព្រុំ សុគុណ " គណិតវិទ្យាហិរញ្ញវត្ថុ"(២០១១)
- ចាប់ សុវណ្ណលីដា និងឡង់ សុធីរ៉ា " ឥណទានមុខជំនួញខ្នាតមធ្យម",(២០១២)
- Robert Cole & Lon Mishler "Consumer and Business Credit Management"(1998), 11th Edition
- Milland Sathye, "Credit Analysis & Lending Management", (2003),
- Prum Sokun "Fundamentals of Corporate Finance I" Chapter 6, Second Edition
- Timothy J. Beihler "The Mathematics of Money",2008
- Sector highlight: Cambodia Microfinance: Development and Challenges by by Mr.Kim Vada, Deputy Director General for National Bank of Cambodia, on March 15-17, at Dhaka, Bangladesh
- http://www.amret.com.kh/amret/index.php/km/2012-08-06-03-28-30/2012-10-01-06-35-24
- www.nbc.org.kh/legislation/law_on_banking_and_financial_institution.php, ច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ
- http://www.nbc.org.kh/economic_research/mfis_reports.php